គណៈកម្មាធិការ
សហប្រតិបត្តិការ
ដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
pour le Cambodge

# ឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរទៅលើជីវភាពរស់នៅ នៅតំបន់ជនបទ

## បទពិសោធន៍ដែលទទួលបានពីកម្មករកាត់ដេរ និង គ្រួសារនៅតំបន់ជនបទ ក្នុងខេត្តព្រៃវែង



**គំរោងវិភាគបញ្ហាអភិវឌ្ឍន៍**

**សិក្ខាកាមនៃវគ្គសិក្សាជាន់ខ្ពស់ជំនាន់ទី ១ និង ក្រុមអេឌីអាយ**

**តុលា ២០០៥**

# ឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរទៅលើជីវភាពរស់នៅ នៅតំបន់ជនបទ

## បទពិសោធន៍ដែលទទួលបានពីកម្មករកាត់ដេរ និង គ្រួសារនៅតំបន់ជនបទ ក្នុងខេត្តព្រៃវែង

គំរោងវិភាគបញ្ហាអភិវឌ្ឍន៍

សិក្ខាកាមនៃវគ្គសិក្សាជាន់ខ្ពស់ជំនាន់ទី ១ និង ក្រុមអេឌីអាយ

ខែ តុលា ២០០៥

# មាតិការឿង


សេចក្តីថ្លែងអំណរគុណ ៣

សេចក្តីសង្ខេប ៤

សេចក្តីផ្តើម ៥

    ទិសដៅនៃការស្រាវជ្រាវ ៧

    វិធីសាស្ត្រស្រាវជ្រាវ ៧

ការលូតលាស់ និង លទ្ធភាពបន្តដំណើរការតទៅមុខនៃឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកម្ពុជា ៨

បទពិសោធន៍របស់កម្មកររោងចក្រកាត់ដេរមកពីខេត្តព្រៃវែង ២៤

បទពិសោធន៍នៃក្រុមគ្រួសារនៅខេត្តព្រៃវែងដែលមានសមាជិកគ្រួសារធ្វើជាកម្មករ ៣៨

ករណីសិក្សាមួយចំនួននៃក្រុមគ្រួសារនៅខេត្តព្រៃវែងដែលមានសមាជិកជាកម្មករ ៤៩

សេចក្តីសន្និដ្ឋាន ៦៨

ឧបសម្ព័ន្ធទី១: ឈ្មោះសិក្ខាកាម និងក្រុមអេឌីអាយ ៧២

ឯកសារស្រាវជ្រាវរបស់គំរោងអេឌីអាយ ៧៣

# ការថ្លែងអំណរគុណ

ក្រុមគំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (ក្រុមអេឌីអាយ) នៃអង្គការស៊ីស៊ីស៊ី និងសិក្ខាកាមប្រចាំវគ្គជាន់ខ្ពស់ទាំងអស់សូមសំដែងនូវការកោតសសើរចំពោះលោក លោកស្រីដែលបានចូលរួមនៅក្នុងការស្រាវជ្រាវនេះ ជាពិសេសកម្មកររោងចក្រកាត់ដេរនៅក្នុងទីក្រុងភ្នំពេញ និងក្រុមគ្រួសារនៅឯខេត្តព្រៃវែងដែលមានសមាជិកក្នុងបន្ទុកបានមកធ្វើជាកម្មកររោងចក្រកាត់ដេរ។ បុគ្គលិកនៃអង្គការកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ និង កម្មករដែលទទួលបន្ទុកនៅតាមមណ្ឌលជួបជុំកម្មករដែលជាដៃគូរបស់អង្គការនេះ បានជួយរៀបចំការងារចុះស្រាវជ្រាវផ្ទាល់ជាមួយកម្មករតាមតំបន់មួយចំនួននៅក្នុងទីក្រុងភ្នំពេញ។ មានការជួយជ្រោមជ្រែងស្រដៀងគ្នានេះដែរគឺ អង្គការសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (ប៉ាដិក) ដែលដឹកនាំដោយលោកស្រី ប៊ូ ចន្ទ លោក កែប កណ្ណារ៉ូ និង លោក ស្រី កុសល បានជួយសំរបសំរួលអោយមានការស្រាវជ្រាវនៅតាមមូលដ្ឋាន ក្នុងខេត្តព្រៃវែង។ នៅឯភ្នំពេញ ក្រុមអ្នកស្រាវជ្រាវក៏មានឱកាសបានជួបពិភាក្សាជាមួយ លោក សុក ហាច នៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា លោកកង ច័ន្ទតារ៉ាវ័ត្ន នៃវិទ្យាស្ថានកម្ពុជា ដើម្បីសិក្សាការអភិវឌ្ឍន៍ និង លោក ជេម ប្រ៊ូវ នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ។ លោកស្រីរេបេខា ខាថាឡា (ហៅ ភីម) និងបុគ្គលិកនៃអង្គការ Crossroads to Development បានជួយក្រុមអេឌីអាយក្នុងការប្រើប្រាស់កម្មវិធីកុំព្យូទ័រ SPSS ។ លោក ថា សុផល នៃការអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (ស៊ីស៊ីស៊ី) បានជួយផ្តល់ការគាំទ្រផ្នែកភស្តុភាដល់ក្រុមស្រាវជ្រាវ ក្នុងដំណើរការស្រាវជ្រាវទាំងមូល ។ សូមបញ្ជាក់ថា ទស្សនៈ និងគំនិតនានាដែលបានលើកឡើងនៅក្នុងការស្រាវជ្រាវនេះ គឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធទាំងស្រុង ។

អង្គការ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ក៏បានជួយគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការបោះពុម្ពផ្សាយនូវរបាយការណ៍ស្រាវជ្រាវនេះដែរ ។

សូមបញ្ជាក់: រូបភាពនៅក្របមុខ ត្រូវបានផ្តល់ដោយអង្គការ Womyn’s Agenda for Change

# សេចក្តីសង្ខេប

ការស្រាវជ្រាវរបស់គំរោងវិភាគបញ្ហាអភិវឌ្ឍន៍នៃអង្គការស៊ីស៊ីស៊ីនេះ មានបំណងស្វែងយល់អំពី ការរីកលូតលាស់ និងលទ្ធភាពដែលនាំអោយមានដំណើរការទៅមុខនៃឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកម្ពុជា និងកត់ត្រាទុកនូវបទពិសោធន៍ផ្ទាល់នៃកម្មករកាត់ដេរដែលមកពីខេត្តព្រៃវែង ព្រមទាំងពិនិត្យមើលនូវការរួមចំណែកនៃឧស្សាហកម្មកាត់ដេរទៅលើការលើកកំពស់ជីវភាពគ្រួសារនៅខេត្តព្រៃវែង និងដោយឡែក ស្វែងយល់ពីឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរ ទៅលើទំនាក់ទំនងយេនឌ័រក្នុងគ្រួសារនៅខេត្តព្រៃវែង ។ ការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សាររបស់ប្រទេសកម្ពុជា កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មជាមួយសហគមន៍អ៊ឺរ៉ុប និងសហរដ្ឋអាមេរិក ការប្រកាន់ខ្ជាប់នូវស្តង់ដារការងារក្នុងស្មារតីទទួលខុសត្រូវចំពោះសង្គម ការចូលរួមយ៉ាងសំខាន់ពីសំណាក់មន្ត្រីរាជរដ្ឋាភិបាល និងមន្ត្រីនៃសមាគមផលិតកររោងចក្រកាត់ដេរនៃប្រទេសកម្ពុជា (GMAC) និងឥទ្ធិពលនៃកូតាសម្លៀកបំពាក់ បានចូលរួមចំណែកក្នុងការជំរុញអោយមានការលូតលាស់នៃឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកម្ពុជា ។ ទោះបីថា ការបញ្ចប់ប្រព័ន្ធកូតាទូទាំងពិភពលោកនៅចុងឆ្នាំ ២០០៤កន្លងមកនេះបានគំរាមកំហែងដល់ការនាំចេញសម្លៀកបំពាក់នាពេលអនាគត ក៏ឧស្សាហកម្មនេះ នៅតែដំណើរការជាបន្តនៅក្នុងឆមាសទី ១នៃឆ្នាំ ២០០៥ នេះ ។ តែក៏នៅតែមានការទាមទារអោយមានកំណែទំរង់ក្នុងទ្រង់ទ្រាយធំ នៅក្រោយពេលបញ្ចប់ប្រព័ន្ធកូតា ដើម្បីអោយឧស្សាហកម្មនេះ អាចមានលទ្ធភាពប្រកួតប្រជែងជាបន្តទៅទៀត ។

ការជួបប្រទះគ្រោះរាំងស្ងួត និងទឹកជំនន់ជាប់ៗគ្នាតាំងពីឆ្នាំ ២០០១ មក ធ្វើអោយខូចខាតទិន្នផលស្រូវ និងបានធ្វើអោយក្រុមគ្រួសារនៅតំបន់ជនបទក្នុងខេត្តព្រៃវែងជួបនូវការខ្វះខាតស្បៀងយ៉ាងខ្លាំងនិងជំពាក់បំណុលច្រើនដោយសារការចំណាយសំរាប់ធ្វើស្រែចំការ ។ ដូច្នេះ ការចំណាកស្រុកមករកការងារធ្វើនៅតាមរោងចក្រកាត់ដេរជាជំរើសមួយដែលមានការចាប់អារម្មណ៏ក្នុងការទទួលនូវប្រាក់ចំណូល ។ ដោយសារបានធ្វើការនៅរោងចក្រ ធ្វើអោយឋានៈ និងតួនាទីរបស់ស្ត្រីនៅក្នុងគ្រួសារបានប្រសើរឡើង តែការខិតខំធ្វើការងារលើសម៉ោងដោយសារមានការងារច្រើនត្រូវបំពេញ បានធ្វើអោយកម្មកររោងចក្រមានទុក្ខកង្វល់ និងមានបញ្ហាសុខភាព ។ ប្រការសំខាន់ដែលគួរធ្វើការកត់សំគាល់នោះគឺ ការដែលកម្មកររោងចក្រអាចផ្ញើប្រាក់កាសទៅដល់ក្រុមគ្រួសារនៅឯតំបន់ជនបទដែលបានរងគ្រោះដោយមហន្តរាយធម្មជាតិ មានលទ្ធភាពទិញស្រូវ និងស្បៀងអាហារផ្សេងៗទៀត ចំណាយលើសុខភាព យកទៅធ្វើស្រែ និងសងបំណុលគេ ។ ជាទូទៅ លុយដែលបានផ្ញើទៅផ្ទះនោះ ត្រូវបានយកទៅចំណាយសំរាប់តែការខ្វះខាតស្បៀងអាហារក្នុងគ្រួសារ ជាជាងយកទៅប្រកបមុខជំនួញខ្នាតតូច ដើម្បីទទួលបាននូវប្រាក់ចំណូល ។ ដូច្នេះ ជាលទ្ធផល ឧស្សាហកម្មកាត់ដេរមិនបានធ្វើអោយជីវភាពក្រុមគ្រួសារនៅតំបន់ជនបទប្រសើររុងរឿងទេ តែបានត្រឹមជួយទប់ទល់នូវការខ្វះខាតនៅក្នុងគ្រួសារប៉ុណ្ណោះ ។

# ឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរទៅលើជីវភាពរស់នៅ នៅតំបន់ជនបទ

## បទពិសោធន៍ដែលទទួលបានពីកម្មករកាត់ដេរ និង គ្រួសារនៅតំបន់ជនបទ ក្នុងខេត្តព្រៃវែង

## សេចក្តីផ្តើម

ការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចពីសេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចទីផ្សាររបស់ប្រទេសកម្ពុជានៅដើមទសវត្ស ១៩៩០ ជាកត្តាជំរុញអោយមានវិនិយោគទុនបរទេសផ្ទាល់យ៉ាងច្រើន ព្រមទាំងការធ្វើឯកជនភាវូបនីយកម្មនៃឧស្សាហកម្មផងដែរ ។ កត្តានេះបានបង្កើតអោយមានបរិយាកាសធ្វើពាណិជ្ជកម្ម ជាពិសេសគឺ ឧស្សាហកម្មកាត់ដេរដែលមានការរីកលូតលាស់តាំងពីពេលនោះមក ។ ទន្ទឹមនឹងនេះដែរ ការបង្កើតបានរាជរដ្ឋាភិបាលកម្ពុជា តាមរយៈ ការបោះឆ្នោតបែបប្រជាធិបតេយ្យនា ឆ្នាំ ១៩៩៣ បានជំរុញអោយប្រទេសកម្ពុជាបង្កើតបាននូវទំនាក់ទំនងផ្នែកពាណិជ្ជកម្មឡើងវិញ ជាមួយរដ្ឋាភិបាលនៃបស្ចឹមប្រទេស ។ ការនាំចេញសម្លៀកបំពាក់បានកើនឡើងយ៉ាងឆាប់រហ័សក្រោយឆ្នាំ ១៩៩៦ នៅពេលដែលកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មត្រូវបានចុះហត្ថលេខា ដែលនៅគ្រាដំបូងបានធ្វើជាមួយសហគមន៍អ៊ឺរ៉ុប និង បន្ទាប់មកជាមួយសហរដ្ឋអាមេរិក ។ នៅក្នុងឆ្នាំ ២០០៤ ឧស្សាហកម្មកាត់ដេរនៅកម្ពុជាទាំងមូលរកបានចំណូលសរុប ១៩៥០ លានដុល្លារ ( មួយពាន់ប្រាំបួនរយហាសិបលានដុល្លារ) ពីរោងចក្រកាត់ដេរ ២០៦ ដែលក្នុងនោះមានកម្មករធ្វើការសរុបចំនួន ២៤៥.០០០នាក់ ។

ក្នុងពេលដែលរោងចក្រភាគច្រើនបានបើកទ្វារនៅទីក្រុងភ្នំពេញ ប្រជាជននៅតំបន់ជនបទ បាននាំគ្នាចូលមកទីក្រុងដើម្បីមករកការងារធ្វើនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ ។ ភាគច្រើននៃអ្នកចំណាកស្រុកមករកការងារធ្វើគឺជាស្ត្រីនៅវ័យក្មេងដែលមកពីខេត្តដែលនៅជិតក្រុងភ្នំពេញ ។ ការដែលរោងចក្រតម្រូវអោយមានការជ្រើសរើសកម្មករស្ត្រីវ័យក្មេងនោះ នាំអោយមានការប្រែប្រួលគួរអោយកត់សំគាល់នូវទំនៀមទម្លាប់ដែលធ្លាប់មាននៅតំបន់ជនបទពោលគឺពីមុន បុរសដែលនៅក្នុងតំបន់ជនបទ បានធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ដើម្បីមករកការងារធ្វើទៅតាមរដូវកាល ចំណែកឯស្ត្រីវិញ ជាពិសេសស្ត្រីនៅលីវ ច្រើនតែនៅឯផ្ទះ តែពេលនេះស្ត្រីជាច្រើនបានចេញពីផ្ទះរបស់ខ្លួនពីតំបន់ជនបទ ដើម្បីមករកការងារធ្វើ ។ តាមពិត ឱកាសមានការងារធ្វើដែលទទួលបានចំណូលជាប្រាក់ដុល្លារគឺជាកត្តាទាក់ទាញខ្លាំងមួយដែលធ្វើអោយស្ត្រីមករកការងារធ្វើនៅភ្នំពេញ ។ ទន្ទឹមនឹងនេះដែរ កត្តាជំរុញពីមូលដ្ឋានក៏ជាកត្តាមួយខ្លាំងណាស់ដែរ ។ ជាក់ស្តែង ការជួបប្រទះនូវគ្រោះទឹកជំនន់ និងរាំងស្ងួតផ្ទួនៗគ្នា ការចំណាយខ្ពស់សំរាប់ធ្វើស្រែចំការ និងការបានទិន្នផលទាបជាបន្តបន្ទាប់ ទើបធ្វើអោយពួកគេត្រូវចាកចេញទៅរកឱកាសការងារផ្សេងទៀត ។ ក្នុងពេលជាមួយគ្នានោះដែរ គេឃើញមានឱកាសតិចតួចសំរាប់ធ្វើការ ក្រៅពីការងារធ្វើស្រែចំការ ។

ដូច្នេះ ការចំណាកស្រុកឆ្ពោះមកកាន់ទីក្រុងភ្នំពេញ ទៅប្រទេសថៃ និងទៅកាន់ប្រទេសវៀតណាម បានក្លាយទៅជាយុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិតជាទូទៅមួយសំរាប់ប្រជាជនក្រីក្រពីតំបន់ជនបទ ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មផ្នែកកាត់ដេរជាមួយសហរដ្ឋអាមេរិក មានភ្ជាប់ទៅនឹងលក្ខខ័ណ្ឌនៃការលើកកំពស់ស្តង់ដាការងារហើយគេឃើញថា កម្មការបានទទួលផលប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ ។ ទោះជាយ៉ាងណាក្តី ស្ត្រីត្រូវធ្វើការជាច្រើនម៉ោង ដើម្បីអាចបែងចែកនូវចំណែកណាមួយនៃប្រាក់ចំណូលរបស់គេ សំរាប់ក្រុមគ្រួសារនៅឯខេត្តព្រៃវែង ។ ដោយសារបញ្ហានេះ ទើបធ្វើអោយពួកគេមានការនឿយហត់ និងចុះខ្សោយកម្លាំង ។ លើសពីនេះទៅទៀត កម្មករជាច្រើនបានទ្រាំរស់នៅក្នុងកន្លែងមួយដែលមានគ្នាច្រើនចង្អៀត ហើយខ្វះខាតច្រើនយ៉ាង។ ទោះជាមានស្ថានភាពបែបនេះក៏ដោយ ពួកគេនៅតែខិតខំស៊ូទ្រាំនឹងការងារ ហើយនឹងឆ្លៀតឱកាសធ្វើអោយខ្លួនបានសប្បាយខ្លះៗ ក្នុងជីវភាពនៅទីក្រុង ។ ទាំងនេះជាការបញ្ជាក់អោយឃើញច្បាស់ពីទឹកចិត្តមុតមាំរបស់ពួកគេក្នុងការជួយលើកស្ទួយគ្រួសារ ដែលកំពុងស្ថិតនៅឯជនបទ។ តែទោះជាយ៉ាងណាក្តី ពួកគេត្រូវជួបឧបសគ្គមួយទៀតគឺ ការប្រែប្រួលដែលបានកើតមាននាចុងឆ្នាំ ២០០៤ ។ ដូច្នេះ ដោយសារតែពួកគេមានការពឹងផ្អែកតែទៅលើឱកាសការងារដែលមាននៅក្នុងរោងចក្រកាត់ដេរ ពេលនោះ អនាគតការងាររបស់កម្មករត្រូវបានទទួលរងនូវការគំរាមកំហែងនៅចុងឆ្នាំ ២០០៤ ក្នុងខណៈដែលកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មត្រូវបានផុតកំណត់ ហើយនិងការកើនឡើងនូវការប្រកួតប្រជែង នៅក្នុងទីផ្សារសម្លៀកបំពាក់នៅលើពិភពលោក ។ បញ្ហាដែលបានលើកមកនេះ បាននាំអោយមានការពិភាក្សាដេញដោលគ្នាយ៉ាងច្រើនអំពី លទ្ធភាពនៃការបន្តដំណើរការទៅមុខនៃឧស្សាហកម្មកាត់ដេរ និងផលវិបាកដែលនឹង កើតមានមកលើសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ។

ក្នុងគោលបំណងអោយមានការយល់ដឹងអំពី សារៈសំខាន់នៃការលូតលាស់របស់ឧស្សាហកម្ម និងពាណិជ្ជកម្ម សំរាប់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ ក្រុមអេឌីអាយបានធ្វើការស្រាវជ្រាវនេះឡើងដោយផ្តោតលើឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ មកលើជីវភាពរស់នៅ នៅតំបន់ជនបទ ក្នុងខេត្តព្រៃវែង ។ ការស្រាវជ្រាវនេះចង់ស្វែងយល់អំពីការរីកលូតលាស់ និងលទ្ធភាពដែលនាំអោយមានដំណើរការតទៅមុខនៃឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកម្ពុជា កត់ត្រាទុកនូវបទពិសោធន៍ផ្ទាល់នៃកម្មករកាត់ដេរដែលមកពីខេត្តព្រៃវែង ពិនិត្យមើលនូវការរួមចំណែកនៃឧស្សាហកម្មកាត់ដេរទៅលើការលើកកំពស់ជីវភាពគ្រួសារនៅក្នុងឃុំពីរ នៅឯខេត្តព្រៃវែង និងស្វែងយល់អំពីឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរ មកលើទំនាក់ទំនងយេនឌ័រនៅក្នុងគ្រួសារទាំងនេះ ។

## និសដៅនៃការស្រាវជ្រាវ

- កំណត់រកមើលនូវការរីកលូតលាស់ និងលទ្ធភាពដែលនាំអោយមានដំណើរការទៅមុខនៃឧស្សាហកម្ម កាត់ដេរនៅក្នុងប្រទេសកម្ពុជា
- កត់ត្រាទុកនូវបទពិសោធន៍ផ្ទាល់នៃកម្មករកាត់ដេរ ដែលមកពីខេត្តព្រៃវែង
- ពិនិត្យមើលនូវការរួមចំណែកនៃឧស្សាហកម្មកាត់ដេរ ទៅលើការលើកកំពស់ជីវភាពគ្រួសារនៅឯខេត្តព្រៃវែង
- ស្វែងយល់អំពីឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរទៅលើទំនាក់ទំនងយេនឌ័រក្នុងគ្រួសារនៅខេត្តព្រៃវែង

## វិធីសាស្ត្រស្រាវជ្រាវ

ការចុះប្រមូលពត៌មាននៅតាមមូលដ្ឋានផ្ទាល់ត្រូវបានធ្វើឡើងនៅក្នុងចន្លោះខែ កញ្ញា និង ខែ តុលា ២០០៤ នៅទីក្រុងភ្នំពេញជាមួយកម្មករកាត់ដេរមកពីខេត្តព្រៃវែង ។ ការប្រមូលពត៌មាននេះរួមមាន ការពិភាក្សាជាក្រុមតូចៗ និងការប្រើបញ្ជីសំណួរសំភាសន៍កម្មករកាត់ដេរផ្ទាល់នៅនឹងទីកន្លែងដែលពួកគេកំពុងស្នាក់នៅ តាមរយៈវិធីសាស្ត្រ PURPOSIVE ។ ការចុះប្រមូលពត៌មាននៅក្នុងឃុំ ក្រាំងស្វាយ និង ឃុំ ល្វា ស្រុកព្រះស្តេច ខេត្តព្រៃវែង ក៏បានធ្វើផងដែរ នៅក្នុងចន្លោះខែ កញ្ញា និង ខែ តុលា ២០០៤ ។ ការប្រមូលពត៌មាននេះ ក៏មានរៀបចំជាការពិភាក្សាក្នុងក្រុមតូចៗ និងបញ្ជីសំណួរសំភាសន៍ក្រុមគ្រួសារដែលមានសមាជិកក្នុងបន្ទុកធ្វើជាកម្មករកាត់ដេរ តាមរយៈវិធីសាស្ត្រ PURPOSIVEផងដែរ ។ បន្ថែមពីលើនេះទៀត ក៏មានការសំភាសន៍ស៊ីជំរៅជាមួយគ្រួសារដែលមានសមាជិកធ្វើជាកម្មករកាត់ដេរ ដើម្បីស្វែងយល់អោយកាន់តែមានភាពពិស្តារថែមទៀតអំពី ដំណើរការ និងទំនាក់ទំនង ។ នៅភ្នំពេញ ក៏មានការសំភាសន៍ជាមួយសេដ្ឋវិទូកម្ពុជាពីរនាក់ និង ប្រធានគំរោងនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដើម្បីបង្កើនការយល់ដឹងអំពី ដំណើរការ និងលទ្ធភាពបន្តដំណើរការទៅមុខនៃឧស្សាហកម្មកាត់ដេរនេះ ។

# ការលូតលាស់ និង លទ្ធភាពបន្តដំណើរការទៅមុខក្នុងរយៈពេលវែងនៃឧស្សាហកម្មកាត់ដេរ នៅក្នុងប្រទេសកម្ពុជា[១]

## ការលូតលាស់នៃឧស្សាហកម្មកាត់ដេរនៅប្រទេសកម្ពុជា

ជាងមួយទសវត្សរ៍កន្លងទៅនេះ ឧស្សាហកម្មកាត់ដេរនៅកម្ពុជា បានរីកលូតលាស់ក្នុងកំរិតមួយដ៏គួរឱ្យភ្ញាក់ផ្អើល ។ ការនាំចេញសម្លៀកបំពាក់បានកើនឡើងពី ២៦.៧ លានដុល្លារ នៅឆ្នាំ១៩៩៥ រហូតដល់ទៅ ១.៦ពាន់លានដុល្លារ នៅឆ្នាំ ២០០៣ ។ នៅឆ្នាំ ២០០៣ វិស័យឧស្សាហកម្មនេះបានស្រូបយកកំលាំងពលកម្មបានជាង ២៣០.០០០នាក់ (ស្មើ៦៥% នៃអ្នកដែលមានការងារធ្វើក្នុងវិស័យផលិតកម្មទូទាំងប្រទេស) និងរកបានចំណូលជារូបិយប័ណ្ណបរទេស (៧៨% នៃចំណូលដែលបានមកពីការនាំចេញសរុប) ។ កម្មករដែលធ្វើការក្នុងរោងចក្រគឺជាស្ត្រីវ័យក្មេងមកពីតំបន់ជនបទ ហើយពួកគេបានផ្ញើប្រាក់កំរៃមួយចំនួនទៅឱ្យក្រុមគ្រួសាររបស់ពួកគេ នៅតាមបណ្តាខេត្តផ្សេងៗ ។ តាមការប៉ាន់ប្រមាណគឺ ក្នុងចំណោមប្រជាជនកម្ពុជាសរុបចំនួន ១៣លាននាក់ មាន១លាននាក់ដែលបានទទួលផលប្រយោជន៏ដោយប្រយោល ឬដោយផ្ទាល់ពីវិស័យឧស្សាហកម្មនេះ ។

ភាគច្រើននៃម្ចាស់រោងចក្រកាត់ដេរជាជនបរទេសដែលមានមកពីប្រទេសចិន ហុងកុង តៃវ៉ាន់ និងសាធារណរដ្ឋកូរ៉េ ហើយរាល់ផលិតផលកាត់ដេរត្រូវបាននាំចេញយកទៅលក់ ។ នៅក្នុងឆ្នាំ ២០០៣ ផលិតផលកាត់ដេរសរុបក្នុងប្រទេសកម្ពុជា ៧៣% ត្រូវបាននាំចេញទៅសហរដ្ឋអាមេរិក ដោយឡែក ២៣% ត្រូវបានលក់នៅសហគមន៏អឺរ៉ុប ។ ដោយគ្មានប្រព័ន្ធផ្គត់ផ្គង់នៅក្នុងប្រទេសនោះ ម្ចាស់រោងចក្រនៅកម្ពុជាបាននាំចូលនូវវត្ថុធាតុដើមស្ទើតែទាំងស្រុង ដូចជា សសៃអំបោះ ក្រណាត់ គ្រឿងសំភារៈផ្សេងៗ និងសំភារៈវេចខ្ចប់មួយចំនួន ។ ដោយសារតម្លៃនាំចូលខ្ពស់ បានធ្វើឱ្យមានការកាត់បន្ថយតំលៃបន្ថែមក្នុងស្រុកនៃការនាំចេញសំលៀកបំពាក់ក្នុងឆ្នាំ២០០៣ ប្រហែល៤៤២លានដុល្លារ ដែលចំនួននេះគឺប្រហែល ២៨% នៃចំណូលដែលបានមកពីការលក់សម្លៀកបំពាក់សរុប ។

[១] ផ្នែកនេះ ដកស្រង់ចេញពី Keith Stuart-Smith, Rekha Dayal, Peter Brimble and Sam Holl, *Phase 1 Report: Cambodia's Garment Industry – Meeting the Challenges of the Post Quota Environment,* (Phnom Penh: Asian Development Bank and Kingdom of Cambodia, Ministry of Commerce, October 2004) and Lynn Salinger et al, *Measuring Competitiveness and Labor Productivity in Cambodia's Garment Industry,* (Washington, DC: Nathan Associates Inc. for the United States Agency for International Development, June 2005).

## *កិច្ចព្រមព្រៀងពាណិជ្ជកម្ម ជាមួយសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក*

ក្នុងវិសាលភាពដ៏ធំទូលាយ ការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សលើវិស័យកាត់ដេរនៅប្រទេសកម្ពុជាគឺជាលទ្ធផលនៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌ (MFA) ដែលបានអនុម័តក្នុងរយៈកាលជាង៣០ឆ្នាំមកហើយ ដោយបណ្តាប្រទេសដែលចំណាយថ្លៃដើមខ្ពស់ខាងឧស្សាហកម្មវាយនភ័ណ្ឌ ដើម្បីកាត់បន្ថយផលិតកម្មវាយនភ័ណ្ឌរបស់ប្រទេសទាំងនោះក្នុងអត្រាមួយដែលអាចគ្រប់គ្រងបាន ។ ការកំណត់បរិមាណដែលត្រូវបានគេហៅថា កូតា ត្រូវបានធ្វើឡើងតាមរយៈការចរចារទ្វេភាគី ឬតាមរយៈឯកតោភាគីទៅលើបណ្តាប្រទេសដែលមានផលិតករសំលៀកបំពាក់ធ្វើការប្រកួតប្រជែងដោយផ្ទាល់ជាមួយផលិតករនៃសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ។ លទ្ធផលមួយគួរអោយកត់សំគាល់នៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌគឺ ការរីកលូតលាស់នៃវិស័យឧស្សាហកម្មកាត់ដេរនៅប្រទេសមួយចំនួនរួមទាំងប្រទេសកម្ពុជាផងដែលមិនសូវមានបទពិសោធន៍នៅក្នុងវិស័យកាត់ដេរនេះ ហេតុនេះហើយ ទើបមិនដាក់កំហិតបរិមាណសំរាប់ការនាំចេញនោះទេ ។

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ កម្ពុជាបានទាក់ទាញវិនិយោគទុនរបស់បរទេសខាងវិស័យកាត់ដេរទៅបានដោយសារតម្លៃកំលាំងពលកម្មថោក ការមិនដាក់កំរិតកូតាក្នុងទីផ្សារពិភពលោកសំខាន់ៗ និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (GSP) ដើម្បីមានលទ្ធភាពឈានចូលទៅក្នុងទីផ្សារសហគមន៍អឺរ៉ុប ។ នៅគ្រាដំបូង ចាប់ពីឆ្នាំ១៩៩៥ សហគមន៍អឺរ៉ុបគឺ ជាទីផ្សារដំបូងសំរាប់កម្ពុជាក្នុងការនាំចេញសំលៀកបំពាក់ ។ លុះមកដល់ឆ្នាំ ១៩៩៩ ច្រកចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិកដោយអនុគ្រោះសំរាប់កម្ពុជា ក៏ត្រូវបានទទួល ទោះជាមានការកំរិតកូតាលើទំនិញ១២មុខក៏ដោយ ការនាំចេញទៅទីផ្សារអាមេរិកតាំងពីពេលនោះមក នៅមានការកើនឡើងគួរអោយកត់សំគាល់ ។ នៅខែមករា ឆ្នាំ១៩៩៩ កិច្ចព្រមព្រៀងវាយនភ័ណ្ឌទ្វេភាគីរវាងសហរដ្ឋអាមេរិក-កម្ពុជា ត្រូវបានរៀបចំឡើងដោយភ្ជាប់កូតាសំរាប់នាំចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ជាមួយលក្ខខ័ណ្ឌគោរពនូវស្តង់ដារពលកម្មអន្តរជាតិដែលត្រួតពិនិត្យដោយអង្គការពលកម្មអន្តរជាតិ(ILO) ។ នេះជាលើកដំបូង និងជាពេលវេលាដែលសហរដ្ឋអាមេរិកភ្ជាប់កំណើនកូតាប្រចាំឆ្នាំជាមួយនឹងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍ស្តង់ដារការងារ ។ នៅខែធ្នូ ឆ្នាំ២០០១ កិច្ចព្រមព្រៀងត្រូវបានផ្តល់បន្ថែមពាឆ្នាំទៀតរហូតដល់ពេលផុតកំណត់នៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌ (ជាមួយនឹងប្រព័ន្ធកូតា) នៅចុងឆ្នាំ២០០៤ ។ នៅឆ្នាំ ២០០១ ប្រទេសកម្ពុជាមានលទ្ធភាពចូលទីផ្សារសហគមន៍អឺរ៉ុបដោយប្រព័ន្ធរួចពន្ធ និងគ្មានកូតា (quota-free and duty-free) ដែលស្ថិតក្រោមប្រព័ន្ធអនុគ្រោះទូទៅរបស់សហគមន៍អឺរ៉ុបដែលអាចនាំចូលគ្រប់មុខទំនិញ លើកលែងតែសព្វាវុធ (EU’s Everything But Arms) សំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងសាកលលោក ។ នៅក្នុងរយៈពេលនេះដែរ សមាគមផលិតករកាត់ដេរកម្ពុជា (GMAC) បានចាប់ផ្តើមបង្កើតឡើងនៅឆ្នាំ១៩៩៦ ហើយបានជួយជំរុញរាជរដ្ឋាភិបាល ខិតខំប្រឹងប្រែងដើម្បីទទួលបាននូវប្រព័ន្ធពាណិជ្ជកម្មពិសេស ពីបណ្តាលប្រទេសឧស្សាហកម្មជឿនលឿន និងសហគមន៍អឺរ៉ុប ។

### *ការចូលរួមចំណែករបស់ឧស្សាហកម្មកាត់ដេរ   ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច*

ដូចបានលើកឡើងខាងដើមមកហើយថា ឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានការលូតលាស់យ៉ាងខ្លាំង ដោយមានការកើនឡើងនូវតំលៃនៃការនាំចេញសម្លៀកបំពាក់ពី ២៦.៧លានដុល្លារនៅឆ្នាំ១៩៩៥ រហូតដល់ជាង ១.៦ពាន់លានដុល្លារនៅឆ្នាំ២០០៣ (សូមមើលតារាងទី១) ។ នៅក្នុងឆ្នាំ២០០៣ ការនាំចេញទៅទីផ្សារអាមេរិក គឺមានតំលៃសរុប ១.១២ពាន់លានដុល្លារ ដែលក្នុងនោះ ៦៣%គឺជាតម្លៃមុខទំនិញស្ថិតក្រោមប្រព័ន្ធកូតា ។ ក្នុងឆ្នាំនេះដែរ ការនាំចូលទៅក្នុងទីផ្សារសហគមន៍អឺរ៉ុប គឺមានចំនួនលើសពី ៤០៧លានដុល្លារ ដែលក្នុងនោះ ៥៩%គឺជាតម្លៃមុខទំនិញស្ថិតក្រោមប្រព័ន្ធកូតា ។ ជាមួយនឹងការពង្រីកប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃប្រទេសកាណាដា ដែលគ្របដណ្តប់ទៅលើវាយនភ័ណ្ឌ និងសំលៀកបំពាក់នោះគឺ ការនាំចេញទៅទីផ្សារដទៃទៀតរបស់កម្ពុជា បានកើនដល់ ៧៩លានដុល្លារ គិតត្រឹមខែមករា ឆ្នាំ ២០០៣ ។ កាលពីឆ្នាំ ឆ្នាំ១៩៩៥ ការនាំចេញសម្លៀកបំពាក់មានតែ៣.១% ប៉ុណ្ណោះនៃការនាំចេញទំនិញសរុបរបស់ប្រទេស តែនៅឆ្នាំ ២០០៣ វិញគឺ មានរហូតដល់ទៅ ៧៨.២% ។ ដូច្នេះក្នុងរយៈពេលមិនដល់១០ឆ្នាំផង ឧស្សាហកម្មនាំចេញសំលៀកបំពាក់ បានក្លាយជាក្បាលម៉ាស៊ីនយ៉ាងសំខាន់សំរាប់ការលូតលាស់របស់ប្រទេសកម្ពុជា ។

នៅឆ្នាំ២០០៤ តំលៃនៃការនាំចេញផលិតផលឧស្សាហកម្មសំលៀកបំពាក់នៃប្រទេសកម្ពុជាបានបន្តកើនឡើង ទោះបីមានបញ្ហាគំរាមកំហែងនៃការឈានចូលទីបញ្ចប់ប្រព័ន្ធកូតាទូទាំងពិភពលោកក៏ដូចប្រទេសកម្ពុជាក្តី ។ នៅដើមឆ្នាំ២០០៥ ឯកឧត្តមរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្មបានរាយការណ៍ថា ការលក់ សំលៀកបំពាក់នៅឆ្នាំ២០០៤ បានកើនឡើងរហូតដល់១.៩៥ពាន់លានដុល្លារ ហើយនឹងអាចកើនឡើង៨០% ក្នុងចំនួនសរុបនៃការនាំចេញ[២] ។

---

[២] កាសែត *The Cambodia Daily*, ចេញថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

| **តារាងទី ១៖ ការនាំចេញសំលៀកបំពាក់របស់កម្ពុជាពីឆ្នាំ១៩៩៥-២០០៣, តំលៃ និងបរិមាណនាំចេញ** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| តំលៃ (លានដុល្លា) | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
| សហរដ្ឋអាមេរិក | 0.5 | 1.6 | 109.9 | 291.8 | 516.1 | 751.3 | 828.6 | 953.5 | 1,121.1 |
| សហគមន៍អឺរុប | 25.7 | 74.8 | 112.4 | 63.1 | 136.7 | 220.8 | 309.1 | 355.7 | 407.4 |
| ប្រទេសផ្សេងៗ | 0.6 | 3.9 | 4.8 | 4.5 | 7.3 | 14.3 | 17.9 | 28.1 | 78.7 |
| **ការនាំចេញសរុប** | **26.7** | **80.3** | **227.1** | **359.4** | **660.1** | **986.4** | **1,155.6** | **1,337.2** | **1,607.1** |
| បំនែកភាគរយនៃការនាំចេញសម្លៀកបំពាក់ | 3.1 | 11.2 | 27.1 | 45.2 | 58.7 | 70.8 | 73.9 | 76.8 | 78.2 |
| | | | | | | | | | |
| បរិមាណ (លានដុំ) | | | | | | | | | |
| សហរដ្ឋអាមេរិក | 1.3 | 8.8 | 62.2 | 124.7 | 148.1 | 206.5 | 266.9 | 309.2 | 340.5 |
| សហគមន៍អឺរុប | 9.0 | 2.0 | 34.3 | 20.7 | 34.7 | 58.3 | 81.3 | 90.2 | 107.2 |
| ប្រទេសផ្សេងៗ | 0.7 | 2.0 | 15.2 | 1.1 | 3.2 | 4.4 | 4.5 | 7.4 | 18.2 |
| **ការនាំចេញសរុប** | **10.9** | **12.8** | **111.7** | **146.5** | **186.0** | **269.2** | **352.7** | **406.8** | **466.3** |
| ប្រភព៖ ក្រសួងពាណិជ្ជកម្ម cited in Stuart-Smith et al, *Phase 1 Report: Cambodia's Garment Industry* | | | | | | | | | |

## ***ចំនួនរោងចក្រ និងការងារ***

នៅក្នុងប្រទេសកម្ពុជា ចំនួននៃរោងចក្រកាត់ដេរបានកើនឡើងយ៉ាងលឿនពី ២០រោងចក្រ នៅឆ្នាំ១៩៩៥ រហូតដល់ជាង ២០០រោងចក្រនៅឆ្នាំ ២០០៤ (សូមមើលតារាងទី២)។ ដោយសាររោងចក្រកាត់ដេរខ្លះតែងតែផ្អាកប្រតិបត្តិការជារឿយៗ ឬក៏មានខ្លះបិទទាំងស្រុងតែម្តងនោះ គេមានការពិបាកក្នុងការកំណត់ចំនួនរោងចក្រជាក់លាក់ ក្នុងពេលកំណត់ណាមួយ ។ នៅឆ្នាំ ២០០៤ របាយការណ៍ជំហានទីមួយរបស់ធានាគារអភិវឌ្ឍន៍អាស៊ី បានសរសេរថា មានរោងចក្រចំនួន ៥៦ បានបិទទ្វារជាស្ថាពរ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍១៩៩០[៣] ។ ដូច្នេះ ចំនួនសរុបនៃរោងចក្រមានរហូតដល់ជាង ២៥០រោងចក្រ បើយើងបូកបញ្ចូលចំនួនរោងចក្រដែលបានបិទនោះ ។ ជាងនេះទៅទៀត មានការជួលក្រុមហ៊ុនតូចៗដែលទទួលម៉ៅការបន្តដើម្បីអោយជួយផលិតសំលៀកបំពាក់បន្ថែម

[៣] Stuart-Smith et al, *Phase 1 Report: Cambodia's Garment Industry*

នៅកំឡុងពេលដែលមានតំរូវការខ្ពស់។ រោងចក្រភាគច្រើនមានទីតាំងនៅភ្នំពេញ និងតំបន់ជុំវិញក្រុងដែលរថយន្តកុងទីន័រអាចមានលទ្ធភាពដឹកចេញចូលតាមបណ្តោយផ្លូវដែលមានចំងាយផ្លូវ ២៣០ គីឡូម៉ែត្រ ទៅដល់ផែសមុទ្រក្រុងព្រះសីហនុ ។ នៅឆ្នាំ ២០០៤ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) បានធ្វើការប៉ាន់ប្រមាណថា តម្លៃទឹកប្រាក់សរុបនៃអចលនទ្រព្យរបស់រោងចក្រចំនួន២០០ ដែលកំពុងប្រត្តិបត្តិការនៅកម្ពុជាសព្វថ្ងៃមានប្រមាណ ២៦០លានដុល្លារ ។ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ក៏បានគណនារកឃើញទៀតថា ទឹកប្រាក់វិនិយោគទុនបរទេសផ្ទាល់នៅក្នុងឧស្សាហកម្មកាត់ដេរនេះ (ដោយរួមបញ្ចូលទាំងប្រតិបត្តិការចរាចរសាច់ប្រាក់) គិតចាប់ពីចន្លោះឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០៣ មានចំនួនសរុបរហូតដល់ទៅជាង ៦០០លានដុល្លារ[៤] ។

| តារាងទី ២: ការកើនឡើងនៃរោងចក្រ និងការងារលើវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជា ១៩៩៥-២០០៤ | | |
|---|---|---|
| ឆ្នាំ | ចំនួនរោងចក្រកាត់ដេរ | ចំនួនកំលាំងពលកម្ម (នាក់) |
| 1995 | 20 | 18,700 |
| 1996 | 24 | 24,000 |
| 1997 | 67 | 51,600 |
| 1998 | 129 | 79,200 |
| 1999 | 152 | 96,600 |
| 2000 | 190 | 122,600 |
| 2001 | 186 | 188,100 |
| 2002 | 188 | 210,400 |
| 2003 | 197 | 234,000 |
| 2004 | 206 | 245,600 |

ប្រភព: ស្ថានទូតអាមេរិកនៅកម្ពុជា "Economic Significance of the Garment Sector in Cambodia," cited in Salinger et al, *Measuring Competitiveness in Cambodia's Garment Industry*

ដូចបានរៀបរាប់ខាងដើម ភាគច្រើននៃរោងចក្រកាត់ដេរគឺគ្រប់គ្រងដោយម្ចាស់មកពីប្រទេសចិន ហុងកុង តៃវ៉ាន់ និងសាធារណរដ្ឋកូរ៉េ ហើយរាល់ផលិតផលសំលៀកបំពាក់ត្រូវបាននាំចេញ។ ក្រុមហ៊ុនដែលមានម៉ាកល្បីៗ ដូចជា The Gap, Nike, Reebok, Adidas, Marks និង Spenser, Wal-Mart, Sears, និង Liz Claiborne គឺជាអ្នកទិញដ៏សំខាន់ក្នុងជំនួញនេះ ។ រោងចក្រនីមួយៗបានផលិតសំលៀកបំពាក់ច្រើនមុខជាមួយនឹងចំនួនដ៏ច្រើន ដូចជា: ខោជើងវែង សំលៀកបំពាក់រាត្រី និងអាវដែលប្រភេទផ្សេងៗ។ អ្នកវិនិយោគដែលមកពីទ្វីបអាស៊ី តែងតែមានរោងចក្រស្រដៀងគ្នានៅក្នុងប្រទេសឯទៀតនៅទ្វីបអាស៊ី ហើយបានសំរេចចិត្តធ្វើការផលិតតាមការបញ្ជាទិញ អាស្រ័យទៅតាមចំនួននៃកូតាដែលមាន គុណភាពផលិតផល តំលៃផលិតកម្ម និងពេលវេលាប្រគល់ទំនិញ។

[៤] លោក សុក ហាច "*Cambodia's Garment Industry in 2005 and Beyond*," Economic Review, Volume 1, Number 5, July-September, 2004

តាមពិត ភាគច្រើននៃរោងចក្រគឺគ្រប់គ្រងដោយបរទេសទាំងស្រុង ហើយយុទ្ធសាស្ត្រនៃការសំរេចចិត្តពីក្រៅប្រទេស បានផ្តល់ការលើកទឹកចិត្តតិចតួច សំរាប់វិនិយោគិនបន្តធ្វើការរកស៊ីនៅកម្ពុជា ក្រោមស្ថានភាពនៃកំរិតប្រកួតប្រជែងដែលមានការកើនឡើងជាលំដាប់នោះ ។

ជាមធ្យមរោងចក្រនីមួយៗមានកម្មករធ្វើការប្រហែល ១.000នាក់ ទោះបីរោងចក្រខ្លះ មានកម្មករតិចជាង ៥00នាក់ និងរោងចក្រខ្លះទៀតមានកម្មករចំនួនជាង ៥.000នាក់ ។ ក្នុងខណៈដែលមានការបញ្ជាទិញផ្លាស់ប្តូរទៅតាមរដូវកាល តំរូវការនៃកំលាំងពលកម្មតែងតែមានការប្រែប្រួលគ្រប់ពេលពីចំនួន ៦0 ទៅ ១00% ។ តាំងពីឆ្នាំ ១៩៩៥ ឧស្សាហកម្មកាត់ដេរ បានបង្កើតអោយមានការងារធ្វើ និងបានកើនឡើងយ៉ាងខ្លាំងរហូតដល់ឆ្នាំ ២00១ ហើយមានការកើនឡើងតិចតួចនៅឆ្នាំបន្តបន្ទាប់ (សូមមើលតារាងទី២) ។ ទោះបីជាមានកម្មករកាត់ដេរដែលមានចំនួន៦៥%នៃអ្នកដែលមានការងារធ្វើនៅក្នុងវិស័យផលិតកម្មក្នុងប្រទេសនៅក្នុងឆ្នាំ ២00៣ ក៏ដោយ ចំនួននេះប្រហែលស្មើនឹង៤%នៃកម្លាំងពលកម្មសរុបនៅទូទាំងប្រទេសប៉ុណ្ណោះ ព្រោះប្រជាជនកម្ពុជាភាគច្រើនគឺជាអ្នកធ្វើការងារកសិកម្ម ។

ការសិក្សាជំហានទីមួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលបានធ្វើនៅឆ្នាំ២00៤ បានប៉ាន់ប្រមាណថា កំលាំងពលកម្មនៅក្នុងវិស័យកាត់ដេរ មាន ៨៥% ជាស្ត្រី ហើយដែលចំនួននេះជិតស្មើនឹង ២0% នៃកំលាំងស្ត្រីដែលមានអាយុ១៨-២៥ឆ្នាំ ។ ការសិក្សាបានរកឃើញទៀតថា កំលាំងពលកម្មកាត់ដេរសរុបដែលមានចំនួន ២៣0.000 នាក់ បានទទួលកំរៃសរុបប្រចាំឆ្នាំប្រមាណ ១៣៥ លានដុល្លារ [៥] ។ ទំនាក់ទំនងគ្នារវាងកំណើនកូតា និងការប្រតិបត្តិតាមស្តង់ដារការងារដែលមានការទទួលខុសត្រូវចំពោះសង្គម បានធ្វើអោយកម្មករទទួលបាននូវផលប្រយោជន៏ ទោះបីមេដឹកនាំនៃសហជីពសេរីកម្មករកម្ពុជាបានទទួលស្គាល់ថា បើមិនមានការចូលរួមពាក់ព័ន្ធពីអង្គការពលកម្មអន្តរជាតិទេនោះ សហជីពរបស់លោកនឹងមានការពិបាកក្នុងការធ្វើការងាររបស់ខ្លួនប្រកបដោយឯករាជ្យភាពក៏ដោយ [៦] ។

---

[៥] Stuart-Smith et al, *របាយការណ៍ជំហានទីមួយ របស់ឧស្សាហកម្មកាត់ដេរនៅកម្ពុជា*

[៦] Elizabeth Becker, "*Labor Standards Keep Garment Industry Afloat,*" *The Cambodia Daily, May 16, 2005*

### *ភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរ*

ឧស្សាហកម្មកាត់ដេរកម្ពុជាធ្លាប់មានកម្លាំងប្រកួតប្រជែងច្រើន ដោយសារមានកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្ម និងការកំណត់កូតាជាមួយអាមេរិក និងសហគមន៍អឺរ៉ុប ។ ទោះជាយ៉ាងណាក៏ដោយ ការផុតកំណត់ប្រព័ន្ធកូតានាចុងឆ្នាំ ២០០៤កន្លងមកនេះ ធ្វើអោយកម្លាំងនៃការប្រកួតប្រជែង បានក្លាយទៅជាបញ្ហាគួរអោយព្រួយបារម្ភមួយ ព្រោះមានការពាក់ព័ន្ធទៅនឹងការចំណាយ ផ្សេងៗដែលមិនសមស្របក្នុងវិស័យកាត់ដេរដូចរៀបរាប់ខាងក្រោម ។

នៅឆ្នាំ២០០១ មានការស្រាវជ្រាវមួយរបស់វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលបានពិនិត្យមើលទៅលើ "ការចំណាយសំរាប់ការិយាធិបតេយ្យ" ទាក់ទងលើវិស័យកាត់ដេរនេះ ។ ការចំណាយនេះមានចំនួនរហូតដល់ ៧% នៃតម្លៃលក់សរុបដែលមានដូចជា ថ្លៃសុំច្បាប់អនុញ្ញាតិដើម្បីដំណើរការរោងចក្រ ច្បាប់អនុញ្ញាតិឱ្យនាំចូលវត្ថុធាតុដើម និងការនាំទំនិញចេញ ព្រមទាំងការចំណាយសំរាប់ការយឺតយ៉ាវក្នុងការទទួលបាននូវលិខិត និងសំណុំឯកសារទាំងនេះ ។ យោងតាមការសិក្សានោះ ម្ចាស់រោងចក្របានប៉ាន់ប្រមាណថា ការចំណាយសំរាប់ការិយាធិបតេយ្យនេះគឺ មានចំនួនប្រហែលស្មើនឹងប្រាក់ចំណេញសុទ្ធរបស់ពួកគេ ហើយនិងប្រហែលពាក់កណ្តាលនៃប្រាក់កំរៃរបស់កម្មករ"[៧] ។

ស្ថានភាពដែលបានរៀបរាប់ខាងលើនេះ មានការផ្លាស់ប្តូតិចតួចពីមួយឆ្នាំទៅមួយឆ្នាំ ។ នៅឆ្នាំ២០០៤ ការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានសិក្សាលំអិតទៅលើចំណុចខ្សោយមួយចំនួនក្នុងវិស័យកាត់ដេរនៅកម្ពុជា ដែលក្នុងនោះរួមមាន "ភាពស្មុគ្រស្មាញនៃបែបបទនាំចេញនាំចូល អំពើពុករលួយ និងការសូកប៉ាន់ដែលមានចំនួនរហូតដល់ ៧% នៃតម្លៃលក់សរុប បញ្ហានៃការលើកទឹកចិត្តកម្មករ និងការបង្កើនផលិតភាព ព្រមទាំងការចំណាយខ្ពស់នៃហេដ្ឋារចនាសម្ព័ន្ធ"[៨] ។ ទាក់ទងទៅនឹងបញ្ហាពុករលួយ ការសិក្សាបានបង្ហាញថា ការចំណាយក្រៅផ្លូវការគឺជាការចាំបាច់បំផុតដើម្បីទទួលបានសំណុំឯកសារដើម្បីនាំចេញផលិតផល និងមានការចំណាយក្រៅផ្លូវការថែមទៀតក្នុងការដឹកទំនិញតាមផ្លូវជាតិទៅដល់កំពង់ផែក្រុងព្រះសីហនុ ការចំណាយនៅកំពង់ផែ និងនៅពេលលើកដាក់ទំនិញលើនាវា ។ ជាងនេះទៅទៀត ចំពោះការចំណាយក្រៅផ្លូវការទៅលើសំណុំបែបបទនាំចេញនាំចូល ត្រូវបានក្រុមហ៊ុនកាត់ដេរមួយចំនួនត្អូញត្អែថា បញ្ហាការិយាធិបតេយ្យដែលពាក់ព័ន្ធនឹងនាំចូលវត្ថុធាតុដើម និងការនាំចេញផលិតផលសំរេច តែងតែបានធ្វើអោយពួកគេមានការខាតបង់ពេលវេលា និងមានការពន្យារពេលជាបន្តបន្ទាប់ដែលពួកគេមិនអាចទទួលយកបានឡើយ ។

---

[៧] លោក សុក ហាច *"ឧស្សាហកម្មកាត់ដេរនៅកម្ពុជា"* Cambodia's Development Review, លេខ៥ ចេញថ្ងៃទី ៣ ខែកក្កដា-កញ្ញា ឆ្នាំ២០០១ ។

[៨] Stuart-Smith et al, *Cambodia's Garment Industry*

រឹងការលើកទឹកចិត្តកម្មករ និងការបង្កើនផលិតភាពវិញ ការសិក្សានោះបានធ្វើការកត់សំគាល់លើបញ្ហាមួយចំនួន ដែលរួមមាន បញ្ហាវិធីសាស្ត្របណ្តុះបណ្តាល ក៏ដូចជាជំនាញដែលបានទទួលនៅមានកំរិតទាប ការមានគំលាតនៃការទំនាក់ទំនង និងការយល់ដឹងនូវវប្បធម៌ពីគ្នាទៅវិញទៅមកវាងកម្មករនិងអ្នកគ្រប់គ្រង លទ្ធភាពប្រើបច្ចេកវិទ្យាមានកំរិតទាប ការមានផលប៉ះពាល់នៅពេលដំណើការផលិតកម្មទ្រង់ទ្រាយធំ ព្រមទាំងទាក់ទងទៅលើសុខភាព និងការខ្វល់ខ្វាយរបស់កម្មករ ។ ក្រៅពីនេះ នៅមានការខ្វះខាតទៅលើហេដ្ឋារចនាសម្ព័ន្ធសំរាប់អ្នកវិនិយោគដូចជា ការផ្គត់ផ្គង់អគ្គីសនីមិនគ្រប់គ្រាន់ ព្រមទាំងមានតម្លៃខ្ពស់ទៀតផង ។ ជាងនេះទៅទៀត ប្រទេសកម្ពុជាពុំមាន កំពង់ផែសមុទ្រទឹកជ្រៅ ដូច្នេះរាល់ការនាំចេញនាំចូល ត្រូវបានផ្ទេរទំនិញនៅប្រទេសទីពាណាមួយ ដែលជាទូទៅ គេផ្ទេរនៅប្រទេសសឹង្ហបូរី ។ ការខ្វះខាតកំពង់ផែសមុទ្រទឹកជ្រៅនេះ ធ្វើអោយមានបញ្ហារាំងស្ទះដល់ការចំណាយ ពេលវេលាក្នុងការដឹកជញ្ជូនទំនិញ ។

នៅខែមិថុនា ឆ្នាំ២០០៥ ការសិក្សាមួយដែលឧបត្ថម្ភដោយ USAID បានបង្ហាញថា មានតែ៧% នៃ រោងចក្រចំនួន ៨០ដែលបានធ្វើការសិក្សាស្រាវជ្រាវ ត្រូវបានគេចាត់ទុកថា ជាសហគ្រាសដែលជាប់ចំណាត់ថ្នាក់ពិភពលោក ។ ទោះជាយ៉ាងណាក៏ដោយ មាន៧៥%ដែលគេយល់ថា មានសក្តានុពលក្នុងការកែលំអរធ្វើអោយប្រសើរឡើងបាន ក្រៅពីនោះ គឺជារោងចក្រដែលត្រូវបានចាត់ទុកថា មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីសំរេចជោគជ័យបាននៅក្នុង យុគសម័យក្រោយកូតានោះទេ ។ ការសិក្សាបានសង្កេតឃើញដែរថា បើមានការបណ្តុះបណ្តាលខាងការងារ បច្ចេកទេសនិង និងការគ្រប់គ្រង និងបច្ចេកទេសផលិតអោយបានប្រសើរ ទើបផលិតភាពអាចកើនឡើងពី១៥ ២០% ហើយបើមានការកើនឡើងនូវផលិតភាពនេះ ឧស្សាហកម្មកាត់ដេរនៅកម្ពុជា អាចទទួលបាននូវតំលៃបន្ថែម ដោយផលិតសំលៀកបំពាក់អោយមានគុណភាព និងមានតំលៃខ្ពស់[៩] ។

ដោយមានការយកចិត្តទុកដាក់ទៅលើតម្រូវការ ក្នុងការធ្វើអោយប្រសើរឡើងនូវការប្រកួតប្រជែង នៅក្នុង ឧស្សាហកម្មកាត់ដេរនោះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកំណែទំរង់ដើម្បីសំរបសំរួលពាណិជ្ជកម្មដូចជា ការសំរួលអោយមានឯកសាររដ្ឋបាលចេញចូលតែមួយ និងដំណើរការច្រកចេញចូលតែមួយនៅក្រុងព្រះសីហនុ។ នាខែ មីនា ឆ្នាំ ២០០៥ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តម **ចម ប្រសិទ្ធ** ដែលបានថ្លែងនៅឯការប្រជុំជាមួយសមាគម ផលិតកររោងចក្រកាត់ដេរកម្ពុជាបានប្តេជ្ញាថា នឹងលាលែងពីតំណែង បើអំពើពុករលួយនៅក្នុងឧស្សាហកម្មកាត់ដេរ មិនត្រូវបានកាត់បន្ថយនោះ[១០] ។

---

[៩] Salinger et al, *Measuring Competitiveness and Labor Productivity in Cambodia's Garment Industry.* See also *Economic Review*, Volume 2, Number 2, April-June, 2005

[១០] កាសែត *The Cambodia Daily*, March 14, 2005

## លទ្ធភាពបន្តដំណើរការតទៅមុខរយៈពេលវែងនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជា

នៅពេលមានការទទួលស្គាល់នូវការកើនឡើងគួរឱ្យភ្ញាក់ផ្អើលនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជា សំរាប់ការនាំចេញ ដោយសារមានប្រព័ន្ធកូតា និងការអនុគ្រោះពាណិជ្ជកម្មនោះ អ្នកសង្កេតការណ៍មួយចំនួនបានទស្សន៍ទាយថា នឹងមានការដួលរលំភ្លាមនៃឧស្សាហកម្មកាត់ដេរក្នុងឆ្នាំ២០០៥ នៅពេលដែលកូតាត្រូវបានគេលប់ចោល ។ អ្នកខ្លះទៀតដែលមានការយល់ដឹងច្រើនទៅលើកត្តាផ្សេងៗពាក់ព័ន្ធក៏បានទាយទុកជាមុនដែរថា នឹងមានការធ្លាក់ចុះជាបណ្តើរៗក្នុងរយៈពេលជាច្រើនឆ្នាំតទៅមុខទៀត។ រីឯ អ្នកដែលមានក្តីសង្ឃឹមច្រើនទៅលើលទ្ធភាពនៃកំណែទំរង់បានធ្វើការអះអាងថា ឧស្សាហកម្មមួយដែលមានការប្រកួតប្រជែងបែបនេះ អាចនឹងរក្សាបាននូវកំរិតផលិតកម្ម និងការងារអោយកម្មករធ្វើក្នុងកំរិតដូចសព្វថ្ងៃនេះដែរ។ ដោយសារការបញ្ចប់ប្រព័ន្ធកូតា អាចនឹងមានផលប៉ះពាល់ដល់ជីវិតរស់នៅរបស់កម្មកររាប់ពាន់នាក់ ព្រមទាំងជីវភាពក្រុមគ្រួសារពួកគេរស់នៅឯតំបន់ជនបទដែលពឹងលើប្រាក់ដែលបានផ្ញើនោះ ដូច្នេះ ការវិភាគទៅលើលទ្ធភាពបន្តដំណើរការវែងឆ្ងាយនៃឧស្សាហកម្មកាត់ដេរ ពិតជាមានការចាំបាច់ និងជាបន្ទាន់ទៀតផង ។

### *គំរូនៃសេណារីយ៉ូពីរៈ ដំណើរការគ្មានកំណែទំរង់ និង ដំណើរការឆ្ពោះទៅរកការស្លុតលាស់*

នៅពេលដែលការបញ្ចប់នៃប្រព័ន្ធកូតា និងការប្រមើលមើលអំពីអនាគតនៃការកើនឡើងនូវឧស្សាហកម្មកាត់ដេរត្រូវបានមជ្ឈដ្ឋានទូទៅលើកឡើងនោះ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០០៤ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានបង្កើតនូវគំរូសេណារីយ៉ូពីរ ដោយផ្អែកទៅតាមការសន្មត់មួយចំនួន[១១] ។ គំរូសេណារីយ៉ូនៃលំនាំ**ដំណើរការគ្មានកំណែទំរង់** (Laissez-faire) មានន័យថា ឧស្សាហកម្ម នេះនៅបន្តដំណើរតាមទម្លាប់កន្លងមកនោះ ត្រូវបានអ្នកវិភាគសន្មត់ថា អាចមានកំណើន ៥% ក្នុងទីផ្សារសំលៀកបំពាក់ពិភពលោក ។ គេបានសន្មត់បន្ថែមទៀតថា ការប្រកួតប្រជែងក្នុងទីផ្សារអាមេរិក នឹងមានកំរិតខ្លាំងក្លា ហើយកំរិតផលិតភាពរបស់ឧស្សាហកម្មកាត់ដេរនេះនៅតែដដែល ហើយនិងរាជរដ្ឋាភិបាលកម្ពុជា មិនមានវិធានការអ្វីដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសនៃការធ្វើពាណិជ្ជកម្មសោះ ។ យោងតាមការសន្មត់ខាងលើនេះ ការនាំចេញសំលៀកបំពាក់ពីកម្ពុជា ទៅសហរដ្ឋអាមេរិកក្នុងចន្លោះពីឆ្នាំ ២០០៥-២០១០ ធ្លាក់ចុះជាមធ្យម ៥% ក្នុងមួយឆ្នាំ ហើយតំលៃផលិតផលកាត់ដេរកាលពីមុនធ្លាប់ស្ថិតនៅក្រោមកូតានៅក្នុងទីផ្សារទាំងនោះ ក៏ធ្លាក់ចុះ ៥%ក្នុងមួយឆ្នាំដែរ ។ ក្នុងពេលជាមួយគ្នានេះដែរ គេបានសន្មត់ថា លក្ខខ័ណ្ឌនានានៅក្នុងសហគមន៍អឺរ៉ុប និង ទីផ្សារផ្សេងៗទៀតដែលរួមមានប្រទេសកាណាដា នឹងនៅតែរក្សាប្រព័ន្ធ

---

[១១] លោក សុក ហាច *"ឧស្សាហកម្មកាត់ដេរកម្ពុជា ឆ្នាំ២០០៥ និងក្រោយ២០០៥"*

អនុគ្រោះដដែល ហើយសំលៀកបំពាក់ដែលនាំចេញទៅទីផ្សារទាំងនោះ នឹងនៅតែបន្តកើនឡើង ៥%ក្នុងមួយឆ្នាំ ហើយតម្លៃមានការកើនឡើង ២% ក្នុងមួយឆ្នាំដែរនោះ ។

ចំពោះ សេណារីយ៉ូនៃដំណើរការឆ្ពោះទៅរកការលូតលាស់វិញ បង្ហាញនូវមាគាំមួយប្រកបដោយភាពសុទិដ្ឋិនិយម សំរាប់ប្រទេសកម្ពុជា ។ គេបានសន្មត់ផងដែរថា ទីផ្សារពិភពលោកសំរាប់ផលិតផលកាត់ដេរ បន្តកើនឡើង៥% ក្នុងមួយឆ្នាំ ហើយការប្រកួតប្រជែងក្នុងទីផ្សារអាមេរិកនៅតែរឹងមាំ។ ប៉ុន្តែផ្ទុយទៅវិញ គេបានសន្មត់ថា កំណែទំរង់ សេដ្ឋកិច្ច និងច្បាប់ ត្រូវបានអនុវត្តន៏ដែលជាការជំរុញអោយផលិតករសំលៀកបំពាក់ នៅតែរក្សាភាពប្រកួតប្រជែង បាន និងរក្សានូវការដណ្តើមបានទីផ្សារនៅក្នុងទីផ្សារពិភពលោកក្នុងកំរិតដដែល ។ ជាពិសេសនោះ រាជរដ្ឋាភិបាល និងឧស្សាហកម្ម នឹងខិតខំរួមគ្នាដើម្បី ១)-ធ្វើអោយប្រសើរឡើងនូវផលិតភាពនៃកំលាំងពលកម្ម ២)-បន្តរក្សា អោយបាន និងទទួលបានការរកទីផ្សារបានច្រើន ៣)-កាត់បន្ថយពេលវេលាដឹកជញ្ជូន និងបង្កើតអោយមាន អ្នកផ្គត់ផ្គង់ពីក្នុងស្រុកសំរាប់ជួយឧស្សាហកម្មនេះ ៤)- កាត់បន្ថយការចំណាយមិនចាំបាច់ និង ទី ៥)-គិតគូរ ដោះស្រាយចំពោះឧបសគ្គរារាំងនានា ។ ដូច្នេះ ចំពោះសេណារីយ៉ូនេះ ការនាំចេញសំលៀកបំពាក់របស់កម្ពុជានឹង បន្តកើនឡើង ៥%ក្នុងមួយឆ្នាំ ស្របទៅតាមកំណើននៃទីផ្សារសំលៀកបំពាក់ក្នុងពិភពលោក ។

គួរអោយកត់សំគាល់ថា ទោះបីសេណារីយ៉ូនៃដំណើរការគ្មានកំណែទំរង់ខាងលើនេះមានភាពទុទិដ្ឋិនិយមក៏ដោយ ក៏សេណារីយ៉ូនេះ មិនបានទស្សន៍ទាយថា ការនាំចេញសំលៀកបំពាក់កាត់ដេរធ្លាក់ចុះភ្លាមៗនោះដែរ ។ ទោះជា យ៉ាងណាក្តី សេណារីយ៉ូនេះ បើគិតជារួមក្នុងរយៈពេលច្រើនឆ្នាំ អាចមានការបាត់បង់ច្រើន ហើយនឹងមានផលវិបាក ខ្លាំងសំរាប់ឧស្សាហកម្មកាត់ដេរនៅកម្ពុជា។ នៅក្រោមសេណារីយ៉ូនៃដំណើរការគ្មានកំណែទំរង់នេះ ការនាំចេញ សំលៀកបំពាក់នឹងអាចធ្លាក់ចុះ ១១០លានដុល្លារនៅឆ្នាំ ២០០៧ ហើយបន្ទាប់មកជិត ៣០០លានដុល្លារ នៅឆ្នាំ ២០១០ ។ ដូចគ្នានេះដែរ នៅឆ្នាំ២០០៧ តំលៃបន្ថែមនឹងធ្លាក់ចុះដល់ ៣៣លានដុល្លារ និង ឆ្នាំ ២០១០ ធ្លាក់ចុះ ៨៩លានដុល្លារ ។ ចំពោះតំលៃពលកម្មធ្លាក់ចុះ១១លានដុល្លារនៅឆ្នាំ២០០៧ និង ៣៣លានដុល្លារ នៅឆ្នាំ២០១០។ រីឯប្រាក់ចំណេញដុលធ្លាក់ចុះ ១៤លានដុល្លារ នៅឆ្នាំ២០០៧ និង ធ្លាក់ដល់ ២៩លានដុល្លារ នៅឆ្នាំ២០១០ ។ នៅឆ្នាំ ២០១០ ការបាត់បង់ការងារនឹងកើនឡើងរហូតដល់ ៣២.០០០នាក់ និងតំលៃប្រាក់ខែធ្លាក់ចុះ ៣៣លានដុល្លារ។ ម្យ៉ាងវិញទៀត បើគិតតាមរយៈ សេណារីយ៉ូនៃដំណើរឆ្ពោះទៅរកការលូតលាស់វិញនោះ គេនឹងបានឃើញនូវ ផលប្រយោជន៏គួរអោយកត់សំគាល់ ។ នៅឆ្នាំ២០១០ តំលៃនៃការនាំចេញសំលៀកបំពាក់នឹងកើនឡើង ១.៣ ពាន់ លានដុល្លារ ការងារថ្មីនឹងកើនឡើងរហូតដល់ជិត ១០០.០០០នាក់ ហើយការចំណាយទៅលើប្រាក់ខែកម្មករ នឹង កើនឡើង ១៧៥ លានដុល្លារដែរ ។ ដូច្នេះ ការទទួលបានប្រាក់ខែក្នុងកំរិតកើនឡើងសំរាប់កម្មករ មានន័យថា នឹងមានការកើនឡើងក្នុងការផ្ញើប្រាក់កាសទៅឯស្រុកកំណើតរបស់ពួកគេនៅតំបន់ជនបទផងដែរ ។

## ***ឥទ្ធិពលរបស់ចិនក្នុងទីផ្សារពិភពលោក***

មានការវាយតំលៃមួយអំពីលទ្ធភាពនៃប្រទេសកម្ពុជាឈានចូលក្នុងទីផ្សារសំលៀកបំពាក់ពិភពលោក ក្រោយពេលបញ្ចប់កូតាដែលបានតម្រូវអោយមានការពិភាក្សាគ្នាអំពី វត្តមាននៃប្រទេសចិនដែលកំពុងតែបង្ហាញខ្លួនជាបណ្តើរៗនៅក្នុងទីផ្សារពិភពលោកនេះ ។ ក្នុងខណៈពេលដែលបណ្តាប្រទេសផ្សេងៗទៀតនៅក្នុងអាស៊ីដូចជា ឥណ្ឌា បង់ក្លាដែស និងវៀតណាម អាចធ្វើការប្រកួតប្រជែងជាមួយប្រទេសកម្ពុជាដែរនោះ តែការពិតប្រទេសចិនត្រូវបានគេមើលឃើញថា ប្រទេសដែលនឹងមានឥទ្ធិពលគំរាមកំហែងខ្លាំងក្លាបំផុត ។ ដោយសារប្រទេសចិនមានការផ្គត់ផ្គង់ផ្នែកវាយនភ័ណ្ឌពីក្នុងប្រទេសរបស់គេ ការមានកំលាំងពលកម្មដ៏ច្រើន និងការវិនិយោគទុនបរទេសផ្ទាល់ រួមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដ៏ល្អនោះ ប្រទេសចិនបានទទួលផលប្រយោជន៍យ៉ាងគួរអោយកត់សំគាល់ពីការនាំចេញសម្លៀកបំពាក់ ទោះជាមានការកំហិតកូតាក៏ដោយ ។ ជាក់ស្តែង តំលៃនាំចេញសំលៀកបំពាក់របស់ប្រទេសចិនបានកើនឡើងពី ៩.៧ពាន់លានដុល្លារនៅឆ្នាំ១៩៩០ ទៅដល់ ៤១.៣ពាន់លានដុល្លារនៅក្នុងឆ្នាំ២០០២ ។ ជាមួយការលប់ចោលនូវប្រព័ន្ធកូតានៅចុងឆ្នាំ២០០៤ ការនាំចេញសំលៀកបំពាក់របស់ប្រទេសចិនអាចនឹងកើនឡើងពី ៥០ពាន់លានដុល្លារក្នុងឆ្នាំ២០០៥ រហូតដល់ ៦៥ពាន់លានដុល្លារក្នុងឆ្នាំ២០១០ ។ ការកើនឡើងនៃពាណិជ្ជកម្មចិនបែបនេះ ជាពិសេស ការឈានចូលទៅក្នុងទីផ្សារអាមេរិកដែលធ្លាប់មានប្រព័ន្ធកូតានោះ អាចនឹងរារាំងនូវការលូតលាស់នៃវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជាជាបន្តទៀត ។

ដោយមានការទទួលស្គាល់នៃសន្ទុះកើនឡើងរបស់ចិននៅក្នុងវិស័យពាណិជ្ជកម្មកាត់ដេរថា ជាឧបសគ្គដល់ផលិតករកាត់ដេររបស់ខ្លួននោះ ប្រទេសអាមេរិកបានជ្រោមជ្រែងធ្វើអោយប្រទេសចិនបានចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដោយដាក់លក្ខខ័ណ្ឌមួយគឺ "**របាំងការពារ**" ឬដាក់កូតាដើម្បីកំណត់ក្នុងការនាំចូលសំរាប់ប្រទេសចិន ។ នៅពេលជិតផុតកំណត់នៃការកិច្ចព្រមព្រៀងវាយនភ័ណ្ឌ ផលិតករអាមេរិកបានធ្វើការស្នើសុំទៅរដ្ឋាភិបាលរបស់គេដើម្បីរក្សាទុកកូតាចំនួន ១៥ ក្នុងចំណោមកូតាទាំង ៩១ ដែលត្រូវបញ្ចប់នៅចុងឆ្នាំ២០០៤ ដោយសំអាងថា ចិនអាចនឹងបំផ្លាញដល់ឧស្សាហកម្មវាយនភ័ណ្ឌរបស់អាមេរិកបាន ។ បើមានការគោរពតាមចំនួនកូតាថ្មីដូចបានរៀបរាប់មកនេះ វាជាការដាក់កំហិតប្រទេសចិន អោយនាំចេញកើនឡើងក្នុងកំរិតត្រឹមតែ ៧.៥% នៅក្នុងផ្នែកនីមួយៗ ។ ប្រទេសចិនបានធ្វើការឆ្លើយតបយ៉ាងខ្លាំងថា លក្ខខ័ណ្ឌ "**របាំងការពារ**" ត្រូវបានរៀបចំឡើងដើម្បីត្រៀមទប់ទល់ទៅនឹងការកើនឡើងនូវការនាំចូលដ៏កំហ៊ុក តែរឿងនេះមិនទាន់នឹងបានកើតចេញជារូបរាងនៅឡើយទេ[១២] ។

---

[១២] របាយការណ៍ពិសេសអំពី: ឧស្សាហកម្មវាយនភ័ណ្ឌ *អ្នកសេដ្ឋកិច្ច*, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៤

ការពិតលក្ខខ័ណ្ឌ "**របាំងការពារ**" ដើម្បីប្រឆាំងទៅនឹងសន្ទុះកើនឡើងភ្លាមៗនៃការនាំចូលរបស់ចិនក្នុងឆ្នាំ ២០០៥ ត្រូវបានគិតគូរដោយយោងតាមទស្សនៈមួយដែលទស្សនាវដ្តី *អ្នកសេដ្ឋកិច្ច* ដែលមាននិន្នាការខាងប្រទេសអាមេរិក និងសហគមន៍អឺរ៉ុប បានអះអាងនៅចុងឆ្នាំ ២០០៤ ថា អ្នកទិញនឹងមានឱកាសជ្រើសរើសសម្លៀកបំពាក់ពីច្រើនប្រភពតាមការពេញចិត្តរបស់ពួកគេ ។ ដូចគ្នានេះដែរ ការបង្ខំឱ្យចិនទទួលយកនូវកូតាថ្មី ជាការផ្តល់នូវអន្តរកាលមួយសំរាប់ការចូលទៅក្នុងទីផ្សារដែលគ្មានប្រព័ន្ធកូតា ដែលនេះជាការបង្អង់ល្បឿននៃការលូតលាស់របស់ប្រទេសចិន និងជាការបន្ធូរបន្ថយផលប៉ះពាល់នៃការផ្លាស់ប្តូរដែលអាចធ្វើឱ្យមានក្លាំងក្លាក្នុងថ្ងៃអនាគត[១៣] ។ ចំពោះប្រទេសកម្ពុជាវិញ វិធានការទាំងនេះ នឹងនាំអោយកម្ពុជាមានពេលវេលាសំរាប់អនុវត្តន៏នូវកំណែទំរង់ដែលជាប្រការចាំបាច់សំរាប់ការប្រកួតប្រជែងអោយបានប្រសើរឡើង ។

## *ការវិវត្តន៍នៅក្នុងឆ្នាំ ២០០៥*

ដូចដែលបានគិតទុកជាមុន ការលុបចោលនូវកូតារបស់អាមេរិក ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥ បាននាំមកនូវការផ្លាស់ប្តូរទីផ្សារពិភពលោកយ៉ាងខ្លាំងសំរាប់ផលិតផលសំលៀកបំពាក់ ។ ជាពិសេស ប្រទេសចិន ទទួលបានការកើនឡើងយ៉ាងខ្លាំងនូវការនាំចេញសំលៀកបំពាក់ ក្នុងអំឡុងពេលតែពីរបីខែដំបូងក្នុងការធ្វើពាណិជ្ជកម្មក្រោយដំណាក់ការគ្មានកូតានេះ ។ ដើម្បីជាការបញ្ជាក់ពីកំនើននេះអោយកាន់តែច្បាស់ ប្រទេសចិនដណ្តើមបានទីផ្សារសម្លៀកបំពាក់ក្នុងត្រីមាសទី១នៃឆ្នាំ ២០០៥ ចំនួន ២០,១% នៃទីផ្សារសម្លៀកបំពាក់សរុបនៅអាមេរិក បើធៀបទៅនឹងឆ្នាំ ២០០៤ មានតែ ១៣,៨%ប៉ុណ្ណោះ ។ បើយើងប្រៀបធៀប ប្រទេសម៉ិកស៊ិក កូរ៉េខាងត្បូង ម៉ូរីទុស និងអាហ្វ្រិចខាងត្បូង ទទួលរងនូវការធ្លាក់ចុះយ៉ាងខ្លាំង ក្នុងការលក់សំលៀកបំពាក់របស់ពួកគេ ។ ការដករបាំងដែលបានឈានទៅរកការប្រកួតប្រជែងនៅដើមឆ្នាំ ២០០៥នេះ គឺជាសម្ពាធមួយធ្វើឱ្យតំលៃសំលៀកបំពាក់នៅលើទីផ្សារពិភពលោក បានធ្លាក់ចុះ[១៤] ។

ប្រទេសកម្ពុជាមិនបានរួចផុតពីនិន្នាការប្រែប្រួលដែលកើតឡើងនៅទូទាំងពិភពលោកនោះទេ ។ ជាក់ស្តែងនៅក្នុងអំឡុងពេលពីរបីខែដំបូងនៅដើមឆ្នាំ ២០០៥ មានរោងចក្រចំនួន១២ ត្រូវបានគេរាយការណ៍ឱ្យដឹងថា បានបិទទ្វារ ហើយរោងចក្រចំនួន ២៤ ផ្សេងទៀតគឺ បិទទ្វារបណ្តោះអាសន្នដែលបណ្តាលឱ្យកម្មករប្រហែល ៣០.០០០ នាក់ បានបាត់បង់ការងារធ្វើ ។ ក្នុងពេលជាមួយគ្នានោះផងដែរ មានរោងចក្រចំនួន ១៣ បានបើកដំណើរការដែលផ្តល់

---

[១៣] របាយការណ៍ពិសេសអំពី: ឧស្សាហកម្មវាយនភ័ណ្ឌ *អ្នកសេដ្ឋកិច្ច*, ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០០៤

[១៤] Salinger et al, *Measuring Competitiveness and Labor Productivity in Cambodia's Garment Industry*

ការងារថ្មីដល់កម្មករចំនួន១០.០០០នាក់[១៥] ។ នៅពាក់កណ្ដាលឆ្នាំ ២០០៥ អគ្គលេខាធិការនៃសមាគមផលិតករ រោងចក្រកាត់ដេរកម្ពុជា បានរាយការណ៍ឱ្យដឹងថា ការងារនៅក្នុងឧស្សាហកម្មកាត់ដេរបានកើនឡើងវិញដែលជាការ ទប់ទល់ទៅនឹងការបាត់បង់ការងារកន្លងមក ហើយឥឡូវនេះមានកម្មករសរុបប្រហែល ២៦៥.០០០ នាក់[១៦] ។ បន្ទាប់ពីនោះមក អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មបរទេសនៃក្រសួងពាណិជ្ជកម្មបានប្រកាសថា នៅខណៈដែល រោងចក្រចំនួន ៩ បានបិទទ្វារ គេឃើញមានរោងចក្រចំនួន ៣០ បានបើកដំណើរការ[១៧] ។ ចំពោះ អង្គការ ពលកម្មអន្តរជាតិវិញបានរាយការណ៍ថា កំរិតនៃការផ្ដល់ការងារត្រូវបានរក្សាឱ្យមានស្ថេរភាពបាន ទោះជាមាន ការប្រែប្រួលខ្លះ ពោលគឺ មានរោងចក្រខ្លះមានកម្មកររហូតជាង ៥.០០០នាក់[១៨] ។

ផ្អែកទៅលើតែបរិមាណផលិតកម្មសុទ្ធសាធ ប្រទេសកម្ពុជាអាចគ្រប់គ្រងខ្លួនឯងបាននូវកំរិតដូចពេលមុន នៅក្នុង រយៈកាលប៉ុន្មានខែដើមឆ្នាំ ក្រោយពេលគ្មានកូតានោះ ។ ឧទាហរណ៍ដូចជា នៅពេលដែលប្រទេសចិន ទទួលបាន ជោគជ័យយ៉ាងខ្លាំង ក្នុងការដណ្ដើមទីផ្សារសំលៀកបំពាក់ទៅលើប្រភេទទំនិញជាច្រើននៅសហរដ្ឋអាមេរិក នៅ អំឡុងពេល៤ខែដំបូងនៅឆ្នាំ ២០០៥ ដោយធៀបទៅនឹងឆ្នាំមុននោះ ប្រទេសកម្ពុជាក៏ទទួលបានកំណើនចំពោះ ទំនិញចំនួន៥ប្រភេទ លើកលែងតែ ២ ប្រភេទដែលបានធ្លាក់ចុះ (សូមមើលតារាងទី ៣) ។ ការប៉ាន់ប្រមាណរបស់ អង្គការពលកម្មអន្តរជាតិ បានឱ្យដឹងថា នៅក្នុងត្រីមាសទី១នៅឆ្នាំ២០០៥ ការនាំចេញសំលៀកបំពាក់របស់ប្រទេស កម្ពុជាទៅកាន់សហរដ្ឋអាមេរិក បានកើនឡើង ១១% គិតជាបរិមាណសំលៀកបំពាក់ និងកើនឡើង ១៧% គិតជា តម្លៃដុល្លារ[១៩] ។ ដូចគ្នានេះដែរ តម្លៃលក់ចេញទូទាំងពិភពលោក ក៏មានការកើនឡើងដែរ ។ ទស្សនាវដ្ដី *អ្នកសេដ្ឋកិច្ច* បានឱ្យដឹងថា តម្លៃនៃការនាំចេញសំលៀកបំពាក់ប្រទេសកម្ពុជា មានការកើនឡើងចំនួន ៥.៥% ចាប់ពីខែមករា-ឧសភា ធៀបទៅនឹងរយៈពេលដដែលនៅក្នុងឆ្នាំមុន[២០] ។ នេះសបញ្ជាក់ឱ្យឃើញច្បាស់ថា នៅក្នុង រយៈពេលខ្លី ឧស្សាហកម្មកាត់ដេរនៅកម្ពុជា មិនដួលរលំឡើយ ។

---

[១៥] Elena Lesley, “*20,000 Garment Jobs Lost in 2005*,” Phnom Penh Post, May 6-19, 2005

[១៦] Timothy Wheeler, “*Scrappy Garment Industry Making Gains in Post-Quota Environment*,” Phnom Penh Post, July 15-28, 2005.

[១៧] *The Cambodia Daily*, August 6-7, 2005

[១៨] *The Cambodia Daily*, October 26, 2005

[១៩] *The Cambodia Daily*, October 26, 2005

[២០] *The economist*, September 10, 2005

| តារាងទី ៣: ការប្រៀបធៀបបរិមាណនៃការនាំចូលប្រភេទសំលៀកបំពាក់សំខាន់ៗ ទៅសហរដ្ឋអាមេរិក រវាងប្រទេសកម្ពុជា និងចិន នៅខែ មករា-មេសា ២០០៤ និងខែ មករា-មេសា ២០០៥ គិតជាលានម៉ែត្រការ៉េ | | | | | | |
|---|---|---|---|---|---|---|
| | នាំចូលពីប្រទេសកម្ពុជា | | | នាំចូលពីប្រទេសចិន | | |
| ប្រភេទសំលៀកបំពាក់ | មករា-មេសា ២០០៤ | មករា-មេសា ២០០៤ | %នៃការផ្លាស់ប្តូរ | មករា-មេសា ២០០៤ | មករា-មេសា ២០០៥ | %នៃការផ្លាស់ប្តូរ |
| Cotton nightwear | 44.7 | 40.2 | -10.1 | 9.4 | 71.4 | 660 |
| Manmade fiber Nightwear | 19.3 | 25.8 | 33.7 | 8.5 | 29.6 | 248 |
| Cotton slacks | 15.2 | 23.2 | 52.6 | 5.2 | 87.5 | 1,584 |
| Cotton knit blouses | 7.1 | 10.4 | 46.5 | 2.2 | 38.4 | 1,639 |
| Cotton Trousers | 7.3 | 9.1 | 24.7 | 3.3 | 50.9 | 1,420 |
| Manmade fiber knit blouses | 3.1 | 3.8 | 22.6 | 9.1 | 38.7 | 324 |
| Manmade fiber skirts | 2.8 | 2.6 | -7.1 | 1.9 | 6.9 | 257 |
| ប្រភព: ក្រសួងពាណិជ្ជកម្មសហរដ្ឋអាមេរិក។ ការិយាល័យវាយនភ័ណ្ឌ និងសំលៀកបំពាក់។ ទិន្និន័យបឋមផ្តល់ឱ្យនៅត្រឹមខែមេសា ឆ្នាំ ២០០៥ ដែលដកស្រង់ចេញពីឯកសារ *Measuring Competitiveness and Labor Productivity in Cambodia's Garment Industry*, ខែមិនា ឆ្នាំ ២០០៥។ | | | | | | |

ទោះជាយ៉ាងណាក៏ដោយ និន្នាការទូទៅនៃការបញ្ជាទិញទំនិញបន្ថែមទៀត និងការធ្លាក់ចុះនូវតម្លៃ គឺជាចំនុចគួរឱ្យព្រួយបារម្ភមួយ ជាពិសេសចំពោះ កម្មករ "កាត់ដេរយកបុង" ដែលទទួលបានប្រាក់កំរៃផ្អែកទៅលើបរិមាណសំលៀកបំពាក់ដែលដេរបាន។ នាខែឧសភា ២០០៥ អនុប្រធានសហជីពសហព័ន្ធកម្មករកាត់ដេរប្រជាធិបតេយ្យកម្ពុជា បានបញ្ជាក់ឱ្យដឹងថា និយោជករោងចក្រខ្លះបានបញ្ចុះតម្លៃប្រាក់ឈ្នួលកម្មករដេរយកចំនួនបុង[២១]។ ដូច្នេះតម្លៃធ្លាក់ចុះនៃផលិតផលកាត់ដេរដែលបណ្តាលឱ្យមានការកាត់បន្ថយប្រាក់កំរៃពេលកម្មគឺ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការដកចេញនូវប្រព័ន្ធកូតា ។ នៅឆ្នាំ ២០០៤ ការសិក្សាមួយរៀបចំសំរាប់រដ្ឋាភិបាលកម្ពុជា ជាការស្រាវជ្រាវដោយធនាគារពិភពលោក បានឱ្យដឹងថា តម្លៃរបស់ផលិតផលក្នុងពេលមានកូតា មានតម្លៃខ្ពស់ជាង តម្លៃដែលគ្មាន

[២១] Lesley, "*20,000 Garment Jobs Lost in 2005*"

កូតាចំនួនប្រហែល ៥ដង ពោលគឺខុសគ្នាប្រហែលពី ៥ ទល់នឹង ១ ដុល្លារ ក្នុងសម្លៀកបំពាក់មួយម៉ែត្រការ៉េ[២២] ។ នៅពេលដែលបរិមាណមានការកើនឡើង ហើយតម្លៃមានការធ្លាក់ចុះ ឧស្សាហកម្មនេះត្រូវត្រូវតែបង្កើនសមត្ថភាពប្រកួតប្រជែង តែមិនត្រូវភ្លេចប្រតិបត្តិតាមស្តង់ដារការងារនោះឡើយ ។

នៅពាក់កណ្តាលឆ្នាំ ការនាំចេញផលិតផលសំលៀកបំពាក់របស់ប្រទេសចិន មានការកើនឡើងខ្លាំង បណ្តាលឱ្យសហរដ្ឋអាមេរិក និងសហគមអឺរ៉ុប ដាក់របាំងការពារ ។ នៅខែឧសភា ឆ្នាំ ២០០៥ សហរដ្ឋអាមេរិកបានប្រកាសថាបានកំណត់កូតាសំរាប់កំណើននៃការនាំចូលត្រឹម ៧.៥%ប្រចាំឆ្នាំសំរាប់ប្រភេទសម្លៀកបំពាក់ដូចជា អាវដៃវែងនិងដៃខ្លី ខោជើងវែង និងខោទ្រនាប់ដែលនាំចូលពីប្រទេសចិន[២៣] ។ ដូចគ្នានេះដែរ នៅខែមិថុនា ឆ្នាំ ២០០៥ សហគមអឺរ៉ុប បានចុះអនុសារណៈនៃការឃោគយល់គ្នាដែលដាក់កំនត់ឱ្យប្រទេសចិន នាំចូលទំនិញសំលៀកបំពាក់ចំនួន១០ ប្រភេទ នៅក្នុងចន្លោះពី ៨-១២,៥%[២៤] ។ លុះមកដល់ដើមខែកញ្ញា ឆ្នាំ ២០០៥ សហគមអឺរ៉ុប បានចរចារឡើងវិញនូវកិច្ចព្រមព្រៀងនេះ ដើម្បីព្រមទទួលយកអាវរងាធំ និងខោជើងវែងនាំចូលពីប្រទេសចិនដែលបានជាប់គាំងក្នុងចំនួនដ៏ច្រើននៅឯកំពង់ផែនៅអ៊ឺរ៉ុប ក្នុងលក្ខខ័ណ្ឌដូរដោះមួយគឺ ការកាត់បន្ថយការនាំចេញរបស់ប្រទេសចិនសំរាប់ឆ្នាំក្រោយ ។ វិធានការនេះ នឹងមានប្រសិទ្ធិភាពក្នុងរយៈពេលបណ្តោះអាសន្ន ដូច្នេះ ការដាក់របាំងការពារ ដែលជាលក្ខខ័ណ្ឌមួយជួយអោយប្រទេសចិន បានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនាឆ្នាំ ២០០១នោះ នឹងមានសុពលភាពត្រឹមឆ្នាំ២០០៨ ប៉ុណ្ណោះ ។ ស្របគ្នានេះដែរ ការដាក់កូតាជាថ្មីទៅលើប្រទេសចិន បានផ្តល់ឱ្យប្រទេសកម្ពុជានូវរយៈពេល២ឆ្នាំកន្លះថែមទៀត ក្នុងការបន្តស្វែងរកឱកាសល្អបំផុត នៅក្នុងទីផ្សារសំលៀកបំពាក់ពិភពលោក ។

ដើម្បីឱ្យប្រទេសកម្ពុជាបោះជំហ៊ានទៅមុខទៀតនៅក្នុងទីផ្សារសហរដ្ឋអាមេរិក មន្ត្រីក្រសួងពាណិជ្ជកម្ម និង មន្ត្រីសមាគមផលិតកររោងចក្រកាត់ដេរកម្ពុជា បានធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិក ដើម្បីបញ្ចុះបញ្ចូលសភាអាមេរិកាំង សំរាប់ការអនុម័តច្បាប់អំពី ជំនួយអនុគ្រោះពន្ធសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។ សេចក្តីព្រាងច្បាប់ត្រូវបានគេបញ្ជូនទៅព្រឹទ្ធសភាអាមេរិកនៅខែមករា ឆ្នាំ ២០០៥ ហើយក្នុងរយៈពេល១ខែក្រោយទៀត កំណែថ្មីនៃសេចក្តីព្រាងច្បាប់នេះ ត្រូវបញ្ជូនបន្តទៅរដ្ឋសភាអាមេរិក ។ ប្រទេសកំពុងអភិវឌ្ឍន៍ចំនួន១៥ ដែលគេបានកំណត់ថានឹងបានទទួលបានផលប្រយោជន៍ពីច្បាប់នេះគឺ មានរាប់បញ្ចូលទាំងប្រទេសកម្ពុជា ព្រមទាំងប្រទេសដែលទទួល

---

[២២] *Cambodia Seizing Global Opportunity: Investment Climate Assessment & Reform Strategy*, (Phnom Penh: Prepared for the Royal Cambodian Government by the World Bank Group, August 2004)

[២៣] *The Cambodia Daily*, May 18, 2005

[២៤] Wheeler, "*Scrappy Garment Industry Making Gains in Post-Quota Environment*"

រងគ្រោះដោយរលកសមុទ្រស៊ូណាមិដូចជា ប្រទេសម៉ាលឌីវ និងសេរីលង្កា ។ ការអនុម័ច្បាប់នេះ អាចផ្តល់ឱ្យប្រទេសកម្ពុជា នូវការនាំចូលប្រភេទទំនិញមួយចំនួនទៅសហរដ្ឋអាមេរិកដោយពុំមានបង់ពន្ធ។ នាពេលបច្ចុប្បន្ននេះ ម្ចាស់រោងចក្រនៅប្រទេសកម្ពុជា បានបង់ពន្ធប្រហែល១៧%ទៅលើទំនិញនាំចូលទៅសហរដ្ឋអាមេរិក។ នៅខែកក្កដា ២០០៥ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាមេរិកកណ្តាល (CAFTA) ត្រូវបានអនុម័ត ដោយសភាអាមេរិកាំងរួចហើយ ដែលនេះជាឱកាសល្អសំរាប់ការត្រួសត្រាយផ្លូវឱ្យមានការពិភាក្សាទៅលើច្បាប់អនុគ្រោះពន្ធនេះអោយកាន់តែល្អិតល្អន់នៅពេលណាមួយ[២៥] ។

ដូច្នេះ ផ្ទុយពីការទស្សន៍ទាយទុកដែលថា ឧស្សាហកម្មកាត់ដេរនឹងដួលរលំភ្លាម១ ឬក៏មានធ្លាក់ចុះជាបណ្តើរ១ បែរជាគេមើលឃើញ លទ្ធភាពដំណើរការទៅតមុខនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជា នៅពាក់កណ្តាលឆ្នាំ ២០០៥ មានភាពប្រសើរ។ ទោះបីជាមានការការថយចុះទីផ្សារផលិតផលខ្លះ ក៏បរិមាណនាំចេញសរុប បានលើសពីកំរិតនាំចេញកាលពីឆ្នាំកន្លងទៅ ហើយការលក់ចេញក៏បានកើនឡើងជាង៥%ដែរ។ គេមើលឃើញថា ការប្រកួតប្រជែងកាន់តែខ្លាំងឡើង នៅលើទីផ្សារពិភពលោក បានផ្តល់ផលប្រយោជន៍ដល់អ្នកទិញជាងអ្នកផ្គត់ផ្គង់។ យោងទៅតាមតំរូវការជាទូទៅដែលត្រូវការទំនិញមានគុណភាពខ្ពស់ក្នុងតម្លៃទាបនោះ ការកែទំរង់នៃវិស័យឧស្សាហកម្មកាត់ដេរគឺជាមានសារៈសំខាន់ខ្លាំងណាស់។ ការកែទំរង់នេះ ទាមទារឱ្យមានការបង្កើនផលិតភាព និងកាត់បន្ថយចំណាយផ្នែកការិយាធិបតេយ្យ ហើយក្នុងពេលជាមួយគ្នានេះដែរ គួរគិតអំពីរក្សាឱ្យបាននូវស្តង់ដារការងារសមស្រប[២៦] ។ ក្នុងខណៈដែលមានការដាក់របាំងការពារជាណ្តោះអាសន្នទៅលើប្រទេសចិន និងអ្នកទិញអាចទិញពីប្រភពផ្គត់ផ្គង់ច្រើនកន្លែងនោះ ឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា នៅមានពេលវេលាដើម្បីធ្វើការកែទំរង់ក្នុងគោលបំណងមានលទ្ធភាពចូលរួមប្រកួតប្រជែងបន្តទៀត ទោះបីជាឧស្សាហកម្មនេះ មិនអាចក្លាយជាក្បាលម៉ាស៊ីនដ៏សំខាន់សំរាប់ការលូតលាស់នៅពេលខាងមុខក្តី។

---

[២៥] Elena Lesley, "*Tsunami-Triggered Trade Bill Stalls in US Senate*," *Phnom Penh Post*, April 22-May 5, 2005. សូមមើលផងដែរនៅក្នុង *The Cambodia Daily*, July 8, 2005 and August 27-28, 2005

[២៦] In 2005 the ILO continued to monitor labor standards in garment factories under its Better Factories Cambodia project ។ សូមមើល *Phnom Penh Post*, July 29-August 11, 2005

## បទពិសោធន៍របស់កម្មកររោងចក្រកាត់ដេរមកពីខេត្តព្រៃវែង

ឯកសារផ្នែកនេះចងក្រងនូវបទពិសោធន៍របស់កម្មកររោងចក្រ ដែលបានធ្វើចំណាកស្រុកមកពីខេត្តព្រៃវែង មករស់នៅ និងប្រកបការងារនៅទីក្រុងភ្នំពេញ។ ពត៌មានទាំងនេះ ត្រូវបានប្រមូលពីកម្មកររោងចក្រដែលមកពីខេត្តព្រៃវែង តាមរយៈការធ្វើអង្កេតជាមួយកម្មករចំនួន ១១៦នាក់ និង លទ្ធផលនៃការពិភាក្សាក្នុងក្រុមតូចៗ ។

### ប្រវត្តិទាក់ទងនឹងកម្មករ

ចំនួនកម្មកររោងចក្រមួយចំនួនធំដែលត្រូវបានសំភាសន៍គឺស្ត្រីមានវ័យក្មេង និងមិនទាន់រៀបការ ។ ពួកគេមកពីស្រុកចំនួន១១ ក្នុងខេត្តព្រៃវែង ហើយចំនួនកម្មករដែលច្រើនបំផុតមកពីស្រុកកញ្ច្រៀច កំពង់ត្របែក មេសាង និងស្រុកពារាំង ។ ក្នុងចំណោមកម្មករចំនួន ១១៦នាក់ដែលគេបានសំភាសន៍មាន ១០៩ (៩៤%) ជាស្ត្រី។ អាយុជាមធ្យមនៃកម្មការដែលត្រូវបានសំភាសន៍ទាំងនោះគឺ ២២.៥ ឆ្នាំ ។ អាយុរបស់គេភាគច្រើន (៦១នាក់ ឬ ៥៣%) ចាប់ ពី ២០-២៤ ឆ្នាំ ។ មានកម្មករពីរនាក់ដែលគេបានសំភាសន៍គឺមានអាយុក្រោម ១៨ ឆ្នាំ ហើយមានចំនួន៨នាក់ដែលមានអាយុ៣០ឆ្នាំ ឬចាស់ជាងនេះ ។ ចំពោះស្ថានភាពគ្រួសារវិញ ពួកគេភាគច្រើនបំផុតគឺនៅលីវ (៩៥នាក់ ឬ ៨៣%) នៃកម្មករចំនួន ១១៦នាក់ ដែលគេបានសំភាសន៍ ។ បើធ្វើការប្រៀបធៀបវិញ គេឃើញមានតែចំនួន ១៥នាក់ (១៣%) បានរៀបការរួច ហើយក្នុងចំណោមអ្នកដែលបានរៀបការនេះ មានតែ៤នាក់ប៉ុណ្ណោះដែលបានរស់នៅជាមួយប្តីរបស់គេនៅទីក្រុងភ្នំពេញ ។ ក្នុងចំណោមអ្នកដែលបានរៀបការរួច មាន៧នាក់មានកូន និងមានតែម្នាក់ទេដែលមានកូនម្នាក់រស់នៅទីក្រុងភ្នំពេញដែរ ។ ក្នុងចំណោមស្ត្រីមេម៉ាយ៥នាក់ដែលបានសំភាសន៍វិញ មាន៤នាក់ បានយកកូនៗរបស់ពួកគេ មករស់នៅក្នុងទីក្រុងភ្នំពេញផងដែរ ។

សំរាប់ការស្រាវជ្រាវនេះ[២៧] កម្មករដែលត្រូវបានសំភាសន៍ទាំង ១១៦នាក់ ត្រូវបានរាប់បញ្ចូលជាសមាជិកនៅក្នុងក្រុមគ្រួសារនៅក្នុងខេត្តព្រៃវែងដែរ ។ យោងតាមការបញ្ជាក់មកនេះ គេបានគណនាឃើញថា ទំហំគ្រួសារជាមធ្យមនៃកម្មករទាំង១១៦នាក់គឺ ៦.៤៦ ។ បើគិតជាមធ្យមនៃអ្នកដែលអាចជួយរកចំណូលសំរាប់គ្រួសារគឺ ៣.៥២ ។ រីឯ ចំនួនមធ្យមនៃអ្នកដែលបានចំណាកស្រុកក្នុងចំណោមអ្នកដែលមានលទ្ធភាពរកចំណូលសំរាប់គ្រួសារ

[២៧] ការស្រាវជ្រាវនេះ យកលំនាំតាម Kethie Friedman ដែលចាត់ទុកក្រុមគ្រួសារជា អង្គការភាពមួយដែលគ្រប់សមាជិកគ្រួសារមានកាតព្វកិច្ច ដាក់បញ្ចូលរួមគ្នានូវធនធាន/ចំណូលដែលរកបានពីគ្រប់ប្រភេទនៃការងារដែលបានធ្វើ ។ សូមមើលឯកសាររបស់ Kethie Friedman អំពី "គ្រួសារជាអង្គភាពមួយដែលដាក់ប្រាក់ចំណូលរួមគ្នា" ដែលបានបោះពុម្ពផ្សាយនៅក្នុង *Households and the World Economy*, Joan Smith, Immanuel Wallerstein, and Hans Dieter Evers, eds., Beverly Hills: Sage Publications, 1984, 37-55

គឺ ១.៩៧ ។ ប្រការគួរអោយកត់សំគាល់នោះគឺ ចំនួនមធ្យមនៃអ្នកដែលបានធ្វើជាកម្មករកាត់ដេរក្នុងគ្រួសារមាន រហូតដល់ទៅ ១.៥៥ ។ នេះជាការបង្ហាញឱ្យឃើញថា កម្មករដែលចំណាកស្រុក ជាពិសេស កម្មកររោងចក្រ កាត់ដេរ ជាកម្លាំងពលកម្មមួយចំណែកយ៉ាងធំសំរាប់រកចំណូលជួយទ្រទ្រង់ដល់ក្រុមគ្រួសារ ។ ដូចគ្នានេះដែរ ចំណុចខាងលើនេះ បានបង្ហាញថា មានក្រុមគ្រួសារជាច្រើនដែលមានសមាជិកគ្រួសារមកធ្វើការ តាមរោងចក្រ កាត់ដេរលើសពីម្នាក់ ។

ការទទួលបាននូវការអប់រំរបស់កម្មករចំនួន ១០៨នាក់ ដែលបានបញ្ចប់ការសិក្សាក្នុងកំរិតណាមួយនោះ ឃើញថា មានចំនួនច្រើន ។ នៅពេលដែលគេបានគណនារកមធ្យមភាគនៃកំរិតសិក្សា ឃើញថា ពួកគេបានបញ្ចប់ត្រឹមថ្នាក់ទី ៥ ដែរ ។ ប្រការគួរឱ្យចាប់អារម្មណ៍នោះគឺ កម្មករកាត់ដេរចំនួន ២៩ នាក់ (២៧%) បានបញ្ចប់កំរិតសិក្សាថ្នាក់ទី ៧ ឬខ្ពស់ជាងនេះ ។

## ប្រវត្តិនៃការធ្វើចំណាកស្រុក និងព្រឹត្តិការណ៍ផ្សេងៗ

អ្នកចំណាកស្រុកមកពីខេត្តព្រៃវែងដែលត្រូវបានសំភាសន៍ បានចាប់ផ្តើមធ្វើការងារតាមរោងចក្រនានា តាំងពីឆ្នាំ ១៩៩៥ ប៉ុន្តែនៅឆ្នាំ២000 ចំនួនអ្នកចំណាកស្រុកមកធ្វើការនៅរោងចក្របានកើនឡើងជាខ្លាំង ហើយក្រោយមក ក៏ថយទៅវិញក្នុងចំនួនតិចតួច (សូមមើលតារាងទី ៤) ។ យោងតាមស្ថិតិខាងលើនេះ គេក៏បានរកឃើញថា កម្មករចំនួន ៦១នាក់ (៥៣%) នៃចំនួនកម្មករដែលត្រូវបានសំភាសន៍ បានធ្វើការនៅតាមរោងចក្រកាត់ដេរលើស ពី ២ឆ្នាំ ។ ទន្ទឹមនេះដែរ ចំនួន៣៩នាក់ (៣៤%) ដែលទើបតែបានចំណាកស្រុកនោះបានធ្វើការ នៅតាមរោងចក្រ កាត់ដេរក្នុងរយៈពេលមួយឆ្នាំ ឬតិចជាងនេះ ។ ពួកគេភាគច្រើន (៦៦នាក់ ឬ៥៧%) បានធ្វើការនៅក្នុងរោងចក្រ តែមួយកន្លែងប៉ុណ្ណោះ ចំណែក៣៣នាក់ (២៨%) បានធ្វើការនៅក្នុងរោងចក្រចំនួនពីរកន្លែង ហើយ១៧នាក់ (១៥%) បានធ្វើការនៅក្នុងរោងចក្រចំនួនបីកន្លែង ឬច្រើនជាងនេះ ។ នៅអំឡុងពេលនៃការស្រាវជ្រាវនេះ កម្មករទាំង ១១៦នាក់ បានធ្វើការនៅក្នុងរោងចក្រច្រើនជាង៤0កន្លែងដោយឡែកពីគ្នា ហើយតាមធម្មតា ពួកគេ ធ្វើការនៅតាមរោងចក្រដែលជិតកន្លែងស្នាក់នៅរបស់ពួកគេ ។

| តារាងទី ៤: ឆ្នាំដែលកម្មកររោងចក្រមកពីខេត្តព្រៃវែង បានចាប់ផ្តើមធ្វើការពីដំបូងតាមរោងចក្រភ្នំពេញ ខែ កញ្ញា-តុលា ឆ្នាំ ២០០៤ | | |
|---|---|---|
| ឆ្នាំ | ចំនួន (នាក់) | ភាគរយ |
| 1997 ឬ ពីមុននេះ | 3 | 2.6 |
| 1998 | 6 | 5.2 |
| 1999 | 10 | 8.6 |
| 2000 | 24 | 20.7 |
| 2001 | 21 | 18.1 |
| 2002 | 16 | 13.8 |
| 2003 | 19 | 16.4 |
| 2004 | 17 | 14.7 |
| **ចំនួនកម្មករផ្តល់ចំលើយ= 116** | | |

មូលហេតុដែលនាំពួកគេ និងសមាជិកផ្សេងទៀតនៅក្នុងគ្រួសាររបស់គេ បានចំណាកស្រុក មកនៅទីក្រុងភ្នំពេញដើម្បីរកការងារធ្វើតាមរោងចក្រកាត់ដេរ មានកត្តាពីរសំខាន់គឺ កត្តាជំរុញ និងកត្តាទាក់ទាញ (សូមមើលតារាងទី ៥) ។ ចំពោះកត្តាជំរុញគឺ ការលើកឡើងយ៉ាងច្រើនលើសលប់អំពី ទិន្នផលស្រូវមិនគ្រប់គ្រាន់ ជាការបង្ហាញអោយឃើញថា មានវិបត្តិខាងវិស័យកសិកម្មនៅក្នុងខេត្តព្រៃវែងដែលបណ្តាលមកពីបញ្ហា គ្រោះទឹកជំនន់ និងរាំងស្ងួតផ្ទួនៗគ្នា ក្នុងរយ:ពេលបួនឆ្នាំកន្លងមកនេះ ។ រីឯភាពគ្មានដីធ្លី ក៏ជាបញ្ហាមួយដែលកម្មករខ្លះកំពុងតែជួបប្រទះ។ ក្នុងពេលជាមួយគ្នានោះដែរ ឱកាសការងារស៊ីឈ្នួលនៅជិតៗភូមិនៅមានកំរិត ព្រមទាំងខ្វះទុនសំរាប់ប្រកបមុខរបររកចំណូល បានបង្ហាញអោយឃើញច្បាស់ពីភាពមិនរីកចំរើននៃឧស្សាហកម្មផ្សេងៗនៅតំបន់ជនបទនោះទេ។ កត្តាទាំងនេះដោយរួមបញ្ចូលទាំង បញ្ហាបំណុលផ្សេងៗដោយសារចំណាយលើថ្លៃសុខភាព និងចំណាយលើការធ្វើស្រែចំការគឺជាកត្តាជំរុញពិតប្រាកដដែលធ្វើអោយពួកគេស្វែងរកការងារធ្វើនៅក្រុងភ្នំពេញ។ ចំពោះកត្តាទាក់ទាញវិញគឺថា ឱកាសការងាររោងចក្រនៅភ្នំពេញ ជាពិសេសសំរាប់ស្ត្រីវ័យក្មេងនៅលីវ ជាជំរើសគួរអោយចាប់អារម្មណ៍មួយ សំរាប់ការស្វែងរកការងារដែលផ្តល់នូវកំរៃសំរាប់ពួកគេ ។

| **តារាងទី៥:  មូលហេតុដែលនាំឱ្យពួកគេចាកចេញពីខេត្តព្រៃវែងមកធ្វើការនៅរោងចក្រ ភ្នំពេញ  ខែកញ្ញា-តុលា  ឆ្នាំ  ២០០៤** | | |
|---|---|---|
| មូលហេតុ | ចំនួន | ភាគរយ |
| ទិន្នផលស្រូវមិនគ្រប់គ្រាន់ | 100 | 86.2 |
| មានការងារធ្វើនៅតាមរោងចក្រកាត់ដេរ | 91 | 78.4 |
| ខ្វះខាតដើមទុនសំរាប់ចាប់ផ្តើមប្រកបរបររកស៊ី | 84 | 72.4 |
| ឱកាសសំរាប់ស៊ីឈ្នួលនៅតាមភូមិ មានកំរិត | 76 | 65.5 |
| ជំពាក់បំណុលដោយសារថ្លៃសុខភាព | 44 | 37.9 |
| ជំពាក់បំណុលដោយសារការធ្វើស្រែ | 33 | 28.4 |
| គ្មានដីធ្លី ( គ្រួសារដែលគ្មានដីធ្វើស្រែ) | 10 | 8.6 |
| ជំពាក់បំណុលដោយសារល្បែងស៊ីសង | 2 | 1.7 |
| ផ្សេងៗ | 21 | 18.1 |
| **ចំនួនកម្មករផ្តល់ចំលើយ= 116** | | |

កម្មកររោងចក្រមកពីខេត្តព្រៃវែង បានទទួលការងារធ្វើនៅតាមរោងចក្រកាត់ដេរនានានៅទីក្រុងភ្នំពេញ តាមរយៈមធ្យោបាយជាច្រើន ។ ស្ទើរតែពាក់កណ្តាល ( ៥៤នាក់ ឬ ៤៧%) នៃកម្មករដែលត្រូវបានសំភាសន៍ចំនួន១១៦នាក់ បាននិយាយថា ពួកគេបានការងារធ្វើដោយសារមានបងប្អូនសាច់ញាតិជួយ ។ ក្នុងចំនួនច្រើនដែរគឺ ( ៤០ ឬ ៣៤%) បានរៀបរាប់ដែរថា គេរកបានការងារធ្វើដោយខ្លួនគេផ្ទាល់ ។ មានមួយចំនួនតូច (១៩ ឬ ១៦%) ដែលទទួលបានការងារធ្វើ ដោយសារមិត្តភក្តិជួយ ។

ផ្ទុយទៅនឹងទស្សនៈពេញនិយមមួយដែលថា ការទទួលបានការងារដោយមិនបាច់ចំណាយលុយនោះ គេឃើញថា មានតែកម្មករ៣២នាក់ (២៨%) នៃកម្មករ១១៦នាក់ដែលត្រូវបានសំភាសន៍ បានសូកលុយគេដើម្បីឱ្យមានការងារធ្វើនៅក្នុងរោងចក្រ។ ចំពោះចំនួនដែលបានសូកគេនោះ ជាមធ្យមគឺមានកំរិតខ្ពស់រហូតដល់ទៅ ៤០.១៦ ដុល្លារ។ តាមពិត ការសូកលុយនេះត្រូវបានធ្វើឡើងក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់រោងចក្រទាំងស្រុង ។ ក្នុងចំណោមកម្មករទាំង៣២នាក់ដែលបានសូកលុយនោះ មាន២៥នាក់បានខ្ចីលុយគេ យកមកសូកគេដើម្បីបានការងារធ្វើ។ ក្នុងចំណោមអ្នកដែលបានខ្ចីលុយគេ មាន១៨នាក់ បានសងបំណុលរួចអស់ រីឯ៧នាក់ទៀត សងបានខ្លះ។ មានតែកម្មករចំនួន៣នាក់ ក្នុងចំណោម៣២នាក់ដែលសូកលុយគេ បានលក់ទ្រព្យសម្បត្តិដូចជា គ្រឿងអលង្ការ ដើម្បីយកលុយមកសូកគេ ដើម្បីទទួលបានការងារធ្វើ។

**ចំណូល ចំណាយ និងប្រាក់ផ្ញើឧបត្ថម្ភដល់ក្រុមគ្រួសារ**

កម្មកររោងចក្រត្រូវបានគេបង់ប្រាក់ឈ្នួលឱ្យទៅតាមម៉ោងដែលគេបានធ្វើ ។ តាមធម្មតា កម្មករដែលត្រូវបានសំភាសន៍១១៦នាក់ បានធ្វើការ៨ម៉ោងក្នុងមួយថ្ងៃ (៩៤%) និង ៦ថ្ងៃក្នុងមួយសប្តាហ៍ (៩៦%)។ ជាធម្មតានៅពេលធ្វើការលើសម៉ោង ភាគច្រើននៃកម្មករដែលបានផ្តល់ចម្លើយទាំងនោះ បានធ្វើការ១០ម៉ោងក្នុងមួយថ្ងៃ ។ នៅតែមានចំនួនកម្មករ១/៤ទៀតដែលបានធ្វើការលើសម៉ោង គឺមានចំនួនលើសពី១០ម៉ោងក្នុងមួយថ្ងៃ ។ សូមបញ្ជាក់ថា កម្មករដែលបានផ្តល់ចម្លើយភាគច្រើននៃ១១៦នាក់ (៩០%) ត្រូវបានគេចាត់ទុកថា ជាកម្មករពេញសិទ្ធិ ចំណែកឯមួយភាគតូច (១០%) ត្រូវបានគេចាត់ទុកថា ជាកម្មករមិនពេញម៉ោង ឬកម្មករអណ្តែត ។

ដោយរួមបញ្ចូលទាំងលុយលើសម៉ោងផង ប្រាក់ខែជាមធ្យមរបស់កម្មករទាំង ១១៦នាក់ដែលត្រូវបានសំភាសន៍ គឺមានចំនួន ៦២.១៤ ដុល្លារ ។ នៅពេលជាមួយគ្នានេះ គេឃើញមានប្រាក់ខែកម្មករផ្សេងៗពីគ្នាដែលគួរឱ្យកត់សំគាល់ ដោយ១/៥នៃកម្មករ រកប្រាក់កំរៃបានក្រោម ៥០ ដុល្លារក្នុងមួយខែ ហើយស្ទើរតែ១/៥ទៀត រកបានលើសពី៧០ដុល្លារក្នុងមួយខែ (សូមមើលតារាងទី ៦)។ គួរកត់សំគាល់ថា ក្នុងចំណោមកម្មករដែលបានសំភាសន៍ទាំងអស់មាន៧នាក់ជាបុរស ហើយប្រាក់ខែជាមធ្យមរបស់គេ ៧១.២៨ ដុល្លារដែលចំនួននេះមានកំរិតខ្ពស់ជាងមធ្យមភាគទូទៅ ។ សំខាន់ជាងនេះទៅទៀតនោះគឺ ប្រាក់កំរៃដែលកម្មកររកបានប្រចាំខែ បានធ្លាក់ចុះយ៉ាងខ្លាំង បើសិនជាដកប្រាក់លើសម៉ោងចេញពីប្រាក់ខែធម្មតារបស់ពួកគេ ។ បើមិនគិតប្រាក់លើសម៉ោង ប្រាក់ចំណូលជាមធ្យមប្រចាំខែរបស់កម្មករ៩៤នាក់ដែលបានបញ្ជាក់ប្រាប់គឺ ៤៤.៧៣ ដុល្លារ ឬ ប្រហែល៧២% នៃប្រាក់កំរៃរួមជាមួយនឹងប្រាក់លើសម៉ោងផង ។ ដូច្នេះ ដើម្បីរក្សាប្រាក់ខែក្នុងកំរិតខ្ពស់របស់គេ កម្មករត្រូវធ្វើការ ១០ម៉ោងក្នុងមួយថ្ងៃ ឬច្រើនជាងនេះ ក្នុងរយៈពេល ៦ថ្ងៃក្នុងមួយសប្តាហ៍ ។

| **តារាងទី ៦: ប្រាក់កំរៃប្រចាំខែរួមទាំងប្រាក់លើសម៉ោង របស់កម្មកររោងចក្រ មកពីខេត្តព្រៃវែង ភ្នំពេញ ខែ កញ្ញា-តុលា ឆ្នាំ ២០០៤** | | |
|---|---|---|
| ប្រាក់កំរៃប្រចាំខែ | ចំនួន | ភាគរយ |
| តិចជាង ៥០ ដុល្លារ | 25 | 21.6 |
| ៥០ -៦០ ដុល្លារ | 42 | 36.2 |
| ៦០.១-៧០ ដុល្លារ | 27 | 23.3 |
| លើសពី ៧០ ដុល្លារ | 22 | 19.0 |
| សរុប | **116** | **100.1** |

ចំពោះពត៌មានអំពីការចំណាយប្រចាំខែជាមធ្យមដែលបានទទួលបានពីការសំភាសន៏ជាមួយកម្មករម្នាក់ៗ ត្រូវបានលាតត្រដាងនៅក្នុងតារាងទី ៧ ។ តួលេខនេះ បានបង្ហាញនូវចំនួនជាមធ្យម ដែលគេបានគណនាដោយផ្អែកលើចំនួនកម្មករសរុប១១៦នាក់ ទោះបីជាកម្មករខ្លះ មិនបានរៀបរាប់នូវមុខចំណាយអោយបានពេញលេញក៏ដោយ ។ នៅពេលដែលគេបានប្រៀបធៀបទៅនឹងប្រាក់ចំណូលប្រចាំខែជាមធ្យម ការចំណាយប្រចាំខែជាមធ្យម ឃើញថាឡើងខ្ពស់គួរឱ្យកត់សំគាល់ ដោយគេមិនទាន់បានគិតបញ្ចូលនូវប្រាក់ផ្ញើឧបត្ថម្ភគ្រួសារនៅខេត្តព្រៃវែង។ ជាធម្មតានៅក្នុងការធ្វើអង្កេត អ្នកផ្តល់ចំលើយតែងតែបង្ហាញនូវតួលេខនៃការចំណាយខ្ពស់ ហេតុនេះហើយគេគួរធ្វើការកត់សំគាល់ជាមុនចំពោះបញ្ហានេះថា នឹងមានភាពមិនប្រក្រតីជាមិនខាន ។

| **តារាងទី ៧: ប្រាក់ចំណាយប្រចាំខែជាមធ្យមនៃកម្មកររោងចក្រមកពីខេត្តព្រៃវែង គិតជាដុល្លារ ភ្នំពេញ ខែ កញ្ញា-តុលា ឆ្នាំ ២០០៤** | |
|---|---|
| អាហារ | 18.75 |
| កន្លែងស្នាក់អាស្រ័យ (រួមទាំងថ្លៃទឹក ភ្លើង) | 8.20 |
| សងប្រាក់កំចី | 7.70 |
| ការធ្វើដំណើរ | 5.52 |
| សម្លៀកបំពាក់ | 5.26 |
| វត្ថុប្រើប្រាស់ផ្ទាល់ខ្លួន | 4.07 |
| សុខភាព | 3.89 |
| ការកំសាន្ត | 3.65 |
| ការអប់រំ | 2.71 |
| សរុប | 59.75 |
| **ចំនួនកម្មករផ្តល់ចំលើយសរុប= 116** | |

អ្វីដែលគេឃើញលេចធ្លោដែរនោះគឺ មធ្យមភាគនៃការចំណាយសំរាប់យកទៅសងបំណុលគេ មានកំរិតខ្ពស់ ។ ប៉ុន្តែបើពិនិត្យមើលឱ្យបានស៊ីជំរៅ គេមើលឃើញថា មានតែ៤៣នាក់ (៣៧%) នៃកម្មករ១១៦នាក់ កំពុងយកលុយរបស់ខ្លួនទៅសងបំណុល ហើយមានតែ២៤នាក់ (២១%) នៃ កម្មករ១១៦នាក់សងប្រាក់ក្នុងចំនួនជាង ៧ដុល្លារ

មួយខែ។ ទោះបីមានកម្មករតិចត្រឹមតែ ១/៥ បានសងប្រាក់កម្ចីក្តី តែទឹកប្រាក់ដែលបានសងមានចំនួនច្រើន ទើបធ្វើអោយគេមើលឃើញថា ចំនួនសងប្រាក់គិតជាមធ្យមហាក់ដូចជាមានកំរិតខ្ពស់ ។ ស្រដៀងគ្នានេះដែរ មានតែ៤៨នាក់ (២១%) នៃអ្នកផ្តល់ចម្លើយចំនួន ១១៦ នាក់ បានចំណាយលុយលើការធ្វើដំណើរ ហើយមានតែ ២៥នាក់ (២១%) ដែលបានចំណាយលុយលើសពី២.៥០ដុល្លារ ក្នុងមួយខែ សំរាប់ការធ្វើដំណើរនោះ ។ ថ្វីត្បិតតែមានការលំបាកក្នុងការទទួលបានទូវតួលេខនៃការចំណាយពិតប្រាកដក្តី តែលំនាំទូទៅនៃការចំណាយបានបង្ហាញអោយឃើញច្បាស់ ពោលគឺមិនសូវជាមានគម្លាតពីគ្នាណាស់ណានោះទេ ។ កម្មកររោងចក្រមកពីខេត្តព្រៃវែង បានចំណាយប្រាក់មួយភាគធំនៃកំរៃដែលទទួលបានប្រចាំខែ សំរាប់តែគាំទ្រដល់សេចក្តីត្រូវការជាមូលដ្ឋានរបស់គេនៅភ្នំពេញប៉ុណ្ណោះដូចជា ម្ហូបអាហារ និងស្នាក់នៅ។

កម្មករស្ទើរតែទាំងអស់ (១១២ ឬ ៩៧%) នៃកម្មករទាំង១១៦នាក់ដែលគេបានសំភាសន៍ បានផ្ញើលុយទៅអោយក្រុមគ្រួសាររបស់គេនៅខេត្តព្រៃវែង ។ ចំនួនលុយជាមធ្យមដែលគេបានផ្ញើជូនគ្រួសារគឺ ១៦.៨២ដុល្លារ ឬប្រហែល ២៧%នៃប្រាក់ចំណូលជាមធ្យមប្រចាំខែរួមទាំងប្រាក់លើសម៉ោងផង ។ ប្រការគួរឱ្យចាប់អារម្មណ៍នោះគឺកម្មករដែល ត្រូវបានសំភាសន៍ ៣៥នាក់ (៣១%) បានខ្ចីប្រាក់ពីគេខ្លះរួមផ្សំដើម្បីផ្ញើទៅស្រុក។ ចំនួនប្រាក់ដែលបានផ្ញើទៅផ្ទះ ក្នុងកំរិតហាក់ដូចមានចំនួនខ្ពស់ ដោយរួមទាំងប្រាក់កម្ចីដែរនោះ បានបង្ហាញអោយឃើញនូវភាពចាំបាច់នៃការរួមចំណែករបស់កម្មករក្នុងការជួយគាំទ្រដល់ក្រុមគ្រួសាររបស់គេនៅខេត្តព្រៃវែង ។ កម្មករបានបញ្ជាក់ថាពួកគេបានប្រើមធ្យោបាយជាច្រើន ដើម្បីផ្ញើលុយទៅផ្ទះ ។ មធ្យោបាយនៃការផ្ញើរួមមាន ការផ្ញើតាមបងប្អូន (៦៧%) ទៅស្រុកដោយខ្លួនឯង (៥៧%) បងប្អូនពីស្រុកមកទទួលយក (៤៤%) និងតាមមិត្តភក្តិ (២២%) ។

នៅពេលដែលគេធ្វើការផ្ទះបញ្ជាំងបន្ថែមទៀត ទើបគេមើលឃើញកាន់តែច្បាស់អំពី ទំនាក់ទំនងរវាងលទ្ធភាពនៃការផ្ញើប្រាក់ក្នុងចំនួនច្រើន និងប្រាក់កំរៃប្រចាំខែដែលពួកគេទទួលបាន។ បើមិនបានទទួលចំណូលពីការធ្វើការលើសម៉ោងទេនោះ កម្មករមិនអាចបំពេញតម្រូវការចាំបាច់របស់ពួកគេនៅភ្នំពេញ ព្រមទាំងបានផ្ញើលុយទៅផ្ទះនៅឯខេត្តព្រៃវែងក្នុងចំនួនក្រាស់ក្រែលនោះបានទេ ។ ដូច្នេះ ដោយសារតែពួកគេបានធ្វើការលើសម៉ោង ដែលជាធម្មតាពួកគេត្រូវបំពេញការងារពី ១០ ម៉ោង ឬច្រើនជាងនេះ ហើយមានរយៈពេល ៦ថ្ងៃក្នុងមួយសប្តាហ៍ ទើបពួកគេអាចបន្តផ្ញើលុយទៅផ្ទះបានជាបន្តបន្ទាប់នោះ។

ជាទូទៅប្រាក់ផ្ញើឧបត្ថម្ភដែលក្រុមគ្រួសារនៅខេត្តព្រៃវែងបានទទួល ត្រូវបានយកទៅប្រើសំរាប់ការចំណាយប្រចាំថ្ងៃ ដើម្បីបំពេញការខ្វះខាតក្នុងជីវភាពគ្រួសារ ជាជាងយកទៅប្រកបមុខរបរជាក់លាក់ណាមួយដើម្បីរកប្រាក់ចំណូល (សូមមើលតារាងទី៨) ។ ទោះបីជាពតិមានលំអិតទាក់ទងទៅនឹងបញ្ហាស្បៀងក្តី តែការទិញស្បៀងអាហារត្រូវបានពួកគេលើកមកនិយាយជាញឹកញាប់។ បើតាមចម្លើយដែលបានលើកឡើងជាច្រើនដែរនោះគឺ ការចំណាយ

លើថ្លៃសុខភាព បំណុល និងការធ្វើស្រែចំការ។ ប្រាក់ដែលបានផ្ញើនេះ ក៏បានប្រើប្រាស់ផងដែរសំរាប់បែងចែកទៅដល់ការរៀនសូត្ររបស់សមាជិកគ្រួសារ បន្ទាប់មកក៏មានការ បែងចែកសំរាប់យកទៅចិញ្ចឹមសត្វបែបយថាផល និងការទិញទ្រព្យសម្បត្តិដូចជា ផ្ទះសម្បែង គ្រឿងយន្តសំរាប់ ធ្វើស្រែ កម្លាំងអូសទាញ ដីធ្លី និងម៉ូតូ ។ ចំពោះការយកលុយដែលបានផ្ញើសំរាប់ធ្វើជំនួយខ្នាតតូចវិញ កម្រនឹងបានឮអ្នកណាម្នាក់បាននិយាយណាស់ ។

| **តារាងទី ៨: ការប្រើប្រាស់លុយរបស់ក្រុមគ្រួសារនៅខេត្តព្រៃវែង ចំពោះលុយដែលកម្មកររោងចក្របានផ្ញើទៅភ្នំពេញ ខែ កញ្ញា-តុលា ឆ្នាំ ២០០៤** | | |
|---|---|---|
| ប្រភេទនៃចំណាយ | ចំនួន | ភាគរយ |
| ចំណាយលើសុខភាព | 99 | 88.4 |
| ចំណាយសំរាប់ការធ្វើស្រែចំការ | 87 | 77.7 |
| សងបំណុល | 76 | 67.9 |
| ចំណាយសំរាប់ការរៀនសូត្ររបស់សមាជិកគ្រួសារ | 68 | 60.7 |
| ចំណាយសំរាប់ការចិញ្ចឹមសត្វ | 46 | 41.1 |
| យកទៅទិញទ្រព្យសម្បត្តិ | 37 | 33.0 |
| បានចាប់ផ្តើមធ្វើជំនួយខ្នាតតូច | 15 | 13.4 |
| **ចំនួនកម្មករផ្តល់ចំលើយសរុប= 112** | | |

## ស្ថានភាពរស់នៅរបស់កម្មករ

កម្មករជាអ្នកផ្តល់ចម្លើយជាច្រើនដែលគេបានសំភាសន៍នោះ បានរស់នៅក្នុងកន្លែងប្រមូលផ្តុំជាច្រើនកន្លែង ដែលបានរៀបចំឡើងសំរាប់កម្មកររោងចក្រកាត់ដេរស្នាក់នៅ ។ ទីស្នាក់អាស្រ័យ ជាធម្មតា ស្ថិតនៅជិតរោងចក្រដែលអាចដើរដល់ ហើយទីកន្លែងស្នាក់នៅនេះ ត្រូវបានសង់ពីឈើដែលមានក្រាលបេតុង ឬឥដ្ឋការ៉ូដោយខ័ណ្ឌជាបន្ទប់ៗជាជួរ។ ទីស្នាក់អាស្រ័យនោះ ត្រូវបានខ័ណ្ឌជាបន្ទប់ៗ ដោយក្នុងមួយបន្ទប់ មានកម្មករពីបីទៅបួននាក់រស់នៅជាមួយគ្នា ។ ចំពោះបន្ទប់ទឹកត្រូវបានប្រើប្រាស់រួមគ្នា ។ នៅតាមបន្ទប់ទាំងនោះមានភ្លើងអគ្គិសនី និងអាងទឹកធំធ្វើពីស៊ីម៉ង់ ស្ថិតនៅខាងក្រៅជិតទីជម្រកទាំងនេះ ។

ក្នុងចំណោមកម្មករទាំង១១៦នាក់នោះ មាន៥២នាក់ (៤៥%)បានបញ្ជាក់ថា ទីស្នាក់អាស្រ័យរបស់គេសមរម្យ ហើយមាន៥១នាក់ (៤៤%) បានចាត់ទុកថា មិនសូវសមរម្យ និង១៣នាក់ទៀត (១១%) បានយល់ថា មិនសមរម្យទេ ។ កម្មករមានការត្អូញត្អែរថា បន្ទប់ទឹកតូច ទីកន្លែងដេក និងចំអិនអាហារចង្អៀត ទឹកមិនសូវមានអនាម័យ និងមិនមានភ្លើង និងទឹកគ្រប់គ្រាន់សំរាប់ប្រើប្រាស់ ។ អ្នកផ្តល់ចម្លើយភាគច្រើន ៦១នាក់ (៥៣%) បាននិយាយថា ស្ថានភាពសន្តិសុខ និងសុវត្ថិភាពនៅក្នុងទីស្នាក់អាស្រ័យរបស់ពួកគេ មានសុវត្ថិភាពគ្រប់គ្រាន់ ចំណែក៣១នាក់ (២៧%) បានចាត់ទុកថាមិនសូវមានសុវត្ថិភាព និង ២៤នាក់ផ្សេងទៀត បានលើកឡើងថា មិនមាន សុវត្ថិភាពគ្រប់គ្រាន់ទេ ។

## ស្ថានភាពការងាររបស់កម្មករ

កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក ត្រូវបានភ្ជាប់ទៅនឹងលក្ខខ័ណ្ឌនៃការអនុវត្តន៏តាមគោលការណ៏ការងារ ។ នៅក្នុងការស្រាវជ្រាវទៅលើកម្មករខេត្តព្រៃវែងចំនួន ១១៦នាក់ មាន ៣៥នាក់ (៣០%) មានអារម្មណ៏ថា ស្ថានភាពការងាររបស់គេ ល្អគ្រប់គ្រាន់ ។ ដោយឡែក កម្មករដែលត្រូវបានសំភាសន៏ជាងពាក់កណ្តាល (៥៩នាក់ ឬ ៥១%) បានរៀបរាប់ថា ស្ថានភាពការងាររបស់គេមិនសូវល្អគ្រប់គ្រាន់ទេ និងមានមួយភាគតូច (១០នាក់ ឬ ៩%) បានរៀបរាប់ថា មិនល្អគ្រប់គ្រាន់ទេ ។ ក្រៅពីនេះ ក៏នៅមានមួយភាគតូចដែរ (១២នាក់ ឬ ១០%) មានការលំបាកក្នុងការបញ្ចេញយោបល់ ។ បញ្ហាជាចំបងមួយចំនួនដែលបានរៀបរាប់ ដោយកម្មករ ១០៨នាក់ មានការទាក់ទងទៅនឹងបញ្ហាសុខភាព និងការរំលោភសិទ្ធិ និងផលប្រយោជន៏ (សូមមើលតារាងទី៩) ។ ការពិភាក្សាក្នុងក្រុមតូចបានពន្យល់ថា ពួកគេមានការស៊ូទ្រាំនឹងការលំបាកច្រើនក្នុងពេលដែលកំពុងបំពេញការងាររបស់គេដូចជា "នៅពេលដែលយើងអ៊ុតសំលៀកបំពាក់ យើងត្រូវឈរយៈពេលច្រើនម៉ោង ហើយនឹងកំដៅដែលភាយចេញពីគ្រឿងម៉ាស៊ីននៅក្នុងរោងចក្រធ្វើឱ្យយើងពិបាកដកដង្ហើម ។ នៅពេលដែលយើងជ្រលក់ពណ៌សំលៀកបំពាក់ យើងត្រូវទទួលរងនូវក្លិនពុលដែលបញ្ចេញដោយជាតិគីមី ។ នៅពេលដែលយើងដេរខោអាវរយៈពេលយូរម៉ោង យើងមានការអស់កម្លាំង និងធ្វើអោយដៃរបស់យើងបានមុតនឹងម្ជុលដេរ ។

**តារាងទី ៩: បញ្ហាដែលកម្មកររោងចក្រមកពីខេត្តព្រៃវែង បានជួបប្រទះក្នុងពេលធ្វើការ ក្នុងការបំពេញការងារបច្ចុប្បន្ន ភ្នំពេញ ខែ កញ្ញា-តុលា ឆ្នាំ ២០០៤**

| ផលវិបាក | ចំនួន | ភាគរយ |
|---|---|---|
| សុខភាពចុះខ្សោយ | 82 | 75.9 |
| ក្លិនជាតិគីមី | 80 | 74.1 |
| គ្រោះថ្នាក់ក្នុងពេលបំពេញការងារ | 56 | 51.9 |
| កង្វះខាតខ្យល់ចេញចូល | 48 | 44.4 |
| សេវាសុខភាពមិនគ្រប់គ្រាន់ | 48 | 44.4 |
| ការរំលោភសិទ្ធិកម្មករ | 48 | 44.4 |
| បង្ខំឱ្យធ្វើការលើសម៉ោង | 38 | 35.2 |
| ធ្វើការយូរម៉ោង | 37 | 34.3 |
| ត្រូវឈររយៈពេលយូរ | 34 | 31.5 |
| មិនបានទទួលប្រាក់កំរៃពេញលេញ | 34 | 31.5 |
| ទីកន្លែងចង្អៀត | 26 | 24.1 |
| ថ្លៃឈប់សំរាកមិនទៀងទាត់ | 22 | 20.4 |
| ខ្វះពន្លឺ | 22 | 20.4 |
| ការបៀតបៀនកេរ្តិ៍ខ្មាស់ | 8 | 7.4 |
| ផ្សេងៗ | 11 | 10.2 |
| **ចំនួនកម្មករផ្តល់ចំលើយសរុប= 108** | | |

ទោះបីមានកម្មករខ្លះបានរកមធ្យោបាយមួយឬច្រើន ដើម្បីដោះស្រាយបញ្ហារបស់គេក្តី អ្នកខ្លះទៀតមិនបានរកដំណោះស្រាយអ្វីទេ ។ ផ្អែកទៅលើចម្លើយរបស់កម្មករ ៩៧នាក់ មាន៤០នាក់បានរាយការណ៍ពីបញ្ហារបស់គេជូនដល់តំណាងសហជីព ហើយ៣៧នាក់បានត្អូញត្អែប្រាប់កម្មករផ្សេងៗទៀត ៣៣នាក់បានរាយការណ៍ពីបញ្ហារបស់គេជូនទៅអ្នកគ្រប់គ្រង ហើយ៥នាក់ផ្សេងទៀតបានរាយការណ៏ទៅអង្គការមិនមែនរដ្ឋាភិបាលមួយ ។ ផ្ទុយ

ទៅវិញ អ្នកផ្តល់ចម្លើយ៣០នាក់មិនមានវិធានការណ៍អ្វីទេ។ ក្នុងចំណោមកម្មករ៨៨នាក់ដែលបានរិះរកមធ្យោបាយដោះស្រាយទៅលើបញ្ហាការងាររបស់គេ មានតែ ៤០នាក់ប៉ុណ្ណោះបាននិយាយថា ពួកគេបានទទួលជោគជ័យ ។

ភាគច្រើននៃកម្មករបានរាយការណ៍ថា ពួកគេយល់ដឹងពីច្បាប់ការងារដែលទាក់ទងទៅនឹងថ្ងៃឈប់សំរាក ការឈប់សំរាកពេលមានជម្ងឺ ឈប់លំហែមាតុភាព ឈប់សំរាកផ្ទាល់ខ្លួន និងការឈប់សំរាកប្រចាំឆ្នាំ ។ ក្នុងចំណោមអ្នកផ្តល់ចម្លើយ១០៥នាក់ដែលបានបញ្ចេញយោបល់អំពីថា តើរោងចក្របានអនុវត្តន៏តាមមាត្រាទាំងនេះឬយ៉ាងណានោះ មាន២១នាក់បាននិយាយថា និយោជករបស់គេបានអនុវត្តន៏ច្បាប់ពេញលេញតាមមាត្រាទាំងនេះ ហើយមាន៧៥នាក់បាននិយាយថា និយោជករបស់គេបានអនុវត្តន៏បានខ្លះ រីឯ៩នាក់ទៀតបានឆ្លើយថា មិនដឹងអ្វីទេ ។

## ការចូលរួមនៅក្នុងសកម្មភាពសហជីព និង សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល

ស្របទៅតាមការរីកចំរើននៃឧស្សាហកម្មរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា គេឃើញមានការលេចចេញជារូបរាងឡើងនូវសហជីពកម្មករក្នុងវិស័យនេះ[២៨] ។ សកម្មភាពនៃសហជីពកម្មករទាំងនេះ ពុំសូវជាមានការពាក់ព័ន្ធញឹកញាប់ទៅនឹងកូដកម្ម និងការតវ៉ាផ្សេងៗរទ តែមានពេលខ្លះកម្មករបានចេញធ្វើបាតុកម្មតាមដងវិថីដែរ ។ តាមការបញ្ជាក់ប្រាប់ កម្មករចំនួន ៥០នាក់ (៤៣%) ក្នុងចំណោមកម្មករចំនួន១១៦នាក់ ដែលគេបានសំភាសន៏គឺជាសមាជិករបស់សហជីព។ ក្នុងចំណោមសមាជិកសហជីពទាំង៥០នាក់ មាន១៤នាក់បានយល់ឃើញថា សហជីពធ្វើការមានប្រសិទ្ធិភាព និងមាន១៩នាក់ទៀតបានអះអាងថា សហជីពមិនសូវមានប្រសិទ្ធិភាព ហើយមាន១០នាក់បានចាត់ទុកថា គ្មានប្រសិទ្ធិភាព ហើយ៧នាក់ផ្សេងទៀតមិនអាចពន្យល់បាន ។ កម្មការនី អាយុ២២ឆ្នាំ មកពីខេត្តព្រៃវែងបានរៀបរាប់ក្នុងភាពមន្ទិលក្នុងចិត្ត អំពីការចូលរួមនៅក្នុងសហជីពរបស់នាង ។" *ខ្ញុំជាសមាជិកសហជីពកម្មករ ហើយថ្លៃសមាជិកភាពរាល់ខែត្រូវបានគេកាត់ជាស្វ័យប្រវត្តិពីប្រាក់ខែរបស់ខ្ញុំ ។ ទោះជាខ្ញុំបានក្លាយជាសមាជិករបស់សហជីពអស់រយៈពេលជាយូរមកហើយក្តី ខ្ញុំមិនដឹងថា តើសហជីពបានធ្វើអ្វីខ្លះសំរាប់ខ្ញុំ ឬក៏សម្រាប់កម្មករដ៏ទៃទៀតទេ ។ យើងបានចូលរួមធ្វើកូដកម្ម ប៉ុន្តែមានការផ្លាស់ប្តូរតិចតួចណាស់ ។"*

---

[២៨] សហជីពរបស់ឧស្សាហកម្មកាត់ដេរទាំងអស់ត្រូវបានភ្ជាប់ទំនាក់ទំនងជាមួយសហព័ន្ធសហជីពថ្នាក់ជាតិណាមួយក្នុងចំណោមសហព័ន្ធសហជីពថ្នាក់ជាតិទាំង ៥ មានដូចជា The Cambodian Federation of Independent Trade Unions; The Cambodian Union's Federation; The Free Trade Union of Workers of the Kingdom of Cambodia; The Cambodian Labor Union Federation; and The National Independent Federation of Textile Unions in Cambodia. សហជីពថ្នាក់ជាតិទាំង ៥ អះអាងថា មានសមាជិកលើសពី ៨០.០០០នាក់ ហើយថា ចំនួននេះស្មើនឹង ៥០%នៃកម្មករកាត់ដេរទាំងអស់ ។ ទោះបីថា ជាង៩០% នៃសមាជិកសហជីពគឺជាស្ត្រី គេឃើញមានស្ត្រីពីរបីនាក់ បានកាន់កាប់មុខតំណែងថ្នាក់ដឹកនាំ ។ See Stuatt-Smith et al, *Phase 1 Report: Cambodia's Garment Industry* ។

ការដែលគួរឱ្យចំណាប់អារម្មណ៍នោះគឺ មានកម្មករ៥៨នាក់ (៥០%) ក្នុងចំណោមកម្មករទាំង១១៦នាក់ ដែលគេបានសំភាសន៍ បានចូលរួមនៅក្នុងការធ្វើកូដកម្ម ឬការតវ៉ានានា ហើយដែលចំនួននេះខ្ពស់ជាង ចំនួនសមាជិកភាពនៃសហជីពដែលបានរៀបរាប់ខាងលើនេះ។ តាមពិតទៅ បើពិនិត្យឱ្យជិតដល់ បានបង្ហាញឱ្យដឹងថា ក្នុងចំណោម៥៨នាក់ដែលបានចូលរួមធ្វើកូដកម្ម មានតែ ៣៣នាក់ប៉ុណ្ណោះជាសមាជិកសហជីព ។ នៅក្នុងចំណោមអ្នកទាំង៥៨ នាក់នេះ មានកម្មករ១៥នាក់បានរៀបរាប់ថា ការធ្វើកូដកម្មមានប្រសិទ្ធិភាព និងមាន៣៥នាក់ មើល ឃើញថាមិនសូវជាមានប្រសិទ្ធិភាព ហើយ៨នាក់ផ្សេងទៀតមានទស្សនៈថា មិនមានប្រសិទ្ធិភាពទេ ។

តាមការប្រៀបធៀប មានកម្មករ២៣នាក់ (២០%) នៃកម្មករ១១៦នាក់ដែលត្រូវបានសំភាសន៍ បានចូលរួមធ្វើបាតុកម្មតាមដងផ្លូវ ។ ក្នុងចំណោមអ្នកដែលបានចូលរួមបាតុកម្ម ២៣នាក់ មានតែ១២នាក់គឺជាសមាជិកសហជីព ហើយក្នុងចំណោម ២៣នាក់ដដែលនេះ មាន២២នាក់ បានចូលរួមក្នុងការធ្វើកូដកម្ម ឬការតវ៉ាផ្សេងៗ ។ ជារួមមានបាតុករ៧នាក់ក្នុងចំណោម២៣នាក់ បានចាត់ទុកថា ការធ្វើបាតុកម្មតាមដងផ្លូវមានប្រសិទ្ធិភាព ១០នាក់ផ្សេងទៀតគិតថា មិនសូវមានប្រសិទ្ធិភាព ហើយ៥នាក់ទៀតបានចាត់ទុកថា គ្មានប្រសិទ្ធិទេ និងមានតែម្នាក់គត់មិនមានយោបល់អ្វីទាំងអស់ ។

ទោះបីមានកម្មករមួយចំនួនតូចដែលត្រូវបានសំភាសន៍ បានចូលរួមក្នុងសកម្មភាពដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ក៏ពួកគេមានការពេញចិត្តក្នុងកំរិតខ្ពស់គួរកត់សំគាល់ ។ ក្នុងចំណោមកម្មករ១៤នាក់ (១២% នៃកម្មករដែលបានផ្តល់ចម្លើយ១១៤នាក់) ដែលបានចូលរួមនៅក្នុងសកម្មភាពផ្សេងៗរបស់អង្គការមិនមែនរដ្ឋាភិបាល មាន៩នាក់បានចាត់ទុកថា ការចូលរួមមានប្រយោជន៍ និង៣នាក់ទៀតយល់ឃើញថា មានប្រយោជន៍បន្តិចបន្តួច ហើយ២នាក់ទៀត គ្មានយោបល់អ្វីឡើយ ។

**ទំនាក់ទំនងយេនឌ័រ**

គួរឱ្យកត់សំគាល់ថា មានកម្មករចំណាកស្រុក១០៧នាក់ (៩២%) នៃកម្មករ១១៦នាក់ដែលត្រូវបានសំភាសន៍ នៅទីក្រុងភ្នំពេញបានអះអាងថា ពួកគេមានទំនុកចិត្តលើខ្លួនឯង តាំងពីពួកគេបានចាប់ផ្តើមធ្វើការនៅក្នុងរោងចក្រកាត់ដេរមក ។ នៅក្នុងលក្ខណៈស្រដៀងគ្នានេះដែរ មានកម្មករ៩៥នាក់ (៨២%) នៃ១១៦នាក់ បានបញ្ជាក់ថាពួកគេទទួលបាននូវឋានៈខ្ពស់នៅក្នុងគ្រួសាររបស់គេ ។ លើសពីនេះទៅទៀត មានកម្មករ៨៩នាក់ (៧៧%) នៃ១១៦នាក់ បានទទួលស្គាល់ថា ពួកគេពេញចិត្តនឹងការងាររបស់ពួកគេ ។

ការធ្វើការនៅក្នុងរោងចក្រកាត់ដេរបាននាំមកនូវទាំងអត្ថប្រយោជន៍ និង បន្ទុកធ្ងន់ ។ កម្មករដែលបានផ្តល់ចម្លើយ១០០នាក់ (៨៦%) នៃ១១៦នាក់បាននិយាយថា មានអត្ថប្រយោជន៍ច្រើន ។ អត្ថប្រយោជន៍ដែលពួកគេបានលើកឡើងរួមមាន សារៈសំខាន់សំរាប់ក្រុមគ្រួសារ មានឱកាសដើម្បីធ្វើសេចក្តីសំរេចដោយខ្លួនគេ ការគោរពពីបងប្អូន និងក្រុមគ្រួសារមានមោទនភាពច្រើនចំពោះពួកគេ ។ នៅក្នុងប្រទេសកម្ពុជាដែលគេមើលឃើញជាទូទៅថា ស្ត្រីវ័យក្មេងក្នុងគ្រួសារក៏ដូចជានៅក្នុងសង្គម មានឋានៈតូចទាបនោះ ពេលនេះការដែលពួកគេទទួលបាននូវផលប្រយោជន៍ដូចបានរៀបរាប់មកនេះគឺជា ការបង្ហាញអោយឃើញនូវការសំរេចបានស្នាដៃសំខាន់ៗយ៉ាងច្រើន ។ នៅពេលជាមួយនេះ កម្មករដែលបានផ្តល់ចម្លើយ ៨១នាក់ (៧០%) នៃ១១៦នាក់ បានទទួលស្គាល់នូវបន្ទុកធ្ងន់ជាច្រើនដែរ ។ បន្ទុកធ្ងន់ដែលបានរៀបរាប់ដោយក្រុមកម្មករ៨១នាក់រួមមាន ក្តីរំពឹងពីក្រុមគ្រួសារក្នុងការអោយគេនៅតែបន្តធ្វើការងារនៅក្នុងរោងចក្រ និងភាពលំបាកក្នុងការរៀបការនិងក្លាយជាគ្រួសារមួយផ្ទាល់ខ្លួនរបស់គេ ។ បន្ថែមពីលើនេះទៀតគឺ ការដែលពួកគេមានឋានៈនៅក្នុងគ្រួសារប្រសើរជាងពេលមុន ក៏អាចចាត់ទុកថាជាលក្ខខ័ណ្ឌមួយ ដែលតម្រូវអោយពួកគេនៅបន្តផ្តល់ការធ្វើប្រាក់ឧបត្ថម្ភដល់ក្រុមគ្រួសារនៅឯខេត្តបន្តទៅមុខទៀត ។

កម្មករជាច្រើនបានបញ្ចេញនូវទស្សនៈទាំងវិជ្ជមាន និងអវិជ្ជមានផងអំពីថា តើអ្នកភូមិផង យល់ឃើញយ៉ាងណានៅពេលដែលស្ត្រីវ័យក្មេងចេញមកធ្វើការងារតាមរោងចក្រនៅទីក្រុងភ្នំពេញនោះ ។ ទោះបីមានកម្មករដែលបានផ្តល់ចម្លើយ ៤៧នាក់(៤០%)នៃ១១៦នាក់បានលើកឡើងថា អ្នកភូមិសម្លឹងមើលមកពួកគេដោយក្តីគោរព ព្រោះពួកគេគឺជាទីសង្ឃឹម និងជាអ្នករកប្រាក់ចំណូលសំខាន់សំរាប់គ្រួសារ នៅមានកម្មករ ៣៤នាក់ទៀត (២៩%) មានអារម្មណ៍ថា អ្នកភូមិមានការមើលងាយ និងខ្វះការគោរព ។រីឯ៣៥នាក់ផ្សេងទៀត (៣០%) មិនមានយោបល់អ្វីសោះឡើយ ។ កម្មករចំណាកស្រុកម្នាក់មកពីខេត្តព្រៃវែងបានគិតថា កម្មករជាស្ត្រីភេទ ត្រូវទទួលរងនូវទ្វេគ្រោះព្រោះថា *"បើស្ត្រីផ្ញើលុយទៅស្រុកច្រើន គេនឹងនាំគ្នានិយាយថា យើងធ្វើអ្វីៗក្នុងផ្លូវមិនល្អដើម្បីរកលុយអោយបានច្រើន ។ តែបើផ្ញើលុយទៅស្រុកតិចវិញ គេនឹងនាំគ្នានិយាយថា យើងចំណាយលុយច្រើនលើខ្លួនឯង ឬសំរាប់អោយគូស្នេហ៍នៅទីក្រុងភ្នំពេញ ។"*

ចំពោះការបន្តការសិក្សារៀនសូត្ររបស់កម្មករវិញ មានកម្មករ៥៤នាក់ (៤៧%) នៃ១១៦នាក់ បាននិយាយថា ពួកគេបានឈប់រៀន នៅពេលដែលពួកគេបានចាកចេញពីស្រុក មកធ្វើការនៅទីក្រុងភ្នំពេញ ។ មានតែកម្មករ ៩ នាក់ប៉ុណ្ណោះ ដែលមានលទ្ធភាពបន្តការសិក្សានៅទីក្រុងភ្នំពេញ ។ស្រដៀងគ្នានេះដែរ មានតែកម្មករ១១នាក់ បាននិយាយថា ពួកគេបានរៀនជំនាញផ្សេងៗដូចជាកាត់ក្រណាត់ និងដេរប៉ាក់ នៅក្នុងរោងចក្រកាត់ដេរ ដែលអាចជួយឱ្យពួកគេអាចរកការងារធ្វើទៅអនាគតបាន ។ កម្មករម្នាក់មកពីខេត្តព្រៃវែងបានសំដែងនូវការសោកស្តាយៈ *"បងប្អូនប្រុសៗរបស់ខ្ញុំយួរកាបូបសៀវភៅទៅសាលារៀន ចំណែកខ្ញុំយួរចង់បាយ ដើរតំរង់ឆ្ពោះទៅរោងចក្រដើម្បីធ្វើការ ។ខ្ញុំចង់ទៅសាលារៀនដែរ ប៉ុន្តែខ្ញុំត្រូវធ្វើការ ដើម្បីជួយឧបត្ថម្ភដល់គ្រួសាររបស់ខ្ញុំ ។"*

ចំពោះការបាត់បង់ការងារវិញ កម្មករដែលបានផ្តល់ចម្លើយ ៣៩នាក់ (៣៤%) នៃ១១៥នាក់បាននិយាយថា ពួកគេធ្លាប់បាត់បង់ការងារតាមរោងចក្រកាត់ដេរពីមុន ។ តាមពិតពួកគេជាច្រើនបានឈប់ពីការងារដោយសារ មូលហេតុផ្ទាល់ខ្លួនរបស់គេ ។ មានកម្មករមួយចំនួនតូចដែលបានបាត់បង់ការងារ នៅពេលដែលរោងចក្រកាត់បន្ថយ កម្មករ ដោយខ្លះអ្នកបញ្ជោទិញ ឬរោងចក្របិទចោល ។ នៅពេលកម្មករឈប់ពីការងារលើកមុន ភាគច្រើនបាន រកការងារធ្វើភ្លាមនៅតាមរោងចក្រផ្សេងៗទៀត ។ អ្នកខ្លះទៀតត្រូវត្រឡប់ទៅស្រុកសិន ទើបត្រឡប់មកភ្នំពេញ ជាថ្មីម្តងទៀត ហើយចាប់ធ្វើការងារនៅក្នុងរោងចក្រកាត់ដេរបន្តទៀត ។

ក្នុងចំណោមកម្មករទាំង១១៦នាក់ ដែលត្រូវបានសំភាសន៍ មាន៩០នាក់ (៧៨%) បានដឹងជាមុនថា កិច្ចព្រមព្រៀង អនុគ្រោះពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក នឹងត្រូវបានបញ្ចប់នៅចុងឆ្នាំ២០០៤ ។ នៅពេលដែលអ្នកសំភាសន៍ បានសួរថា តើពួកគេនិងធ្វើការងារអ្វី ពេលដែលគេអស់ការងារធ្វើនៅឆ្នាំ ២០០៥ ពេលនោះមានកម្មករចំនួនច្រើន ណាស់បានឆ្លើយថា ពួកគេនឹងត្រឡប់ទៅស្រុកវិញ ។ អ្នកខ្លះទៀតអះអាងថា ពួកគេនឹងរកការងារធ្វើនៅតាម រោងចក្រកាត់ដេរផ្សេងទៀត ឬរកការងារអ្វីផ្សេងទៀតនៅក្នុងទីក្រុងភ្នំពេញ ។ ជាទូទៅ កម្មករជាច្រើនមិនមាន ផែនការច្បាស់លាស់ថា តើគេនឹងប្រកាន់យកទិសដៅណាមួយនោះទេ ។ បើតាមការយល់ឃើញគឺ ពួកគេគិតផ្តោត តែទៅលើការងារបច្ចុប្បន្នដែលពួកគេកំពុងតែធ្វើនេះសិន ។

## បទពិសោធន៍នៃក្រុមគ្រួសារនៅខេត្តព្រៃវែងដែលមានសមាជិកគ្រួសារធ្វើជាកម្មករ

ផ្នែកនេះធ្វើការពិនិត្យ និងពិភាក្សាទៅលើបទពិសោធន៍នៃក្រុមគ្រួសារនៅខេត្តព្រៃវែងដែលមានសមាជិកគ្រួសារជាកម្មករកាត់ដេរ ។ ពត៌មានទាំងនេះទទួលបានពីការសំភាសន៍ជាមួយក្រុមគ្រួសារចំនួន ២១៨នាក់ នៅឃុំល្វា និងឃុំក្រាំងស្វាយ នៃស្រុកព្រះស្តេច ខេត្តព្រៃវែង (១០៩គ្រួសារក្នុងឃុំនីមួយៗ) និង មានការពិភាក្សាជាក្រុមតូចៗជាច្រើនក្រុម ជាមួយថ្នាក់ដឹកនាំនៅតាមភូមិជាច្រើននាក់ ។

### ប្រវត្តិទូទៅ

សំរាប់ការស្រាវជ្រាវនេះ កម្មករចំណាកស្រុក ត្រូវបានចាត់ទុកជាសមាជិកម្នាក់ក្នុងគ្រួសារនៅឯខេត្តព្រៃវែងដែរ ។ ដូច្នេះ មធ្យមភាគនៃទំហំគ្រួសារទាំង ២១៨គ្រួសារដែលត្រូវបានសំភាសន៍គឺ ៦.៨៤ ។ បើគិតជាមធ្យមនៃអ្នកដែលអាចជួយរកចំណូលសំរាប់គ្រួសារគឺ ៣.៩៨ ។ រីឯ ចំនួនមធ្យមនៃអ្នកដែលបានចំណាកស្រុកក្នុងចំណោមអ្នកដែលមានលទ្ធភាពរកចំណូលសំរាប់គ្រួសារ គឺ ១.៩៥ ។ ចំពោះចំនួនមធ្យមភាគនៃអ្នកដែលបានធ្វើជាកម្មករកាត់ដេរក្នុងគ្រួសារវិញគឺមានរហូតដល់ទៅ ១.៤០ ។ នេះជាការបង្ហាញឱ្យឃើញថា កម្មករដែលចំណាកស្រុក ជាពិសេសកម្មកររោងចក្រកាត់ដេរ ជាកម្លាំងពលកម្មមួយចំណែកធំសំរាប់រកចំណូលជួយទ្រទ្រង់ដល់ក្រុមគ្រួសារដែរ ។ ដូចគ្នានេះដែរ ចំណុចខាងលើនេះបានបង្ហាញថា មានក្រុមគ្រួសារជាច្រើនដែលមានសមាជិកគ្រួសារមកធ្វើការនៅតាមរោងចក្រកាត់ដេរលើសពីម្នាក់ ។

ជារួម សមាជិកគ្រួសារដែលបានចំណាកស្រុកគឺស្ត្រីវ័យក្មេងនៅលីវ ។ គេបានរកឃើញថា ក្នុង ២១៨គ្រួសារដែលបានសំភាសន៍មានសមាជិកដែលធ្វើជាកម្មករកាត់ដេរទាំងអស់ចំនួន ៣០៦នាក់ ។ ក្នុងចំណោមកម្មករ ៣០៦នាក់, មានស្ត្រីចំនួន ២៥៤ នាក់ (៨៣%) ។ ចំណែកអាយុរបស់ពួកគេ កត់ត្រាបានពីកម្មករតែ ៣០៥នាក់ប៉ុណ្ណោះ ។ ជាក់ស្តែងអាយុជាមធ្យមនៃកម្មករដែលចាស់ជាងគេបំផុតដែលស្ថិតក្នុង២១៨គ្រួសារនោះគឺ ២៣.៧៥ឆ្នាំ ។ ចំពោះអាយុជាមធ្យមនៃអ្នកចាស់ជាងគេលំដាប់ទី២ ក្នុងចំណោម៧១គ្រួសារគឺ ២១.៦២ឆ្នាំ និងអាយុជាមធ្យមនៃអ្នកចាស់ជាងគេលំដាប់ទី៣ ក្នុងចំណោម១៣គ្រួសារគឺ ២១.៥៤ ឆ្នាំ ។ រីឯអាយុជាមធ្យមនៃអ្នកចាស់ជាងគេលំដាប់ទី៤ ក្នុងចំណោម៣គ្រួសារគឺ ២០ ឆ្នាំ ។ តាមការកត់សំគាល់ មានកម្មករ១០នាក់ក្នុងចំណោមកម្មករ ៣០៥ នាក់គឺជាអនិតិជន ពោលគឺបានចូលធ្វើការតាំងពីអាយុមិនទាន់ដល់ ១៨ម្ល៉េះ ។ ចំពោះស្ថានភាពគ្រួសាររបស់កម្មករ បានកត់ត្រាពត៌មាននេះត្រឹមតែ ៣០៥ នាក់ប៉ុណ្ណោះ ។ ជារួម ២៣៩នាក់ (៧៨%) នៅលីវ រីឯ៥៧នាក់ (១៧%) រៀបការរួចហើយ និង ១២ នាក់ (៤%) ជាស្ត្រីមេម៉ាយ ដោយឡែកមាន ២ នាក់ បានបែកគ្នា ឬលែងលះគ្នា ។

## ប្រវត្តិនៃការធ្វើចំណាកស្រុក និង ស្ថានការណ៍ផ្សេងៗ

តាមការសំភាសន៍ជាមួយក្រុមគ្រួសារនៅក្នុងឃុំល្វា និងឃុំក្រាំងស្វាយ បានបញ្ជាក់ថា សមាជិកគ្រួសាររបស់ពួកគេបានចេញទៅធ្វើការនៅភ្នំពេញតាំងពីមុនឆ្នាំ ១៩៩៧ និងមានការកើនឡើងយ៉ាងខ្លាំងឆ្នាំ ២០០០ និងបន្ទាប់មកបានធ្លាក់ចុះវិញបន្តិចហើយនៅថេរ តែឡើងខ្ពស់ខ្លាំងម្តងទៀតនៅក្នុងឆ្នាំ ២០០៣ (សូមមើលតារាងទី១០)។ ក្នុងខណៈពេលដែលការចំណាកស្រុកពលកម្មតាមរដូវកាលរបស់បុរសទៅកាន់ទីក្រុងភ្នំពេញគឺ កើតមានជាធម្មតានៅក្នុងទសវត្សរ៍១៩៩០ ក្នុងពេលនោះក៏មានការរីកលូតលាស់នៃវិស័យកាត់ដេរនៅក្នុងសហស្សវត្សថ្មី ដែលបានជំរុញឱ្យ មានរលកថ្មីមួយនៃការចំណាកពលកម្មពីជនបទមកកាន់ទីក្រុង ដែលភាគច្រើនស្ត្រីវ័យក្មេងមានឱកាសបានធ្វើការងារក្នុងរយៈពេលវែង។

| តារាងទី ១០: ឆ្នាំដែលកម្មករបានចេញពីក្រុមគ្រួសារមកចាប់ផ្តើមការងារនៅរោងចក្រកាត់ដេរ ឃុំល្វា និង ឃុំក្រាំងស្វាយ ខេត្តព្រៃវែង ខែ កញ្ញា-តុលា ២០០៤ | | |
|---|---|---|
| **ឆ្នាំ** | **ចំនួន** | **ភាគរយ** |
| មុន ឬ នៅឆ្នាំ 1997 | 15 | 6.9 |
| 1998 | 15 | 6.9 |
| 1999 | 24 | 11.1 |
| 2000 | 34 | 15.7 |
| 2001 | 29 | 13.4 |
| 2002 | 31 | 14.4 |
| 2003 | 38 | 17.6 |
| 2004 | 30 | 13.9 |
| **ចំនួនគ្រួសារដែលបានផ្តល់ចំលើយសរុប= 116** | | |

កត្តាទាក់ទាញដោយសារមានឱកាសការងារធ្វើនៅក្នុងរោងចក្រកាត់ដេរគឺជា ភស្តុតាងច្បាស់លាស់ដែលធ្វើអោយសមាជិកក្រុមគ្រួសាររបស់គេ ត្រូវចំណាកស្រុកមករកការងារធ្វើនៅទីក្រុង។ ប៉ុន្តែកត្តាជំរុញក៏ជាហេតុផលសំខាន់ដែលធ្វើអោយសមាជិកគ្រួសាររបស់ពួកគេចំណាកស្រុកដែរ (សូមមើលតារាងទី១១) ។ ឧបសគ្គដែលបានជួបប្រទះដោយសារភាពរាំងស្ងួត និងទឹកជំនន់ក្នុងតំបន់ដែលបានស្រាវជ្រាវ បានបំផ្លាញផលដំណាំស្រូវរយៈពេល៤ឆ្នាំជាប់ៗគ្នាកន្លងមកនេះ និងបានធ្វើអោយឱ្យកសិករជាច្រើនជំពាក់បំណុលគេដោយសារ មិនមានលទ្ធភាពទូទាត់ចំពោះការខាតបង់ក្នុងការធ្វើស្រែចំការរបស់ពួកគេ ។ រីឯបំណុលទាក់ទងនឹងការព្យាបាលសុខភាព បានដាក់ទំងន់បន្ថែមទៅលើវិបត្តិដែលគេមានស្រាប់ទៀត ។ ដោយសារកង្វះឱកាសការងារដើម្បីកំរៃនៅក្នុងភូមិ និងកង្វះខាតធនធានដើម្បីប្រកបមុខរបរអ្វីមួយ ទើបប្រជាជនត្រូវស្វែងរកជំរើសផ្សេងទៀតក្រៅពីនៅក្នុងខេត្តព្រៃវែង។

| តារាងទី ១១: មូលហេតុដែលធ្វើអោយសមាជិកគ្រួសារធ្វើចំណាកស្រុក<br>ឃុំល្វា និង ឃុំក្រាំងស្វាយ ខេត្តព្រៃវែង<br>ខែ កញ្ញា-តុលា ឆ្នាំ ២០០៤ | | |
|---|---|---|
| **មូលហេតុ** | **ចំនួន** | **ភាគរយ** |
| ទិន្នផលស្រូវមិនគ្រប់គ្រាន់ | 180 | 83.7 |
| ការងារមាននៅរោងចក្រកាត់ដេរ | 165 | 76.7 |
| ឱកាសការងារនៅតាមភូមិមិនសូវមាន | 154 | 71.6 |
| កង្វះខាតធនធានយកទៅប្រកបមុខរបរ | 138 | 64.2 |
| បំណុលដោយសារចំណាយលើសុខភាព | 78 | 36.3 |
| បំណុលដោយសារការធ្វើស្រែចំការ | 64 | 29.8 |
| ភាពគ្មានដីធ្លី (ក្រុមគ្រួសារមិនមានដីស្រែ) | 12 | 5.6 |
| បំណុលបណ្ដាលមកពីការលេងល្បែង | 2 | 0.9 |
| ផ្សេងៗ | 17 | 7.9 |
| **ចំនួនគ្រួសារដែលបានផ្ដល់ចំលើយសរុបៈ 215** | | |

ដើម្បីទទួលបានការងារធ្វើនៅរោងចក្រកាត់ដេរ ជានិច្ចកាលទាមទារអោយមានការជួយជ្រោមជ្រែងពីអ្នកដទៃ។ ជាងពាក់កណ្ដាលនៃគ្រួសារដែលត្រូវបានសំភាសន៍ចំនួន ២១៦ នាក់ (១២០នាក់ ឬ ៥៥%) បានរំលឹកថា សមាជិកគ្រួសាររបស់ខ្លួនទទួលបានការងារធ្វើនៅរោងចក្រកាត់ដេរដោយមានសាច់ញាតិជួយ ។ អ្នកខ្លះទៀត (៥០ នាក់ ឬ ២៣%) មានមិត្តភក្ដិជួយ តែអ្នកខ្លះទៀត (៤៦ នាក់ ឬ ២១%) រកការងារបានធ្វើដោយខ្លួនឯង។

ការសូកលុយដើម្បីទទួលបានការងារក្នុងរោងចក្រកាត់ដេរកើតមានជាទូទៅ ទោះបីមិនមែនគ្រប់ករណីក៏ដោយ។ ប៉ុន្តែវាជាការអនុវត្តជាក់ស្ដែង។ ជាក់ស្ដែង ៩៥ គ្រួសារ (៤៤ %) ចំណោម ២១៨ គ្រួសារដែលត្រូវបានសំភាសន៍បញ្ជាក់ថា សមាជិកគ្រួសាររបស់គេបានសូកលុយដើម្បីទទួលបានការងារធ្វើនៅរោងចក្រកាត់ដេរ ។ តាមធម្មតាចំនួនជាមធ្យមដែលបានសូកលុយគេគឺមានកំរិតខ្ពស់រហូតដល់ទៅ ៥១.៩៨ ដុល្លារ។ ក្នុងចំណោមក្រុមគ្រួសារដែលបានសំភាសន៍៩៥គ្រួសារដែលបានសូកលុយគេនោះ មាន៨១គ្រួសារបានខ្ចីលុយដើម្បីយកទៅសូកគេ។ ក្នុងចំណោមគ្រួសារដែលបានខ្ចីគេ មាន៦៩គ្រួសារបានសងគេរួចរាល់ហើយ ។ ដូចគ្នានេះដែរ ក្នុងចំណោម៩៥គ្រួសារដែលបានសូកលុយ មាន៣៣គ្រួសារបានលក់ទ្រព្យសម្បត្តិ ដើម្បីយកទៅសូកគេ ឬសងបំណុលដែលបានខ្ចីគេយកទៅសូកប៉ាន់នោះ។ ទ្រព្យសម្បត្តិដែលបានលក់រួមមាន ជ្រូក គោ ដី និងគ្រឿងអលង្ការ។

## កម្មសិទ្ធិដីធ្លី និងផលិតកម្មកសិកម្ម

ចាប់តាំងពីមានការបែងចែកដីស្រែឡើងវិញដល់ប្រជាកសិករនៅដើមទសវត្សរ៍ទី ៨០នោះមក ការបង្កបង្កើនផលស្រូវនៅលើដីឡូត៍បន្តិចបន្តួចបានក្លាយជាយុទ្ធសាស្ត្រសំខាន់សំរាប់ចិញ្ចឹមជីវិតគ្រួសារក្នុងឃុំល្វា និងឃុំក្រាំងស្វាយ ។ ក្នុងពេលពេលស្រាវជ្រាវកាលពីខែ កញ្ញា-តុលា ២០០៤ បានរកឃើញថា ២០២ គ្រួសារ (៩៣%) នៃ២១៨គ្រួសារដែលត្រូវបានសំភាសន៏ មានកម្មសិទ្ធិដីស្រែ ។ មធ្យមភាគនៃផ្ទៃដីស្រែដែលកាន់កាប់ដោយក្រុម គ្រួសារទាំង ២០២ នោះ មានតែ ១,៥៦ ហិកតា ។ ស្របពេលនោះដែរ មាន៦៣គ្រួសារ (២៩%) នៃគ្រួសារចំនួន ២១៨ ដែលត្រូវបានសំភាសន៏ បានជួលដីស្រែគេ ។ មធ្យមភាគនៃផ្ទៃដីស្រែដែលបានជួលដោយក្រុមគ្រួសារ ទាំង៦១ដែលបានផ្តល់ចំលើយ មានត្រឹមតែ ០,៨៥ហិកតាប៉ុណ្ណោះ ។ សូមបញ្ជាក់ថា ៦០ គ្រួសារក្នុងចំណោម៦៣គ្រួសារដែលបានជួលដីគេនោះ ក៏ជាគ្រួសារដែលមានដីស្រែរបស់គេខ្លះដែរ ។

ក្នុងរដូវបង្កបង្កើនផលឆ្នាំកន្លងទៅនេះ មាន១៩១គ្រួសារ (៩៣%) នៃ២០៥គ្រួសារដែលមានដីស្រែនោះ បានបង្កបង្កើនផលនៅលើដីស្រែរបស់ពួកគេដែរ។ ផ្អែកលើក្រុមគ្រួសារ១៩០ដែលបានឆ្លើយ ផ្ទៃដីជាមធ្យមដែលបានបង្កបង្កើនផលក្នុងឆ្នាំកន្លងមក មានតែ១,៤៨ហិកតា ហើយទទួលបានផលស្រូវជាមធ្យម ១.៥៨១ (មួយពាន់ប្រាំរយប៉ែតសិបមួយ) គីឡូក្រាម ឬ ១,៥៨តោន ។ នៅពេលដែលគណនាជាទិន្នផលក្នុងមួយហិកតាវិញ គេឃើញបានទិន្នផលដ៏ទាបមួយគឺ ១,០៧ តោន ។ បើប្រៀបធៀបទៅនឹងសមាជិកគ្រួសារជាមធ្យមដែលកំពុងតែរស់នៅឯផ្ទះប្រមាណ ៤,៨៩ នោះ ម្នាក់ៗបានទទួលស្រូវត្រឹមតែ ៣២៣គីឡូក្រាម ពីការប្រមូលផលនាឆ្នាំកន្លងមក។ បើគេចាប់ផ្តើមគិតបញ្ចូលសមាជិកដែលបានមកកាត់ដេរដែរនោះ ម្នាក់ៗអាចទទួលបានស្រូវជាមធ្យមត្រឹមតែ ២៣១ គីឡូក្រាមប៉ុណ្ណោះ ។ តាមផលស្រូវដែលទទួលបានកន្លងមក ការដែលមានសមាជិកក្នុងគ្រួសារចំណាកស្រុកគឺជាការកាត់បន្ថយនូវបន្ទុកធ្ងន់មួយនៅគ្រួសាររបស់គេ។

មិនមែនជារឿងចម្លែកនោះទេ នៅពេលដែលមានគ្រួសារដែលត្រូវបានសំភាសន៏ ១៧២ នាក់ (៨៤%)ក្នុងចំណោម ២០៤គ្រួសារនោះ បានអះអាងថា ការប្រមូលផលស្រូវរបស់ពួកគេ មិនគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់គ្រួសាររយៈពេលមួយឆ្នាំទេ ។ ភាគច្រើនបំផុត (៩៦%) នៃគ្រួសារដែលមានការខ្វះខាត ត្រូវការទិញស្រូវចូលបន្ថែម សំរាប់រយៈពេល២ខែ ឬលើសពីនេះ ។ ដោយឡែក មានគ្រួសារជាងពាក់កណ្តាល (៥៨%) ត្រូវការទិញស្រូវចូលបន្ថែមសំរាប់រយៈពេល៤ខែ ឬច្រើនជាងនេះ និង គ្រួសារ ១/៤ (២៧%) ត្រូវការទិញស្រូវបន្ថែមសំរាប់រយៈ ពេល៦ខែ ឬច្រើនជាងនេះ។

ដោយសារគ្រោះរាំងស្ងួតខ្លាំងបានធ្វើឱ្យប៉ះពាល់ដល់ឃុំទាំងពីរនៅចុងឆ្នាំ ២០០៤ បានធ្វើអោយវិបត្តិក្នុងវិស័យកសិកម្មស្ទើរតែក្លាយជាវិបត្តិដែលកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ។ នារដូវបង្កបង្កើនផលបច្ចុប្បន្ន ១៩៣គ្រួសារ (៩៤%) ក្នុងចំណោម២០៥គ្រួសារដែលមានដីស្រែកំពុងតែមមាញឹកក្នុងការធ្វើស្រែ ។ តែដោយសារផលវិបាកគ្រោះរាំងស្ងួត ភាគច្រើននៃកសិករទាំងនោះមិនអាចប៉ាន់ស្មានថា នឹងទទួលបានទិន្នផលប៉ុន្មាននោះទេ ។ ទន្ទឹមនឹងនេះក៏មាន៧២គ្រួសាររំពឹងទុកថា ផលស្រូវដែលកំពុងតែខិតខំធ្វើ នឹងបានជាមធ្យមប្រហែល៨៤៩គីឡូក្រាម ។ ចំនួនទិន្នផលស្រូវរំពឹងទុកនេះ រឹតតែទាបជាង ពោលគឺស្មើនឹង ៤៦% នៃទិន្នផលស្រូវជាមធ្យមដែលបានទទួលនារដូវកាលបង្កបង្កើនផលក្នុងឆ្នាំកន្លងមក។

ក្នុងខណៈពេលដែលគ្រួសារមួយចំនួនតូចគ្មានដីធ្លី (១៦គ្រួសារ ឬ៧%) ក្នុងចំណោមក្រុមគ្រួសារទាំង២១៨ ដែលត្រូវបានសំភាសន៍នោះ គេយល់ឃើញថា មាននិន្នាការមួយឈានទៅរកវិសមភាពធនធានដីធ្លី កាន់តែលេចឡើង។ ក្នុងចំណោមក្រុមគ្រួសារទាំងអស់ដែលត្រូវបានសំភាសន៍ មាន ៤៣គ្រួសារ (២០%) បានលក់ដីស្រែ។ រីឯផ្ទៃក្រឡាជាមធ្យមដែលបានលក់ដោយ ៤១ គ្រួសារស្មើនឹង ០,៩២ ហិកតា។ ផ្ទុយទៅវិញ មាន៤៨គ្រួសារ (២២%) នៃក្រុមគ្រួសារដែលបានសំភាសន៍ទាំងអស់ បានទិញដីស្រែដែលមានផ្ទៃដីដែលបានទិញជាមធ្យម ១,៨៣ហិកតា ។ គួរកត់សំគាល់ថា ៣៤ គ្រួសារ (៧៩%)នៃអ្នកលក់ដីទាំងអស់ មិនមែនជាអ្នកធ្លាប់បានទិញដីស្រែនោះទេ ហើយនិងដោយឡែក ៣៩ គ្រួសារ (៨១%)នៃអ្នកទិញដីស្រែទាំងអស់ ក៏មិនមែនជាអ្នកធ្លាប់បានលក់ដីស្រែនោះដែរ។ រឿងរ៉ាវទាំងនេះ បានបង្ហាញអោយឃើញនូវរឿងរ៉ាវផ្សេងៗគ្នានៃអ្នកដែលពាក់ព័ន្ធក្នុងការទិញ និងលក់ដីស្រែ។ ជាក់ស្តែង អ្នកដែលលក់ដីស្រែ មានដីសែតិចជាងអ្នកមិនបានលក់ ជាមធ្យម ០,៧១ ហិកតា ។ ចំណែកអ្នកទិញដីស្រែវិញ មានដីស្រែច្រើនជាងអ្នកមិនបានទិញ ជាមធ្យម ០,៨៥ ហិកតា ។ មេឃុំក្រាំងស្វាយបានធ្វើអត្ថាធិប្បាយថា អ្នកទិញដីដែលរស់នៅក្នុងមូលដ្ឋានដែរនោះ បានខិតខំទិញដីពីគ្រួសារដែលលក់ដីក្នុងពេលមានគ្រោះអាសន្ន ដើម្បីពង្រីកទំហំដីកម្មសិទ្ធិរបស់ពួកគេ។

## ការផ្ញើប្រាក់របស់កម្មករចំណាកស្រុក

ក្រុមគ្រួសារទាំងអស់ដែលត្រូវបានសំភាសន៍សុទ្ធតែមានសមាជិកគ្រួសារធ្វើជាកម្មករកាត់ដេរ។ ដូច្នេះ ជាការធម្មតាដែលមាន២០៦គ្រួសារ (៩៤%) នៃគ្រួសារដែលបានសំភាសន៍ទាំង២១៨គ្រួសារ បានទទួលប្រាក់ផ្ញើឧបត្ថម្ភពីសមាជិកគ្រួសារដែលជាកម្មករកាត់ដេរនោះ។ ចំនួនជាមធ្យមប្រចាំខែដែលគ្រួសារទាំង២០៥ បានទទួលគឺ ១៦,១២ ដុល្លារ។ ក្រុមគ្រួសារទាំងនោះ បានប្រើប្រាស់លុយដែលបានទទួលសំរាប់ជួយផ្គត់ផ្គង់ជីវភាពគ្រួសារ មានគ្រួសារខ្លះបានយកទៅប្រកបមុខរបរខ្នាតតូច (សូមមើលតារាងទី១២)។ ជាក់ស្តែង ទោះបីជាពតិមានលំអិតទាក់ទងទៅនឹង

បញ្ហាស្បៀងក្តី តែការទិញស្បៀងអាហារ ត្រូវបានពួកគេលើកមកនិយាយជាញឹកញាប់ ។ ការបែងចែកលុយដែលផ្ញើមកសំរាប់ការចំណាយលើសុខភាពក្នុងគ្រួសារ និងយកទៅធ្វើស្រែចំការ ក៏ត្រូវបានគេរៀបរាប់ជាទូទៅដែរ ។ ក្រៅពីនោះ ក៏មានការចំណាយសំរាប់ការសិក្សារៀនសូត្ររបស់សមាជិកក្នុងគ្រួសារ និងការទូទាត់បំណុល។ មានគ្រួសារខ្លះបានយកទៅរួមផ្សំដើម្បីទិញទ្រព្យសម្បត្តិរួមមាន ផ្ទះ គ្រឿងយន្ត សំរាប់ធ្វើស្រែចំការ ដី កម្លាំងអូសទាញ និងម៉ូតូ ។ ចំណែកឯ ការយកទៅប្រកបមុខរបរខ្នាតតូចវិញ មានគ្រួសារមួយភាគតូចប៉ុណ្ណោះ ។

| **តារាងទី ១២: ការប្រើប្រាស់លុយរបស់ក្រុមគ្រួសារនៅខេត្តព្រៃវែង ចំពោះលុយដែលកម្មកររោងចក្របានផ្ញើទៅឃុំល្វា និង ឃុំក្រាំងស្វាយ ខេត្តព្រៃវែង ខែ កញ្ញា-តុលា ២០០៤** | | |
|---|---|---|
| មុខចំណាយ | ចំនួន (នាក់) | ភាគរយ |
| ចំណាយលើសុខភាពគ្រួសារ | 162 | 78.60 |
| ចំណាយសំរាប់ការធ្វើស្រែចំការ | 140 | 68.00 |
| ឧបត្ថម្ភការរៀនសូត្រដល់សមាជិកគ្រួសារ | 130 | 63.10 |
| សងបំណុលគេ | 96 | 46.60 |
| យកទៅទិញទ្រព្យសម្បត្តិសំរាប់គ្រួសារ | 45 | 21.80 |
| ធ្វើជំនួញ ឬមុខរបរខ្នាតតូច | 18 | 8.70 |
| **ចំនួនគ្រួសារដែលបានផ្តល់ចំលើយសរុប = 215** | | |

## យុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិត

ក្រុមគ្រួសារក្នុងឃុំល្វា និងឃុំក្រាំងស្វាយដែលបានសំភាសន៍បានប្រកបមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ តាមរយៈសកម្មភាពរកចំណូលច្រើនផ្នែកដែលរួមមាន ការធ្វើស្រែ ការងារចំណាកស្រុក (ជាពិសេស ធ្វើការនៅរោងចក្រកាត់ដេរ) ការដាំដំណាំ ការលក់ដូរ (ដូចជា ជ្រូក គោ និងមាន់) ស៊ីឈ្នួលគេ (ទាំងការងារកសិកម្ម និងក្រៅពីកសិកម្ម) ការប្រមូលនិងលក់បន្លែបង្កាដែលបានពីវាលស្រែ ព្រមទាំងការផលិត និងលក់គ្រឿងសិប្បកម្មផ្សេងៗ។ គួរកត់សំគាល់ផងដែរថា ក្នុងចំណោមឱកាសរកចំណូលទាំងនេះ គេមើលឃើញថា ការធ្វើស្រែចំការ និងការងារចំណាកស្រុកគឺជាប្រភពផ្គត់ផ្គង់ជីវភាពដ៏សំខាន់បំផុត (សូមមើលតារាងទី១៣)។ ដោយសារតែមានគ្រោះរាំងស្ងួត និងទឹកជំនន់ផ្ទួនៗគ្នាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និង ការបញ្ចប់កូតានាំចូលសម្លៀកបំពាក់នៅចុងឆ្នាំ ២០០៤ ទើបធ្វើអោយមុខរបរចម្បងដែលនាំមកនូវចំណូលច្រើនសំរាប់គ្រួសារដូចដែលបានលើកឡើងមកនេះ ស្ថិតក្នុងភាពមិនទៀងទាត់ឡើយ ។ ម្យ៉ាងទៀត លទ្ធភាពនៃការវិលត្រឡប់របស់កម្មករកាត់ដេរក្នុងចំនួនច្រើនទៅកាន់

ភូមិកំណើតរបស់គេនៅឯព្រៃវែង អាចជាបន្ទុកធ្ងន់បន្ថែមទៀតចំពោះគ្រួសារ ក្នុងខណៈដែលសេដ្ឋកិច្ចគ្រួសារពឹងផ្អែកទៅលើតែការធ្វើស្រែចំការ ហើយមិនបានផលល្អផងនោះ ។ ស្រដៀងគ្នានេះដែរ ការមានឱកាសតិចតួចសំរាប់អ្នកចំណាកពលកម្មមកពីជនបទ មកកាន់ទីក្រុងភ្នំពេញ នឹងបន្តធ្វើអោយសមាជិកគ្រួសារដែលចាប់ផ្តើមមានវ័យអាចជួយរកចំណូលក្នុងគ្រួសារបាន បែរជានៅរង់ចាំពឹងផ្អែកតែទៅលើមុខរបរធ្វើស្រែចំការដែលមានទិន្នផលទាបស្រាប់ ហើយដែលងាយនឹងប៉ះពាល់ដោយគ្រោះមហន្តរាយធម្មជាតិ ។

**តារាងទី ១៣ៈ ចំណាត់ថ្នាក់នៃប្រភេទមុខរបររបស់ក្រុមគ្រួសារ**
**ឃុំល្វា និង ឃុំក្រាំងស្វាយ ខេត្តព្រៃវែង**
**ខែ កញ្ញា-តុលា ២០០៤**

| ប្រភេទមុខរបរ | សំខាន់ណាស់ | | សំខាន់លំដាប់ទី២ | | សំខាន់លំដាប់ទី៣ | | សំខាន់លំដាប់ទី៤ | | សំខាន់លំដាប់ទី៥ | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| ធ្វើស្រែ និងដាំដំណាំ | 164 | 79.6 | 22 | 11 | 3 | 1.9 | 1 | 2.4 | 0 | 0 |
| ការងារចំណាកស្រុក (រួមទាំងការងារក្នុងរោងចក្រកាត់ដេរ) | 31 | 15 | 119 | 59.8 | 44 | 27.7 | 7 | 17.1 | 0 | 0 |
| ធ្វើការលក់-ដូរ (សត្វពាហនៈ និងសត្វស្លាប) | 4 | 1.9 | 40 | 20.1 | 68 | 42.8 | 14 | 34.1 | 3 | 42.8 |
| ស៊ីឈ្នួលធ្វើការងារតាមភូមិ (ស៊ីឈ្នួលធ្វើស្រែ និងការងារផ្សេងៗតាមភូមិ) | 5 | 2.4 | 13 | 6.5 | 36 | 22.6 | 15 | 36.6 | 2 | 28.6 |
| ផលិត និងលក់គ្រឿងសិប្បកម្ម | 2 | 1 | 5 | 2.5 | 8 | 5 | 4 | 9.8 | 2 | 28.6 |
| **សរុប** | **206** | **99.9** | **199** | **99.9** | **159** | **100** | **41** | **100** | **7** | **100** |

តាមរយៈកំរិតនៃចំណាយប្រចាំគ្រួសារ បានឆ្លុះអោយឃើញពីជីវភាពគ្រួសារដែលស្ថិតនៅក្នុងកំរិតទាបនៅឡើយ ។ ក្រុមគ្រួសារដែលត្រូវបានសំភាសន៍បាននិយាយថា គាត់បានចាយវាយប្រាក់ចំណូលភាគច្រើនទៅលើស្បៀងអាហារ ការចំណាយលើការធ្វើស្រែចំការដូចជា ជី ថ្នាំសំលាប់សត្វល្អិត និងដោយឡែក សំរាប់ការព្យាបាលសុខភាពក្នុងគ្រួសារ (សូមមើលតារាងទី ១៤)។ ចំណែកឯ ការយកទៅទិញទ្រព្យសម្បត្តិ និងធ្វើជំនួញខ្នាតតូច គឺមានតិចតួចណាស់ ។ តាមពិតទៅ ឧស្សាហកម្មកាត់ដេរបានផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចខ្លះសំរាប់ក្រុមគ្រួសារនៅទីជនបទក្នុងខេត្តព្រៃវែងដែលបានសំភាសន៍មកនេះ តែឧស្សាហកម្មនេះ មិនបានលើកកំពស់ក្រុមគ្រួសារទាំងនេះអោយហួសពីកំរិតជីវភាពតូចទាប ពោលគឺ មិនបានក្លាយទៅជាគ្រួសារមានទ្រព្យសម្បត្តិអ្វីច្រើននោះឡើយ ។

| តារាងទី ១៤: ចំណាត់ថ្នាក់នៃកំរិតចំណាយរបស់ក្រុមគ្រួសារ ឃុំល្វា និង ឃុំក្រាំងស្វាយ ខេត្តព្រៃវែង ខែ កញ្ញា-តុលា ២០០៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មុខចំណាយ | ចំណាយច្រើន | | ចំណាយលំដាប់ទី២ | | ចំណាយលំដាប់ទី៣ | | ចំណាយលំដាប់ទី ៤ | | ចំណាយលំដាប់ទី៥ | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| ស្បៀងអាហារ | 144 | 70.2 | 36 | 17.6 | 19 | 10.2 | 2 | 2.0 | 0 | 0 |
| ចំណាយសំរាប់ធ្វើស្រែចំការ | 34 | 16.6 | 99 | 48.3 | 36 | 19.2 | 10 | 10.2 | 0 | 0 |
| ចំណាយលើសុខភាព | 21 | 10.2 | 56 | 27.3 | 88 | 47.0 | 16 | 16.3 | 2 | 20 |
| សងបំណុល | 5 | 2.4 | 10 | 4.8 | 37 | 19.9 | 53 | 54.1 | 4 | 40 |
| ទិញទ្រព្យសម្បត្តិ | 0 | 0 | 4 | 1.9 | 3 | 1.6 | 12 | 12.2 | 2 | 20 |
| ធ្វើជំនួញខ្នាតតូច | 1 | 0.5 | 0 | 0 | 4 | 2.1 | 5 | 5.1 | 0 | 0 |
| **សរុប** | **205** | **99.9** | **205** | **99.9** | **187** | **100** | **98** | **99.9** | **10** | **100** |

## ការដោះស្រាយវិបត្តិ

ក្នុងចំណោមគ្រួសារដែលត្រូវបានសំភាសន៏ ២១៨គ្រួសារ មាន១៩២គ្រួសារ (៨៨%) បានទទួលស្គាល់ថា ពួកគាត់បានជួបវិបត្តិនេះក្នុងរយះកាលពី៥ឆ្នាំកន្លងមកនេះ។ វិបត្តិដែលបានកើតឡើងញឹកញាប់ជាងគេដែលបានបញ្ជាក់ជូនក្នុងចំណោមគ្រួសារទាំង១៩២នាក់នោះគឺ ការខូចខាតផលស្រូវដំណាំ (១៤៦គ្រួសារ ឬ ៧៦%) និងសមាជិកគ្រួសារមានជំងឺ (១៤0គ្រួសារ ឬ៧៣%)។ នៅពេលប្រឈមមុខនឹងវិបត្តិនានា ក្រុមគ្រួសារទាំងនោះបានឆ្លើយតបតាមមធ្យោបាយច្រើនយ៉ាង មានដូចជា ពួកគាត់បានកាត់បន្ថយការហូបចុកក្នុងគ្រួសារ ស្វែងរកជំនួយពីសាច់ញាតិខ្ចីបុលដោយមានការប្រាក់ និងលក់ទ្រព្យសម្បត្តិខ្លះដូចជា សត្វពាហនៈ គ្រឿងអលង្ការ និងដីធ្លី។

## ទំនាក់ទំនងយេនឌ័រក្នុងគ្រួសារ

ក្នុងចំណោមគ្រួសារដែលត្រូវបានសំភាសន៏ទាំង ២១៨គ្រួសារ មាន១៧០គ្រួសារ (៧៨%) បាននិយាយថាពួកគាត់បានប្រឈមមុខនឹងកង្វះកំលាំងពលកម្មក្នុងផ្ទះ តាំងពីសមាជិកគ្រួសារបានចេញពីផ្ទះទៅរកការងារធ្វើ ហើយកង្វះកំលាំងពលកម្មនេះ បានប៉ះពាល់ដល់ការងារផលិតកម្ម (ការធ្វើស្រែ និងការចិញ្ចឹមសត្វ) ក៏ដូចជាការងារក្នុង និងជុំវិញផ្ទះសម្បែង (ការចំអិនអាហារ បោកគក់ និងការមើលថែទាំក្មេង និងមនុស្សចាស់នៅក្នុងគ្រួសារ) (សូមមើលតារាងទី១៥)។

| **តារាងទី ១៥: ប្រភេទនៃបញ្ហាកង្វះកំលាំងពលកម្មដែលក្រុមគ្រួសារបានប្រឈមមុខ<br>ខេត្តព្រៃវែង ខែ កញ្ញា-តុលា ២០០៤** | | |
|---|---|---|
| ប្រភេទនៃបញ្ហា | ចំនួន | ភាគរយ |
| កង្វះកំលាំងពលកម្មធ្វើស្រែចំការ | 160 | 94.10 |
| កង្វះពលកម្មមើលថែសត្វ | 97 | 57.10 |
| កង្វះពលកម្មសំរាប់ចំអិនអាហារ និងសំអាតផ្ទះសម្បែង | 83 | 48.80 |
| កង្វះពលកម្មសំរាប់ការបោកគក់ | 71 | 41.80 |
| កង្វះពលកម្មមើលថែទាំក្មេងតូចៗ | 49 | 28.80 |
| កង្វះពលកម្មមើលថែទាំមនុស្សចាស់ | 36 | 21.20 |
| កង្វះពលកម្មដើម្បីជួយលក់ដូរនៅក្នុងផ្ទះ | 7 | 4.10 |
| ផ្សេងៗ | **10** | 5.90 |
| **ចំនួនគ្រួសារដែលបានផ្តល់ចំលើយសរុប = 170** | | |

ទោះជាមានការបាត់បង់នូវកម្មលាំងពលកម្មនៅឯផ្ទះក៏ដោយ ក្រុមគ្រួសារភាគច្រើនគឺ ១៨១ គ្រួសារ (៨៣%) នៃគ្រួសារដែលត្រូវបានសំភាសន៏២១៨គ្រួសារបានអះអាងថា សមាជិកគ្រួសារធ្វើការនៅរោងចក្រកាត់ដេរ មានសារៈសំខាន់សំរាប់ក្រុមគ្រួសារនាពេលបច្ចុប្បន្ននេះ ជាងពីមុនការចាប់ផ្តើមធ្វើការងារនៅភ្នំពេញ ។ ដោយសារភាគច្រើននៃកម្មករគឺជាស្ត្រី នេះជាការបង្ហាញអោយឃើញនូវភាពប្រសើរឡើងនៃស្ថានភាព ឬឋានៈរបស់ស្ត្រីនៅក្នុងក្រុមគ្រួសារ ។ តាមលទ្ធផលនៃការពិភាក្សាក្រុមតូចៗជាមួយថ្នាក់ដឹកនាំភូមិ ក៏បានបង្ហាញនូវការយល់ស្របដូចគ្នាដែរថាស្ថានភាពឬឋានៈរបស់ស្ត្រីដែលជាកម្មករកាត់ដេរបានពិតជាមានភាពប្រសើរនៅក្នុងគ្រួសារមែន។ ជាក់ស្តែងផលប្រយោជន៏ដែលទទួលបានពីការផ្ញើប្រាក់ឧបត្ថម្ភរបស់កម្មករ អាចទូទាត់គ្នាបានជាមួយនឹងបញ្ហាកង្វះពលកម្មដែលក្រុមគ្រួសារបានប្រឈមកន្លងមក។

ខណៈដែលស្ថានភាព ឬឋានៈរបស់កម្មករ និងស្ត្រីបានប្រសើរឡើង ដោយការបំពេញការងារនៅរោងចក្រកាត់ដេរ យើងពិនិត្យឃើញថា ២០២ គ្រួសារ (៩៣%) នៃគ្រួសារដែលបានសំភាសន៍ទាំងអស់ បានសំដែងនូវក្តីកង្វល់អំពីសមាជិកគ្រួសាររបស់គេដែលកំពុងតែរស់នៅ និងធ្វើការនៅទីក្រុងភ្នំពេញ។ កង្វល់ចំបងរបស់ក្រុមគ្រួសារទាំងនោះ គឺទាក់ទងនឹងសុវត្ថិភាពផ្ទាល់ខ្លួន បញ្ហាសុខភាព លក្ខខ័ណ្ឌនៃការរស់នៅ និងក្តីបារម្ភខ្លាចសមាជិកគ្រួសាររបស់ខ្លួនដែលបានមកធ្វើការនេះ រស់នៅកណ្តោចកណ្តែងម្នាក់ឯង។

មានគ្រួសារជាងពាក់កណ្តាល (១៣២គ្រួសារ ឬ ៦១%) នៃក្រុមគ្រួសារទាំង ២១៨ បានដឹងថា កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកនឹងត្រូវបញ្ចប់នៅចុងឆ្នាំ ២០០៤។ ភាគច្រើននៃគ្រួសារទាំងនេះ បានអះអាងថា សមាជិកគ្រួសារដែលជាកម្មករ គួរតែត្រឡប់ទៅកាន់ភូមិកំណើតវិញ បើពួកគេត្រូវបាត់បង់ការងារនៅតាមរោងចក្រនៅក្នុងឆ្នាំ ២០០៥ ។ ប៉ុន្តែក៏មានគ្រួសារជាច្រើនបានគិតដែរថា ពួកគេក៏នឹងអាចត្រឡប់ទៅទីក្រុងភ្នំពេញវិញ ដើម្បីរកការងារធ្វើនៅតាមរោងចក្រកាត់ដេរដទៃទៀត និងការងារផ្សេងៗទៀត។ បញ្ហានេះក៏ធ្លាប់កើតមានកន្លងមកជាហូរហែដែរ ពោលគឺ នៅពេលដែលសមាជិកជាកម្មករខ្លះបានបាត់បង់ការងារ ពួកគេបានវិលមករកការងារនៅទីក្រុងភ្នំពេញវិញ ។ ចំណែកឯ ការពិភាក្សាក្នុងក្រុមតូចបានបញ្ចេញទស្សនះថា ពួកគេមានការគាំទ្រ និងចង់អោយកូនប្រុសធ្វើការនៅភ្នំពេញ ច្រើនជាងកូនស្រី។

## ករណីសិក្សាមួយចំនួននៃក្រុមគ្រួសារនៅខេត្តព្រៃវែងដែលមានសមាជិកជាកម្មករ

ផ្នែកនេះមានការលាតត្រដាងនូវប្រវត្តិរឿងរ៉ាវរបស់ក្រុមគ្រួសារកម្មករមួយចំនួន នៅខេត្តឃុំល្វា និងឃុំក្រាំងស្វាយ ក្នុងស្រុកព្រះស្ដេច ខេត្តព្រៃវែង ។ ករណីសិក្សានេះ មានរៀបរាបលអំពីសារៈសំខាន់នៃការងារកាត់ដេរ ចំពោះជីវភាពគ្រួសារដែលពឹងផ្អែកលើការធ្វើស្រែចំការ ហើយដែលពួកគេកំពុងតែខិតខំប្រកបរបរនេះ ដើម្បីចិញ្ចឹមជីវិតក្នុងខណៈពេលដែលមានការចំណាយខ្ពស់សំរាប់ការធ្វើស្រែចំការ ការធ្លាក់ចុះនៃទិន្នផលស្រូវបណ្ដាលមកពីមានគ្រោះរាំងស្ងួត និងទឹកជំនន់ផ្ទួនៗគ្នា និងការបែងចែកដីស្រែចំការទៅអោយសមាជិកគ្រួសារដែលបានរៀបការរួចផងនោះ ។ សំរាប់គ្រួសារមួយចំនួន ការផ្ញើប្រាក់មកផ្ទះរបស់សមាជិកកាត់ដេរ មានសារៈសំខាន់ណាស់សំរាប់ជួយដល់ជីវភាពរស់នៅរបស់ក្រុមគ្រួសារ ។ ឯក្រុមគ្រួសារខ្លះទៀត លុយផ្ញើមកនេះ បានជួយដល់ការចំណាយផ្នែកសុខភាពក្នុងគ្រួសារ ។ សំរាប់គ្រួសារមួយចំនួនទៀត លុយនេះបានជួយបន្ធូរបន្ថយការខ្វះខាតស្រូវអង្ករក្នុងគ្រួសារ ។

ទោះបីគេមើលឃើញថា គ្រួសារជាច្រើនដែលបានលើកឡើងក្នុងករណីសិក្សាទទួលផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចពីការងាររោងចក្រកាត់ដេរក៏ដោយ ផលវិបាកនៃការរស់នៅបែកគ្នាក៏កើតមានជាក់ស្ដែងដែរ ។ ជាពិសេស ឪពុកម្ដាយមានការខ្វាយខ្វល់អំពីកូនៗនៅលីវដែលកំពុងតែរស់នៅឯទីក្រុងភ្នំពេញ ។ ពួកគេនឹកគិតថា កូនស្រីរបស់ពួកគេអាចនឹងរៀបការជាមួយបុរសមកពីខេត្តផ្សេងៗដែលអាចនឹងមិនវិលត្រឡប់មករស់នៅក្នុងភូមិកំណើតវិញ ។ ក្នុងខណៈពេលជាមួយគ្នានោះដែរ ឱកាសសំរាប់ធ្វើការនៅជុំវិញភូមិកំណើត មានតិចតួចណាស់ ។ ដោយសារកម្មករមើលឃើញនូវឱកាសការងារល្អនៅក្នុងទីក្រុង ទើបពួកគេសុខចិត្តរស់នៅក្នុងភាពកណ្ដោចកណ្ដែងឆ្ងាយពីក្រុមគ្រួសារ និងខិតខំប្រឹងប្រែងធ្វើការងារ ។ ការធ្វើការងារលើសម៉ោងច្រើនគឺជា ការងារដែលកម្មករបានទទួលធ្វើជាទូទៅ ហើយមានករណីមួយដែលបានបញ្ជាក់ថា កម្មករបានដួលទៅលើកំរាលឥដ្ឋដោយមិនដឹងខ្លួន ។ ដោយឡែក ស្ត្រីដែលមានកូន តែងតែទុកកូនរបស់គេអោយឪពុកម្ដាយជួយមើលថែទាំនៅឯខេត្តដោយសារការងារច្រើនពេក ។ តាមការរៀបរាប់ ទាំងកម្មករ និងក្រុមគ្រួសាររបស់ពួកគេ មានការពឹងផ្អែកមកលើការងារមួយដែលមានភាពមិនទៀងទាត់ឡើយ ។ ជារួម ពួកគេមិនមានឥទ្ធិពលអ្វី ដើម្បីជំរុញអោយឧស្សាហកម្មកាត់ដេរអោយនៅបន្តទៅមុខទៀតជួយលើកំពស់នៅជីវភាពរស់នៅរបស់ពួកគេនោះទេ ។

**ករណីសិក្សាទី ១:**

**គ្រួសាររបស់លោក ង៉ែត ខេង និង អ្នកស្រី ហ៊ួត សុថា**

**នៅភូមិត្នោតច្រុះ ឃុំល្វា**

លោក ង៉ែត ខេង និងភរិយា ហ៊ួត សុថា បានរស់នៅក្នុងមួយជីវិតរបស់ពួកគេនៅក្នុងភូមិត្នោតច្រុះ ឃុំល្វា។ បច្ចុប្បន្ននេះ លោក ខេង មានអាយុ ៤៩ ឆ្នាំ ចំណែកអ្នកស្រីសុថា មានអាយុ ៤៨ ឆ្នាំ គូស្វាមីភរិយានេះមានកូនបីនាក់ ហើយសុទ្ធតែនៅលីវ ។ កូនប្រុសរបស់ពួកគាត់ឈ្មោះ ង៉ែត វណ្ណៈ អាយុ ២៥ ឆ្នាំ កំពុងរស់នៅ និងធ្វើស្រែចំការជាមួយឪពុកម្តាយ ។ ប៉ុន្តែកូនស្រីទាំងពីររបស់គាត់ ង៉ែត ម៉ាឡៃ អាយុ ២២ ឆ្នាំ និង ង៉ែត សុខា អាយុ ១៩ ឆ្នាំ បានធ្វើចំណាកស្រុកទៅធ្វើការងារកាត់ដេរនៅទីក្រុងភ្នំពេញ។

កញ្ញា ង៉ែត សុខា ជាប្អូនស្រីពៅក្នុងចំណោមបងប្អូនស្រីទាំងពីរ បានចាកចេញពីផ្ទះមុនគេរយៈពេលបីឆ្នាំមកហើយ បន្ទាប់ពីនាងបានបញ្ចប់ការសិក្សាថ្នាក់ទី៩ ។ កញ្ញាបានរស់នៅទីក្រុងភ្នំពេញជាមួយមិត្តភក្តិមកពីភូមិជាមួយគ្នា។ នៅឆ្នាំដំបូង កញ្ញាមិនអាចរកការងារបានធ្វើនៅក្នុងរោងចក្រដែលគ្រប់គ្រងដោយបរទេសនោះទេ ដូច្នេះ កញ្ញាត្រូវចំណាយពេលរបស់នាង រៀនដេរសំលៀកបំពាក់ឱ្យអ្នកជំនួញស្ត្រីក្នុងស្រុកម្នាក់ ។ កញ្ញារកប្រាក់បានបន្តិចបន្តួច ហើយត្រូវពឹងផ្អែកលើក្រុមគ្រួសារនៅភូមិត្នោតច្រុះ ដើម្បីផ្គត់ផ្គង់ជីវភាពនាងនៅទីក្រុង ។ ឪពុកម្តាយរបស់កញ្ញាបានផ្ញើអង្ករ១៥គីឡូក្រាម និងថវិកា ២៥,000រៀលសំរាប់ឆ្នាំដំបូង ។ លុះក្រោយមកនាងក៏រកការងារ បានធ្វើនៅក្នុងរោងចក្រកាត់ដេរដែលមានម្ចាស់ជាជនបរទេស។

តាមបទពិសោធន៍របស់កញ្ញា ង៉ែត ម៉ាឡៃ ដែលជាបងស្រីគឺប្រហាក់ប្រហែលនឹងប្អូនស្រីដែរ។ នាងបានធ្វើចំណាកស្រុកទៅកាន់ក្រុងភ្នំពេញរយៈពេល២ឆ្នាំមកហើយ បន្ទាប់ពីនាងបានបញ្ចប់ថ្នាក់មធ្យមសិក្សា ប៉ុន្តែនាងត្រូវចំណាយពេលវេលារៀនដេរជាមួយអ្នកបើកហាងកាត់ដេរក្នុងស្រុកម្នាក់ ។ ប្រាក់ចំណូលរបស់នាងពេលនោះបានតិចតួច ហើយបានប្អូនស្រីរបស់នាងឈ្មោះ សុខា ជួយផ្គត់ផ្គង់នាងបន្ថែម ។ ឪពុកម្តាយរបស់កញ្ញា ម៉ាឡៃ ក៏បានផ្តល់អង្ករឱ្យនាង ១៥គីឡូក្រាមរៀងរាល់ពីរខែម្តង ។ បងប្អូនស្រីទាំង២ បច្ចុប្បន្ននេះកំពុងរស់នៅជាមួយគ្នា និងធ្វើការនៅរោងចក្រជាមួយគ្នា ដែលក្នុងរោងចក្រនេះជាការងារដំបូងរបស់កញ្ញា ម៉ាឡៃ ប៉ុន្តែជារោងចក្រទី៣សំរាប់កញ្ញាសុខា។ ពួកគេម្នាក់ៗសុទ្ធតែបានសូកលុយគេ ដើម្បីទទួលបានការងារធ្វើនៅតាមរោងចក្រ ។ បច្ចុប្បន្ននេះ ម៉ាស៊ីនដេរដែលគេបានហាត់រៀន ត្រូវបានយកទៅរក្សាទុកនៅឯផ្ទះភូមិកំណើត ហើយពួកគេទាំងពីរកំពុងទទួលបានចំណូលជាដុល្លារ ក្នុងនាមជាកម្មការិនីរោងចក្រកាត់ដេរ។

ឥឡូវនេះ ដោយសារកូនស្រីទាំងពីរដែលកំពុងរកចំណូលបានពីរោងចក្រ ទើបមានប្រាក់ចំណូលផ្ញើត្រឡប់មកក្រុមគ្រួសារនៅខេត្តព្រៃវែងជាបណ្ដើរវិញហើយ។ អ្នកស្រី ហ៊ួត សុថា បានអះអាងថា គាត់មិនបានទទួលប្រាក់ដែលកូនស្រីទាំងពីររបស់គាត់ផ្ញើមកទៀងទាត់ទេ។ តាមធម្មតា អ្នកស្រីទទួលបានប្រាក់ពីកូនស្រី នៅពេលណាដែលកូនមកលេងផ្ទះក្នុងពេលពួកគេសំរាកពីការងារ ប៉ុន្តែថ្មីៗនេះ អ្នកស្រីទទួលបាន៥០ ដុល្លារពីកូនស្រីទាំង២នាក់ ហើយអំឡុងពេលរាំងស្ងួតកាលពីប៉ុន្មានខែកន្លងមកនេះ កូនស្រីទាំងពីរបានផ្ញើ ៥០ ដុល្លារផងដែរ សំរាប់ទិញសាំងបូមទឹកដាក់ស្រែ។ អ្នកស្រី សុថា បានបន្ថែមទៀតថា ប្រសិនកូនស្រីទាំងពីរធ្វើការលើសម៉ោង ពួកគេនឹងទទួលបានលុយបន្ថែមដើម្បីផ្ញើមកផ្ទះ ប៉ុន្តែបើមិនបានធ្វើការងារលើសម៉ោងទេ មានការលំបាកសំរាប់ពួកគេក្នុងការផ្ញើប្រាក់មកឱ្យពួកយើង។ កញ្ញា ម៉ាឡៃ និង សុខា ទទួលបានបៀវត្សក្នុងម្នាក់ៗចំនួន ៤៥ ដុល្លារ ក្នុង១ខែ ដោយមិនមានការងារថែមម៉ោង ។ ជាមួយគ្នានេះដែរ ពួកគេទាំងពីរនាក់ត្រូវចំណាយ ២៥ ដុល្លារសំរាប់ឈ្នួលបន្ទប់បូកនឹងថ្លៃទឹកភ្លើងចំនួន ៥ ដុល្លារទៀត ។ ពួកគេមិនមានសល់ប្រាក់ច្រើនទេ ក្រោយពេលចំណាយលើថ្លៃអាហារ សំលៀកបំពាក់ និងសំភារៈផ្ទាល់ខ្លួន។

## ការធ្វើស្រែចំការរបស់ក្រុមគ្រួសារ

គ្រួសារលោក ង៉ែត ខេង និង អ្នកស្រី ហ៊ួត សុថា មានផ្ទៃដីស្រែ ១,៧ ហិកតាដែលដល់រដូវប្រមូលផលម្តងៗ ទទួលបានផលស្រូវ ១,៥តោន ឬ ត្រឹមតែ ០,៩តោនក្នុងមួយហិកតា បើការបង្ករបង្កើន ផលនោះមិនត្រូវបានបំផ្លាញដោយគ្រោះរាំងស្ងួត និងទឹកជំនន់ទេនោះ។ កាលពីរដូវប្រមូលផល ២០០៣-២០០៤កន្លងមក ដោយសារគ្រោះរាំងស្ងួត គាត់ប្រមូលផលបានត្រឹមតែ១តោនប៉ុណ្ណោះ ប៉ុន្តែក្នុងរដូវធ្វើស្រែឆ្នាំ ២០០៤-២០០៥ថ្មីៗនេះ គ្រោះរាំងស្ងួតបានធ្វើឱ្យរាំងស្ទះដល់ការដកស្ទូងនាខែកក្កដា ហើយទឹកជំនន់បន្តបន្ទាប់ បានពន្យារដំណើរការនោះបន្តទៅមុខទៀត ។ ពួកគេបានធ្វើការដកស្ទូងនៅក្នុងខែកញ្ញា ហើយមានគំរោងនឹងច្រូតកាត់ នៅខែមករាខាងមុខ។

ទោះបីជាលោក ខេង និងអ្នកស្រី សុថា ព្រមទាំងកូនប្រុស វណ្ណៈ កំពុងធ្វើការដកស្ទូងលើផ្ទៃដីស្រែប្រចាំគ្រួសារក៏ដោយ ក៏ចំណាយលើការធ្វើស្រែមានកំរិតខ្ពស់។ ចំណាយទាំងនោះរួមមាន ចំណាយជួល ម៉ាស៊ីនបូមទឹក សំរាប់ជីគីមី និងថ្នាំសំលាប់សត្វល្អិត ចំណាយជួលអ្នកដកស្ទូង និងច្រូតកាត់ ដើម្បីបញ្ចប់ការងារទាំងនោះអោយទាន់ពេលវេលា និងចំណាយលើការបោកស្រូវថែមទៀត។ លោក ខេង បានប៉ាន់ប្រមាណថា គ្រួសាររបស់គាត់ត្រូវចំណាយ ៧០០,០០០ ទៅ ១ លានរៀល ដើម្បីចំណាយសំរាប់ការធ្វើស្រែក្នុងមួយរដូវ។

ដើម្បីទប់ទល់ទៅនឹងការចំណាយក្នុងការធ្វើស្រែចំការ ក្រុមគ្រួសាររបស់គាត់បានចិញ្ចឹមជ្រូក មាន់ និងទា សំរាប់លក់។ លើសពីនេះ ពួកគាត់ក៏បានទៅស៊ីឈ្នួលធ្វើស្រែចំការដូចជា ដកស្ទូង ច្រូតកាត់ និងភ្ជួររាស់ដោយប្រើគោ

របស់គាត់ដើម្បីបានកំរៃខ្លះ។ តាមធម្មតា ក្រុមគ្រួសាររបស់គាត់ ក៏បានខ្ចីលុយពីអ្នកដ៏ទៃដើម្បីចំណាយលើការធ្វើស្រែចំការដែរ ហើយប្រាក់កំចីនឹងត្រូវបង់ការប្រាក់ប្រមាណ ៣០% នៅពេលប្រមូលផលស្រូវម្តង។

ដូចបានរៀបរាប់រួចមកហើយ ទោះបីជាស្ថិតក្នុងរដូវកាលមិនមានឧបសគ្គក៏ដោយ ក៏ដីស្រែដែលពឹងផ្អែកតែទៅលើទឹកភ្លៀងទទួលបានទិន្នផលត្រឹមតែ ១,៥ តោនស្រូវប៉ុណ្ណោះ។ ចំពោះគ្រួសារទាំងមូលដែលមានសមាជិក ៥នាក់ ក្រុមគ្រួសារត្រូវការទិន្នផលស្រូវ ៣តោនក្នុងមួយឆ្នាំ ។ ប្រសិនបើកូនស្រីទាំង២រស់នៅជុំគ្នាឯផ្ទះវិញនោះ ការធ្វើស្រែនឹងមិនអាចផ្គត់ផ្គង់ជីវភាពរបស់ពួកគេបានទេ ។ ចំពោះប្រាក់ដែល ដែលកូនស្រីទាំងពីរបានផ្ញើមក សំរាប់ទិញស្រូវអង្ករនោះ បានជួយសំរាលបន្ទុកឪពុកម្តាយរបស់ពួកគេបានគួរអោយកត់សំគាល់។ ដូច្នេះ នេះជាការរួមចំណែកយ៉ាងសំខាន់នៃការងារកាត់ដេរសំរាប់ជីវភាពរស់នៅរបស់ក្រុមគ្រួសារនៅតំបន់ជនបទនោះ ។

## ការប្រមើលមើលអនាគតក្នុងគ្រួសារ

លោក ខេង និង អ្នកស្រី សុថា ចង់អោយកូនស្រីទាំងពីរគឺ ម៉ាឡៃ និងសុខា ត្រឡប់មកភូមិកំណើតវិញ និងរៀបការនៅទីនេះ ក្នុងថ្ងៃណាមួយ។ តែពួកគេគិតថាដីស្រែដែលមាន ពុំអាចគ្រប់គ្រាន់សំរាប់ជួយដល់កូនៗទាំងអស់បានទេ និងជាពិសេស នៅពេលពួកគេមានក្រុមគ្រួសាររៀងៗខ្លួន ។ លើសពីនេះទៅទៀត នៅខេត្តព្រៃវែងពុំមានរោងចក្រកាត់ដេរ ឬរោងចក្រធំៗឯទៀតទេ ។ មានសិប្បកម្មធ្វើឥដ្ឋមួយនៅតាមបណ្តោយផ្លូវជាតិ បានជ្រើសរើសអ្នកធ្វើការពីក្នុងភូមិ មួយចំនួនតូចប៉ុណ្ណោះ ។ ឱកាសសំរាប់រកស៊ីឈ្នួលផ្សេងៗទៀតនៅជុំវិញភូមិ ក៏ពុំសូវមាន ។ អ្នកស្រី សុថា បានលើកឡើងថា "បើ ម៉ាឡៃ និងសុខា ត្រឡប់មកភូមិកំណើតវិញ ពួកគេមិនអាចរកចំណូលបានទេ ។ បើនៅធ្វើនៅតាមរោងចក្រ យ៉ាងហោចណាស់ក៏ពួកគេអាចជួយខ្លួនគេបានដែរ " ។ រីឯកូនប្រុសរបស់លោក ខេង និងអ្នកស្រី សុថា ឈ្មោះវណ្ណៈ ក៏បានធ្វើដំណើរទៅភ្នំពេញដើម្បីទៅរកការងារធ្វើតាមរោងចក្រនៅទីនោះដែរ ។ តែមានឱកាសតិចតួចណាស់ សំរាប់បុរសវ័យក្មេង ហើយការសូកលុយចូលក៏ខ្ពស់ថែមទៀត ។ ក្រោយពីធ្វើការនៅរោងចក្រមួយក្នុងរយៈពេលខ្លីបានពីរសប្តាហ៍ វណ្ណៈក៏វិលត្រឡប់មកផ្ទះវិញ ។

សុថា បានធូរចិត្ត ដោយសារកូនស្រីទាំងពីរបានរៀនសូត្រក្នុងកំរិតខ្ពស់ ហើយបានត្រៀមខ្លួនមើលថែទាំខ្លួនឯងក្នុងភាពម្ចាស់ការបាន ។ តែគាត់នៅតែបារម្ភដោយសារកូនស្រីទាំងពីរនាក់ស្ថិតនៅឆ្ងាយ ។ គាត់មិនដឹងថា មិនដឹងជាមានរឿងអ្វីអាចកើតឡើងចំពោះពួកគេទាំងពីរទេ ។ គាត់ក៏ពុំប្រាកដក្នុងចិត្តថា កូនទាំងពីរនឹងវិលមកផ្ទះវិញ ក្នុងកាលៈទេសៈណាដែលរោងចក្របិទទ្វារនោះទេ ។

**ករណីសិក្សាទី ២:**

**គ្រួសាររបស់លោក សុត សេង និង អ្នកស្រី ចាន់ រ៉ាវី**

**នៅភូមិត្នោតច្រុះ ឃុំល្វា**

លោក សុត សេង និងភរិយារបស់គាត់ ចាន់ រ៉ាវី បានរស់នៅក្នុងភូមិត្នោតច្រុះ ឃុំល្វាជារៀងរហូតមក។ បច្ចុប្បន្ននេះ លោក សេង មានអាយុ ៥១ ឆ្នាំ ចំណែកអ្នកស្រី រ៉ាវី មានអាយុ ៤៦ ឆ្នាំ គូស្វាមីភរិយាកសិករពីរនាក់នេះមានកូនប្រាំបីនាក់ កូនច្បងទាំង២បានរៀបការរួចហើយ ហើយរស់នៅចិញ្ចឹមគ្រួសារគេដោយផ្ទាល់ ចំណែកកូន៦នាក់ផ្សេងទៀតកំពុងស្ថិតនៅក្នុងបន្ទុករបស់គាត់នៅឡើយ ។ ចៅស្រីដែលត្រូវជាកូនរបស់កូនប្រុសដែលបានរៀបការហើយមានអាយុមិនដល់មួយឆ្នាំផងនោះ កំពុងតែរស់នៅជាមួយគាត់ ហើយឪពុកម្តាយរបស់ចៅស្រីនោះបានជួយឧបត្ថម្ភប្រាក់ ១០,០០០រៀល ក្នុងមួយខែសំរាប់ផ្គត់ផ្គង់កូនរបស់គេ។

រីឯកូនស្រីរបស់គាត់ដែលបានរៀបការហើយឈ្មោះ សុត ភី អាយុ ២៤ឆ្នាំ បានធ្វើដំណើរទៅភ្នំពេញដើម្បីធ្វើការងារធ្វើតាមរោងចក្រកាត់ដេរកាលពីឆ្នាំ ២០០០ ដែលកាលនោះនាងនៅលីវនៅឡើយ។ នាងបានធ្វើដំណើរទៅធ្វើការជាមួយបងថ្លៃស្រីរបស់នាងដែលជាភរិយានៃបងប្រុសរបស់នាង ។ ដោយសារប្រាក់ខែនាដំណាក់ការដំបូងរបស់នាងទាបពេក ត្រឹមតែ ២០ ដុល្លារ ក្នុងមួយខែ ទើបនាង ភី បានប្តូររោងចក្រណាដែលមានប្រាក់ខែខ្ពស់ជាងនេះ។ កាលនោះ ឪពុកម្តាយនាងបានផ្គត់ផ្គង់នាងនូវអង្ករ១៥គីឡូក្រាមក្នុងមួយខែដើម្បីផ្តល់បន្ថែមលើចំណូលរបស់នាង។ កាលពីឆ្នាំ ២០០១ នាង ភី បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នករត់ម៉ូតូឌុបដែលមានស្រុកកំណើតនៅខេត្តកំពង់ចាម ហើយបច្ចុប្បន្ននេះកំពុងធ្វើការនៅនៅភ្នំពេញ ។ នៅពេលនាងបានរៀបការរួច ឪពុកម្តាយនាងមិនបានផ្តល់អង្ករដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារផ្ទាល់របស់នាងនៅទីក្រុងភ្នំពេញទៀតទេ ។ បច្ចុប្បន្ននេះ នាងភី នៅធ្វើការនៅក្នុងរោងចក្រនៅឡើយ ហើយបានប្រាក់ខែ ៤០ ដុល្លារក្នុងមួយខែ ។ ប្រាក់ចំណូលនេះគឺសំរាប់ជួយទ្រទ្រង់គ្រួសាររបស់នាងនៅភ្នំពេលដែលមានកូនក្នុងបន្ទុកចំនួន២នាក់ទៀត។ ជាច្រើនឆ្នាំមកហើយដែលនាង ភី បានធ្វើការនៅរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញ ប៉ុន្តែ នាងមិនដែលបានផ្ញើលុយកាក់ទៅជូនឪពុកម្តាយរបស់នាងនៅឯផ្ទះទេ។

លោក សុត សេង និងអ្នកស្រី ចាន់ រ៉ាវី ក៏មានកូនស្រីនៅលីវម្នាក់ឈ្មោះ សុត សាវី អាយុ ២២ ឆ្នាំ កំពុងធ្វើការនៅរោងចក្រកាត់ដេរដែរ។ កញ្ញា សាវី បានចេញពីភូមិរយៈពេល៥ខែហើយ បន្ទាប់ពីបុណ្យចូលឆ្នាំខ្មែរ ដោយឪពុករបស់នាងបានជូនដំណើរមកដល់ភ្នំពេញ ។ ហើយបច្ចុប្បន្ននេះ នាងរស់នៅជាមួយនឹងបងប្អូនជីដូនមួយរបស់នាងដែលមកពីភូមិជាមួយគ្នា។ ដូចបងស្រីច្បងរបស់នាងដែរ សាវី មិនបានសូកលុយដើម្បីទទួលបានការងារធ្វើទេ ។ សាវី អាចរកលុយបានគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ខ្លួននាង ហើយមិនបានទទួលអង្ករពីឪពុកម្តាយនាងទេ។ បើទោះថានាងបានចាយវាយច្រើនសំរាប់ការរស់នៅរបស់នាង ក៏នាងនៅតែអាចចាត់ចែងផ្ញើប្រាក់២០,០០០រៀល(៥ ដុល្លារ)

ក្នុងមួយខែទៅដល់ក្រុមគ្រួសារនៅខេត្តព្រៃវែងដែរ។ ម្តាយរបស់ សារីបាននិយាយថា សារី មិនអាចជួយរកចំណូលបានក្នុងការងារធ្វើស្រែដោយសារទឹកជំនន់នាថ្មី១នេះ ទើបនាងបានសំរេចចិត្តសុំការអនុញ្ញាតិពីឪពុកម្តាយរបស់នាងដើម្បីចេញទៅធ្វើការនៅភ្នំពេញ។

## ការធ្វើផ្សែចំការរបស់ក្រុមគ្រួសារ

គ្រួសាររបស់អ្នកទាំងពីរមានដីកម្មសិទ្ធិចំនួន ១.៥ហិកតាដែលក្នុងនោះដីស្រែមាន១ហិកតាស្ថិតនៅក្បែរភូមិ និងដីកន្លះហិកតាទៀតនៅជិតស្ទឹង។ ផ្ទៃដីទាំងនេះ ត្រូវបានគេបែងចែកអោយទៅឱ្យគ្រួសារនេះដែលមានកូនពីរនាក់នៅរស់ជាមួយក្នុងសម័យដែលមានការបែងចែកដីស្រែតាមក្រុមសាមគ្គីកាលពីដើមទសវត្សឆ្នាំ ១៩៨០។ ដីមួយហិកតា ស្ថិតក្នុងតំបន់ដែលរងគ្រោះរាំងស្ងួត ទើបក្រុមគ្រួសារមិនអាចប្រមូលផលស្រូវនៅលើផ្ទៃដីនេះបាន តាំងពីឆ្នាំ ២០០០មកម្ល៉េះ។ ការពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ដីស្រែនេះត្រូវបានគេធ្វើការដកស្ទូងនៅខែកក្កដាគឺចំពេលដែលមានភ្លៀងធ្លាក់ខ្លាំង។ បើប្រៀបធៀបនឹងផ្ទៃដីកន្លះហិកតាដែលនៅជិតដៃទន្លេមេគង្គ ដីនេះស្រោចស្រប់ដោយការបូមទឹកបញ្ចូលបាននាចុងរដូវ។ ទោះជាយ៉ាងណាក្តី កាលពី៤ឆ្នាំកន្លងទៅ ២០០០-២០០៤ ទឹកជំនន់បានឡើងមក ក្រោយពីមានគ្រោះរាំងស្ងួតបានបំផ្លាញសំណាប ហើយបានខូចទិន្នផលស្រូវនៅលើផ្ទៃដីស្រែដ៏តូចនេះ។ កាលពីរដូវធ្វើស្រែឆ្នាំ ២០០៤-២០០៥ នេះ ក្រុមគ្រួសារបានធ្វើការដកស្ទូងរួចរាល់ជាស្ថាពរលើផ្ទៃដីកន្លះហិកតា ហើយទឹកជំនន់ចាប់ផ្តើមស្រកចុះជាបណ្តើរ១ហើយ ដូច្នេះ សុត សេង និង ចាន់ រារី មិនគិតថា ខ្លួននឹងប្រឈមនឹងផលវិបាកនាពេលខាងមុខឡើយ។

លោក សុត សេង បានប៉ាន់ប្រមាណថា គ្រួសារគាត់ត្រូវការស្រូវ ៣តោនកន្លះ (ឬ៣.៥០០គីឡូក្រាម) ដើម្បីឆ្លើយតបនឹងតំរូវការប្រើប្រាស់ស្រូវប្រចាំឆ្នាំរបស់គ្រួសារ។ តាមធម្មតា គ្រួសារគាត់ទទួលបានផលស្រូពី ៥០០ ទៅ ៦០០ គីឡូក្រាមនៅលើផ្ទៃដីកន្លះហិកតា សំរាប់រដូវកាលប្រមូលផលនីមួយ១។ ជាភ័ព្វសំណាង អង្គការប៉ាដិកបានផ្តល់ម៉ាស៊ីនបូមទឹកសំរាប់ឃុំទាំងមូល ធ្វើអោយក្រុមគ្រួសាររបស់គាត់ មានលទ្ធភាពបូមទឹកស្រោចស្រប់សំរាប់ធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ ដែលលើកទីមួយគឺចាប់ពីខែមីនា-សីហា និងលើកទីពីរចាប់ពីខែ សីហា-មករា ។ ប៉ុន្តែដោយសារមិនទទួលបានទិន្នផលលើផ្ទៃដីជាងមួយហិកតាដែលស្រោចស្រប់ដោយទឹកភ្លៀងនោះ ទើបធ្វើអោយគ្រួសារនេះ មិនអាចមានស្បៀងគ្រប់គ្រាន់ពីទិន្នផលស្រូវដែលបានពីដីស្រែកន្លះហិកតានោះទេ ។ ដើម្បីបំពេញការខ្វះខាតនេះ ក្នុងឆ្នាំ ២០០២ លោក សុត សេង បានចាប់ផ្តើមជួលដីគេ ០.៧ហិកតា នៅជិតប្រភពទឹកទន្លេដែលជាប់នឹងភូមិធំ។ ដោយសារតែដីជួលនេះ ស្ថិតនៅជិតប្រភពទឹកគ្រប់គ្រាន់ ដូច្នេះជាធម្មតា គ្រួសារអាចប្រមូលផលស្រូវ ១.០០០ គីឡូក្រាមក្នុងមួយលើក១នៃការធ្វើស្រែពីរដងក្នុងមួយឆ្នាំរបស់គាត់ ។ ទិន្នផលនេះបានជួយបំពេញនូវតំរូវការក្នុងគ្រួសារបានច្រើន ទោះបីគាត់នៅតែជួនប្រទះនឹងការខ្វះខាតក៏ដោយ។

ទន្ទឹមនឹងនេះដែរ ក្រុមគ្រួសារបានចំណាយច្រើនសំរាប់ការធ្វើស្រែម្តងៗ ។ ការចំណាយទាំងនេះរួមមាន ថ្លៃឈ្នួល ១២០ គីឡូក្រាមសំរាប់ដីជួល ០,៧ហិកតា ក្នុងរដូវកាលប្រមូលផលមួយលើកៗ ចំណាយលើប្រេងសាំងបូមទឹកប្រហែល២០០,០០០រៀលក្នុងមួយលើកៗ និងចំណាយលើជីគីមីប្រហែល ១០០,០០០រៀល សំរាប់រដូវកាលប្រមូលផលនីមួយៗ។ មុនឆ្នាំ ២០០០ លោក សុត សេង និងអ្នកស្រី ចាន់ រ៉ាវី បានជួលកំលាំងពលកម្មដើម្បីធ្វើស្រែ បច្ចុប្បន្ននេះ សមាជិកគ្រួសារបានធ្វើការដកស្ទូងដោយខ្លួនឯងវិញ ។ ដើម្បីអោយបានប្រាក់កាសសំរាប់យកទៅចំណាយក្នុងការធ្វើស្រែម្តង ក្រុមគ្រួសារក៏បានចិញ្ចឹមជ្រូក មាន់ និងទាសំរាប់លក់ផងដែរ។

## ការប្រមើលមើលអនាគតក្នុងគ្រួសារ

ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ ចាន់ រ៉ាវី បានជួយរកប្រាក់ចំណូលសំរាប់ក្រុមគ្រួសារដោយការផលិត និងលក់ស្រាស ។ ពីដំបូង គាត់បានប្រើប្រាស់ស្រូវដែលធ្វើបានពីដីស្រែផ្ទាល់ខ្លួនដើម្បីផលិតស្រា បន្ទាប់មកទិញអង្ករពីផ្សារ នៅពេលគាត់បានចំណូលពីការលក់ស្រា ។ ពេលបច្ចុប្បន្ននេះ ថ្លៃស្រូវមានតំលៃខ្ពស់ ដូច្នេះគាត់ត្រូវរង់ចាំរហូតដល់ការប្រមូលផលរួច ទើបគាត់ចាប់ផ្តើមបិតស្រាជាថ្មី ។ សមាជិកគ្រួសារធ្វើកញ្ច្រែងឬស្សីសំរាប់លក់ទៅឱ្យអ្នកភូមិផ្សេងៗ។ កាលពីមុន គ្រួសារនេះមានគោច្រើនក្បាល ប៉ុន្តែពួកគាត់បានលក់សត្វទាំងនោះ ដោយសារទឹកជំនន់ជាប់ៗគ្នា។ សមាជិកគ្រួសារក៏បានជួយរកកំរៃ តាំងពីនៅក្បែរៗភូមិ រហូតដល់ទៅធ្វើការនៅភ្នំពេញ ប៉ុន្តែពេលខ្លះ មានឱកាសតិចតួចណាស់ ។ សុត វុទ្ធី អាយុ ២០ឆ្នាំ ត្រូវជាកូនប្រុសរបស់លោក សេង និង អ្នកស្រី រ៉ាវី បានធ្វើការងាររយៈពេលបីខែនៅរោងចក្រក្រដាសមួយនាទីក្រុងភ្នំពេញ បន្ទាប់មក បានវិលត្រឡប់មកកាន់ផ្ទះវិញ ហើយមានការងារខ្លះៗដែលត្រូវធ្វើបន្ថែម។ ឧសគ្គមួយទៀតដែលគ្រួសារនេះត្រូវជួបប្រទះដែរនោះគឺ គាត់មិនទាន់ដឹងច្បាស់ថា នៅពេលណាដីស្រែដែលបានជួលប្រមាណ ០,៧ហិកតា នឹងត្រូវបានម្ចាស់គេយកវិញ ព្រោះម្ចាស់ដីបច្ចុប្បន្ននេះ ធ្វើការនៅមុំទីប្រជុំជនអ្នកលឿង។

សេង និង រ៉ាវី បានទទួលស្គាល់ថា កូនស្រីរបស់គាត់ឈ្មោះ សុត សាវី អាយុ ២២ ឆ្នាំ បានប្រឈមមុខនឹងឧបសគ្គមួយក្នុងការធ្វើការងារនៅរោងចក្រនៅភ្នំពេញ និងផ្គត់ផ្គង់ជីវភាពដោយខ្លួននាងនៅភ្នំពេញ។ ទោះជាយ៉ាងណាក្តី ពួកគេមានភាពកក់ក្តៅ ពីព្រោះបងស្រី២នាក់របស់នាងដែលបានរៀបការហើយ រស់នៅជិតនាងនៅនឹងទីក្រុងស្រាប់នោះ អាចជួយនាងនៅពេលមានធុរៈសំខាន់ ។ គូស្វាមីភរិយានេះ មានអារម្មណ៍ថា សាវី នឹងបន្តស្នាក់នៅធ្វើការនាទីក្រុងភ្នំពេញយូរឬឆាប់ អាស្រ័យលើការងារដែលនាងមាន ។ តែបើនាងសំរេចចិត្តត្រឡប់មកកាន់ស្រុកកំណើតវិញនោះ ឳពុកម្តាយនាងបានសន្យាថា នឹងទទួលខុសត្រូវ និងស្វែងរកវិធីជួយនាង។

**ករណីសិក្សាទី ៣៖**

**គ្រួសាររបស់លោក ព្រុំ សុខ និង អ្នកស្រី កែវ ចរិយា**

**ភូមិព្រីង ឃុំក្រាំងស្វាយ**

លោក ព្រុំ សុខ និងភរិយារបស់គាត់ កែវ ចរិយា កំពុងរស់នៅក្នុងភូមិ ព្រីង ឃុំក្រាំងស្វាយ។ បច្ចុប្បន្ននេះ លោក សុខ មានអាយុ ៤៧ ឆ្នាំ ចំណែកអ្នកស្រី ចរិយា មានអាយុ ៤៥ ឆ្នាំ គូស្វាមីភរិយានេះមានកូន ៧នាក់។ កូនស្រីច្បងរបស់គាត់ឈ្មោះ ព្រុំ សេដ្ឋា បានរៀបការរួចហើយ និងរស់នៅជាមួយស្វាមីនិងកូនរបស់នាង នៅកំពង់ចម្លងអ្នកលឿង ។ មុនពេលនាងរៀបការ សេដ្ឋា ធ្លាប់ធ្វើការនៅរោងពុម្ពនាទីក្រុងភ្នំពេញ ។ រៀងរាល់ខែ ឬពីរខែម្តង នាងមានលទ្ធភាពផ្ញើប្រាក់ខ្លះមកឱ្យឪពុកម្តាយនៅភូមិកំណើត។ តែឥឡូវនេះ ទោះជានាងមិនមានការងារធ្វើនៅទីក្រុងភ្នំពេញក៏ដោយ សេដ្ឋា បានជូនឪពុកម្តាយនាង ២០,០០០ ឬ ៣០,០០០ រៀល (៥-៧.៥ ដុល្លារ) រៀងរាល់ ២ឬ៣ខែម្តង។ នាងនៅតែមានលទ្ធភាពធ្វើដូច្នេះ ពីព្រោះនាងមានស្វាមីធ្វើការជាសន្តិសុខនៅច្រកព្រំដែនថៃ នៅឃុំប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

លោក សុខ និងអ្នកស្រី ចរិយា ក៏មានកូនស្រីនៅលីវម្នាក់ឈ្មោះ ព្រុំ សុផានី អាយុ ២១ ឆ្នាំ ។ សុផានី ត្រូវបានគេជ្រើសរើសឱ្យធ្វើការងារនៅរោងចក្រកាត់ដេរមួយនៅទីក្រុងភ្នំពេញរយៈពេល៣ឆ្នាំកន្លងមកហើយ ។ នៅគ្រាដំបូង នាងបានចាកចេញពីភូមិកំណើតមកភ្នំពេញជាមួយអ្នកជិតខាង ដោយមិនទាន់មានការងារជាក់លាក់ណាមួយសំរាប់នាងធ្វើនៅឡើយ ។ ឪពុកម្តាយនាងឧបត្ថម្ភនាងនូវអង្ករ និងប្រាក់ ១០,០០០រៀល សំរាប់ការធ្វើដំណើរ និងចំណាយផ្សេងៗ។ ពីរសប្តាហ៍ក្រោយមក នាងរកការងារបានធ្វើនៅរោងចក្រកាត់ដេរ មួយកន្លែងដែលស្ថិតនៅកន្លែងធ្វើការរបស់អ្នកជិតខាងដែលបាននាំនាងមកភ្នំពេញនោះដែរ ។ មុននឹងបានចូលធ្វើការងារនេះ គេតម្រូវអោយនាងសូកលុយរត់ការចំនួន៤០ដុល្លារ ហើយដើម្បីបានប្រាក់នេះសំរាប់កូន លោក សុខ បានខ្ចីពីអ្នកចងការប្រាក់នៅក្នុងភូមិម្នាក់ដោយមានការប្រាក់ ២,៥០ ដុល្លារ ក្នុងមួយខែ។ លុះបាន ៦ខែក្រោយមក លុយដែលបានខ្ចីនេះត្រូវបានសងរួចអស់ ដោយសារប្រាក់ខែរបស់សុផានីខ្លះ និងប្រាក់ចំណូលរបស់ឪពុករបស់នាងខ្លះ ។ លោក សុខ បាននិយាយក្នុងទឹកចិត្តអាលោះអាល័យថា គាត់បានព្រមឱ្យកូនស្រីទៅបំរើការនៅទីក្រុងភ្នំពេញ ពីព្រោះតែខ្លួនគាត់មិនអាចទ្រទ្រង់ជីវភាពប្រចាំគ្រួសារបាន។

## ការធ្វើផែស្រចំការរបស់ក្រុមគ្រួសារ

លោកព្រុំ សុខ និងអ្នកស្រី កែវ ចរិយា មានដីស្រែដែលពឹងផ្អែកលើទឹកភ្លៀងចំនួន២ហិកតានៅក្នុងភូមិដែលអាចបង្កបង្កើនផលបានតែម្តងគត់ក្នុងមួយឆ្នាំ ។ កាលពីប៉ុន្មានឆ្នាំកន្លងមកនេះ ដីស្រែនេះបានទទួលរងភាពរាំងស្ងួត និងទឹកជំនន់ដែលធ្វើឱ្យទិន្នផលស្រូវមានការថយចុះ។ បើមានការប្រើប្រាស់ជី លោក សុខ អាចប្រមូលផលស្រូវបាន ១,២០០ គីឡូក្រាមលើផ្ទៃដីទាំង២ហិកតា ឬមួយហិកតាទទួលបាន ៦០០ គីឡូក្រាមប៉ុណ្ណោះ។ ផ្ទុយទៅវិញបើគាត់មិនប្រើជីវិញ នោះផលស្រូវដែលទទួលបានគឺត្រឹមតែ ៩៦០គីឡូក្រាមតែប៉ុណ្ណោះ ឬស្មើនឹង ៤៨០គីឡូក្រាមក្នុងមួយហិកតា។ ជីគីមីមានតំលៃខ្ពស់ តាមធម្មតា លោក សុខ ត្រូវទិញបណ្តាក់ដោយគិតការប្រាក់ ១០,០០០រៀល (២.៥០ដុល្លារ) ក្នុង១ខែ។ នៅពេលមានទិន្នផលស្រូវទាប ពេលខ្លះគាត់ត្រូវតែលក់ជ្រូកដើម្បីសងបំណុលគេ។ ដើម្បីកាត់បន្ថយទៅនឹងការចំណាយក្នុងការធ្វើស្រែ សមាជិកគ្រួសារទាំងមូលត្រូវធ្វើការភ្ជួររាស់ និងដកស្ទូងដោយខ្លួនឯង ហើយនៅពេលច្រូតកាត់ប្រមូលផល ពួកគាត់ប្រវាស់ដៃជាមួយអ្នកជិតខាង។

នៅរដូវប្រាំង ជូនកាល លោក ព្រុំ សុខ ទៅភ្នំពេញធ្វើការជាកម្មសំណង់មួយខែឬច្រើនខែ ហើយគាត់ស្នាក់នៅក្នុងការដ្ឋានសំណង់ និងប្រើប្រាស់លុយដែលគាត់រកបានមួយថ្ងៃ ៥,០០០រៀល (១.២៥ដុល្លារ) ដើម្បីទិញម្ហូប។ ចំណែកឯ អ្នកស្រី កែវ ចរិយា វិញ ស៊ីឈ្នួលធ្វើស្រែឱ្យគេនៅជិតភូមិ ដើម្បីបំពេញការខ្វះខាតក្នុងក្រុមគ្រួសារ។ មុនពេល សុផានី ចាកចេញទៅធ្វើការនៅរោងចក្រកាត់ដេរ នាងក៏ស៊ីឈ្នួលដកស្ទូងច្រូតកាត់ដូចម្តាយនាងដែរ។

## ប្រាក់ធ្វើឧបត្ថម្ភដល់ក្រុមគ្រួសារពីរោងចក្រកាត់ដេរ

លោក ព្រុំ សុខ បានបន្តទៀតថា គាត់ដឹងមិនច្បាស់ទេថា តើកូនស្រីគាត់ សុផានី ទទួលបានកំរៃប៉ុន្មានពីរោងចក្រទេ ប៉ុន្តែគាត់គិតថា នាងអាចរកបានតិចបំផុត ៧០ដុល្លារដែរក្នុងមួយខែ។ រៀងរាល់២ ឬ ៣ ខែម្តង នាងបានផ្តល់ឱ្យឪពុកម្តាយពី ៣០-៤០ ដុល្លារ ។ តាមធម្មតា សុផានី តែងយកប្រាក់ទៅជូនឪពុកម្តាយ នៅពេលនាងទៅលេងស្រុកកំណើត ប៉ុន្តែករណីនាងជាប់រវល់ ឪពុកនាងនឹងមកទទួលប្រាក់នៅភ្នំពេញ។ លោក ព្រុំ សុខ បានទទួលស្គាល់ថា បើគ្មានការផ្ញើប្រាក់ឧបត្ថម្ភពីកូនស្រីគាត់ទេ គ្រួសារគាត់នឹងមិនមានប្រាក់គ្រប់គ្រាន់ ដើម្បីទិញម្ហូបអាហារបានទេ ។ ពួកគាត់ប្រើលុយដែលផ្ញើនោះ ទិញអង្ករ និង ប្រហុក ហើយក៏បានទិញកូនជ្រូកដែរ តែច្រើនងាប់ទៅវិញ។ នៅពេលដែលសួរគាត់ថា តើនឹងមានអ្វីកើតឡើងសំរាប់គ្រួសារទាំងមូល បើសុផានីត្រូវរៀបការ លោក ព្រុំ សុខ មិនមានចំលើយសោះឡើយ។

## ករណីសិក្សាទី ៤:
## គ្រួសាររបស់លោក ទុន ទូច និង អ្នកស្រី ចេក សុគន្ធា
## ភូមិព្រីង ឃុំក្រាំងស្វាយ

លោក ទុន ទូច មានអាយុ ៥៥ ឆ្នាំ ជាប្រធានភូមិនៃភូមិព្រីង ឃុំក្រាំងស្វាយ និង ភរិយារបស់គាត់ អ្នកស្រី ចេក សុគន្ធា មានអាយុ ៥៤ ឆ្នាំ ។ គូស្វាមីភរិយានេះមានកូន ៧នាក់ ប្រុស៤នាក់ ស្រី៣នាក់ ដែលមានអាយុចន្លោះពី ១៥-៣៤ឆ្នាំ ។ កូន៤នាក់បានរៀបការហើយ កូន៣នាក់ទៀតនៅលីវ។ កូនច្បង២នាក់រស់នៅផ្ទះដាច់ដោយឡែក នៅក្នុងភូមិជាមួយប្ដីប្រពន្ធនិងកូន១របស់ពួកគេ រីឯកូន៥នាក់ទៀត ដែល២នាក់រៀបការហើយ កំពុងតែរស់នៅក្នុងដំបូលផ្ទះជាមួយគាត់ទាំងពីរនាក់។ មានតែកូនម្នាក់គត់ដែលរស់នៅក្រៅភូមិ។ ទាក់ទងទៅនឹងការប្រែប្រួលក្នុងទម្លាប់ប្រពៃណីខ្មែរដែលស្ត្រីមិនទៅណាឆ្ងាយពីផ្ទះនោះ ពេលនេះគាត់មានកូនស្រីរបស់គាត់ឈ្មោះ ទុន ខេម៉ារី អាយុ ១៨ ឆ្នាំ នៅលីវ បានចេញទៅឆ្ងាយ ហើយកំពុងតែធ្វើការងារនៅរោងចក្រកាត់ដេរមួយ នាទីក្រុងភ្នំពេញ។

នាង ខេម៉ារី បានធ្វើចំណាកស្រុកទៅទីក្រុងភ្នំពេញ៩ខែកន្លងទៅនេះ ដោយទៅជាមួយបងប្អូនស្រីរបស់នាងម្នាក់ មានអាយុ២១ឆ្នាំមកពីភូមិជាមួយគ្នា។ ឪពុកម្ដាយនាងបានឱ្យប្រាក់នាង ៥០,០០០រៀលសំរាប់ការធ្វើដំណើរ និងចំណាយផ្សេងៗពេលនាងចាកចេញពីផ្ទះ។ នាងបានស្នាក់នៅផ្ទះជាមួយសាច់ញាតិរបស់នាង។ មួយខែក្រោយមក នាង ខេម៉ារី រកការងារបានធ្វើនៅរោងចក្រមួយដែលសាច់ញាតិនាងក៏ធ្វើការនៅទីនោះដែរ នាងមិនបានសូកលុយសំរាប់ការចូលធ្វើការឡើយ។ ម្ដាយរបស់នាងបានធ្វើការកត់សំគាល់ថា "ខេម៉ារី មានការអន្ទះសារចង់ទៅភ្នំពេញ ពីព្រោះថា មិនមានការងារនៅក្នុងភូមិសំរាប់នាងធ្វើឡើយ ក្រៅពីការងារធ្វើស្រែចំការ ។ នាងទើបតែបានបញ្ចប់ការសិក្សាថ្នាក់ទី៨ ប៉ុន្តែចង់ជួយរកចំណូលសំរាប់គ្រួសារទាំងមូល។"

## ការធ្វើស្រែចំការរបស់ក្រុមគ្រួសារ

គ្រួសារនេះមានដីស្រែដែលពឹងផ្អែកលើទឹកភ្លៀងចំនួន៣ហិកតានៅក្នុងភូមិ ប៉ុន្តែគាត់បានបែងចែក ១ហិកតាកន្លះដល់កូនគាត់៤នាក់ដែលរៀបការហើយ គ្រួសារនេះនៅសល់ដីត្រឹមតែ១ហិកតាកន្លះប៉ុណ្ណោះសំរាប់បង្កបង្កើនផល។ កាលពីប៉ុន្មានឆ្នាំកន្លងមកនេះ គ្រួសារនេះអាចប្រមូលផលបាន ២,៤០០គីឡូក្រាម ឬ ១,៦តោន ក្នុងមួយហិកតា នារដូវកាលច្រូតកាត់ម្ដងៗ ។ ប៉ុន្តែនៅប៉ុន្មានឆ្នាំកន្លងមកនេះ គ្រោះរាំងស្ងួត និងទឹកជំនន់បាន បំផ្លាញទិន្នផលស្រូវអស់។ កាលពីឆ្នាំ ២០០០ និង ២០០១ ទឹកជំនន់បានបន្ថយទិន្នផលស្រូវលើផ្ទៃដីនេះ មកនៅត្រឹមតែ ៩៦០ គីឡូក្រាម ឬ ០,៦៤តោនក្នុង១ហិកតា ។ រីឯឆ្នាំ ២០០២ និង ២០០៣ ដោយសារគ្រោះរាំងស្ងួត ទិន្នផលស្រូវបានត្រឹមតែ ១,៥៦០គីឡូក្រាម ឬ ១,០៤តោនក្នុង១ហិកតា។ នេះបញ្ជាក់ឱ្យឃើញថា ក្នុងរយៈពេល ៤ឆ្នាំជាប់ៗគ្នាកន្លងទៅនេះ គ្រួសារនេះត្រូវទិញស្រូវបន្ថែមទៀតដើម្បីបង្គ្រប់ការខ្វះខាត ព្រោះថា តម្រូវការស្រូវដើម្បីផ្គត់ផ្គង់គ្រួសារគឺ ២,៤០០គីឡូក្រាមក្នុងមួយឆ្នាំ។

នៅឆ្នាំ២០០៤ ភ្លៀងធ្លាក់មកយឺត ពួកគាត់បានពន្យារពេលស្ទូងពីខែកក្កដាទៅខែកញ្ញា និងមានគំរោងច្រូតកាត់ប្រមូលផលនៅខែធ្នូ ឬខែមករា ។ លោក ទូច បានប្រើជីគីមី ប៉ុន្តែមិនបានប្រើថ្នាំសំលាប់សត្វល្អិតទេ ។ កាលពីឆ្នាំ ២០០៤ គ្រួសារនេះបានលក់កូនជ្រូក២ក្បាលដើម្បីទិញជី២ការុង សំរាប់ដាក់ស្រែ ។ ក្រៅពីការធ្វើស្រែចំការ លោក ទូច បានទទួលប្រាក់ឧបត្ថម្ភ ២០,០០០រៀលក្នុងមួយខែក្នុងឋានៈគាត់ជាប្រធានភូមិ ហើយចំណូលនេះបានជួយរួមចំណែកការខ្វះខាតក្នុងគ្រួសារ ។

## ប្រាក់ផ្ញើឧបត្ថម្ភដល់ក្រុមគ្រួសារពីរោងចក្រកាត់ដេរ

នាង ទុន ខេម៉ារី រកចំណូលបាន ៤០ដុល្លារក្នុងមួយខែ ពីការងាររោងចក្រកាត់ដេរនៅភ្នំពេញ ។ បើធ្វើការថែមម៉ោង នាងនឹងទទួលបាន ៥០ ដុល្លារក្នុងមួយខែ។ នាងទៅលេងស្រុកកំណើតរៀងរាល់២ខែម្តង ហើយតាមធម្មតាបានជូនប្រាក់ទៅអោយម្តាយនាង ២០ ដុល្លារក្នុងមួយខែ ទោះជាយ៉ាងណាក៏ដោយ នៅពេលខ្លះ នាងបានជូនម្តាយត្រឹមតែ ១០ ដុល្លារប៉ុណ្ណោះក្នុងមួយខែ។ អ្នកស្រី សុគន្ធា បានប្រើប្រាស់ ប្រាក់ដែលកូនផ្ញើមកសំរាប់ទិញថ្នាំប៉ុណ្ណោះ ដោយសារអ្នកស្រីមានជំងឺប្រចាំកាយ ហើយត្រូវចំណាយពី ៨០,០០០-៩០,០០០រៀល (២០-២២.៥ដុល្លារ) ក្នុងមួយខែដើម្បីទិញថ្នាំ ។ លោកស្រីទិញថ្នាំនៅគ្លីនិកសុខភាព ហើយបង់ឱ្យគេនៅពេលណា ដែលលោកស្រីបានទទួលប្រាក់ដែលកូនស្រីផ្ញើមក។

លោកស្រី សុគន្ធា មានការព្រួយបារម្ភពីកូនស្រីរបស់គាត់ ព្រោះថាមុនពេលធ្វើចំណាកស្រុកទៅភ្នំពេញ កញ្ញា ខេម៉ារី មិនដែលទៅណាក្រៅពីទៅសាលារៀនឡើយ ។ នាងគឺជាក្មេងស្រីដែលរស់នៅ និងធ្វើការនៅឆ្ងាយ ហើយម្តាយរបស់នាងមិនបានដឹងទេថា តើនឹងមានអ្វីកើតឡើងចំពោះរូបនាង ។ ប៉ុន្តែ តើមានជំរើសអ្វីក្រៅពីនេះ? បើម្តាយ នាងចង់អោយនាងនៅក្នុងភូមិ នោះគ្រួសារនឹងប្រឈមមុខនឹងវិបត្តិហិរញ្ញវត្ថុមិនខានឡើយ។ លោកស្រីនិយាយថា "គាត់ពេញចិត្តនឹងឱ្យកូនស្នាក់នៅធ្វើការឯភ្នំពេញ បើការងារនៅតែមានបន្តទៀត ប៉ុន្តែបើនាងមិនមានការងារធ្វើទេ ខ្ញុំចង់ឱ្យនាងត្រឡប់មកផ្ទះវិញ ពីព្រោះខ្ញុំមិនចង់ឱ្យនាងរៀបការជាមួយបុរសមកពីទីឆ្ងាយទេ។"

**ការសិក្សាលើករណីទី ៥:**

**គ្រួសាររបស់លោក សៅ សំផន និង អ្នកស្រី ខាន់ សត្ថា**

**ភូមិពានី ឃុំល្វា**

លោក សៅ សំផន អាយុ ៦៩ឆ្នាំ ជាប្រធានភូមិពានី ចំណែកភរិយារបស់គាត់ឈ្មោះ ខាន់ សត្ថា អាយុ ៦៨ ឆ្នាំ គ្រួសារនេះមានកូន ៦នាក់ ដែលមានអាយុចាប់ពី ២៥ ដល់ ៤៤ ឆ្នាំ ។ កូនស្រីច្បងបង្អស់នៅលីវ កំពុងរស់នៅជាមួយឪពុកម្តាយ ព្រមទាំងមានចៅ២នាក់ទៀតរស់នៅជាមួយ ចៅស្រីអាយុ១០ឆ្នាំ និងចៅប្រុសអាយុ៧ឆ្នាំ។ ចៅទាំងពីរនេះគឺជាកូនរបស់កូនស្រីរបស់គាត់ម្នាក់ទៀត ឈ្មោះ សៅ សុភី អាយុ ២៧ឆ្នាំ រស់នៅជាមួយប្តី នៅភ្នំពេញ និងធ្វើការនៅរោងចក្រកាត់ដេរ។

សុភី បានជួបប្តីនាងដែលមានដើមកំណើតនៅខេត្តកំពង់ឆ្នាំង នៅពេលនាងបានទៅលេងផ្ទះម្តាយមីងនៅភ្នំពេញ។ ប្តីប្រពន្ធវ័យក្មេងនេះបានរៀបការនៅភូមិពានី បន្ទាប់មកបានត្រឡប់ទៅទីក្រុងវិញស្នាក់នៅកន្លែងដែលប្តីនាងកំពុងធ្វើការសំណង់ ។ សុភី សំរាលកូនទាំងពីរនៅភូមិពានី ហើយត្រឡប់ទៅភ្នំពេញវិញ ដោយទុកកូនទាំងពីរ អោយម្តាយនាងមើលថែទាំនៅឯភូមិកំណើត ។ នៅគ្រាដំបូង សុភី បានជួយរកចំណូលបន្ថែមពីលើចំណូលរបស់ប្តីនាងដោយការទិញលក់បន្លែនៅភ្នំពេញ លុះបីឆ្នាំក្រោយមក នាងរកការងារបានធ្វើនៅរោងចក្រកាត់ដេរដែលនាងទទួលបានប្រាក់ខែ ៤០ដុល្លារ និង ៦០ដុល្លារក្នុងមួយខែ ករណីធ្វើការថែមម៉ោង។ ទន្ទឹមនឹងនេះដែរ ប្តីនាងអាចរកចំណូលបាន ១៦០,០០០-២០០,០០០ រៀល (៤០-៥០ដុល្លារ) ក្នុងមួយខែពីការងារសំណង់។ លោក សៅ សំផន បានបញ្ជាក់ថា សុភី និងប្តីរបស់នាង បានផ្តល់លុយឱ្យពួកគាត់មួយខែពី១០-១៥ដុល្លារសំរាប់ផ្គត់ផ្គង់កូនរបស់គេទាំងពីរនាក់។

ក្រៅពីសុភី លោក សំផន និងអ្នកស្រី សត្ថា មានកូនដែលរៀបការហើយ៣នាក់ទៀតកំពុងរស់នៅ និងធ្វើការនៅឯទីក្រុងភ្នំពេញ។ សៅ ស៊ីលាត អាយុ ៣៧ឆ្នាំ កូនប្រុសរបស់គាត់កំពុងធ្វើការងារសំណង់ បានផ្តល់ឱ្យឪពុកម្តាយពី២០,០០០-៣០,០០០៛ (៥-៧.៥ដុល្លារ) រៀងរាល់២-៣ខែម្តង នៅពេលដែលគាត់មកលេងស្រុកកំណើត ។ ចំណែក សៅ ផល្លី ជាកូនស្រីរបស់គាត់អាយុ៣៣ឆ្នាំ និងប្តីនាងក៏ធ្វើការងារសំណង់ដែរនោះ ផល្លីបានដាក់ពាក្យចូលធ្វើការនៅរោងចក្រ៤-៥ហើយ ប៉ុន្តែគេមិនទទួលយក ហើយក្រុមគ្រួសារបានគិតថា ដោយសារតែនាងមានអាយុលើស៣០ឆ្នាំ និងថែមទាំងមានកូន៣នាក់ទៀត ។ ដោយសារតំរូវការចាំបាច់ប្រចាំគ្រួសារនាង ផល្លី មិនដែលបានផ្ញើប្រាក់ទៅឱ្យឪពុកម្តាយនាងទេ ។ កូនប្រុសរបស់គាត់ម្នាក់ទៀតឈ្មោះ សៅ ប៊ុណ្ណារិទ្ធិ អាយុ ២៥ ឆ្នាំ ជាអ្នកបើកបរឱ្យក្រុមហ៊ុនសំណង់ ចំណែកឯប្រពន្ធរបស់គាត់ដែលមានស្រុកកំណើតនៅភូមិត្នោតច្រុះ ដែលនៅជិត

ភូមិពានីដែរនោះ កំពុងធ្វើការងារនៅរោងចក្រកាត់ដេរមួយ ។ ប៊ុណ្ណារិទ្ធី បានផ្តល់អោយឪពុកម្តាយ ១០-២០ដុល្លារ ក្នុងមួយខែ។ គ្រួសារនេះនៅមានកូនស្រីម្នាក់ទៀតឈ្មោះ សៅ សុភារ៉ា អាយុ ៤២ ឆ្នាំ រស់នៅជាមួយកូនពីរនាក់របស់នាងក្នុងភូមិពានីមានផ្ទះដាច់ដោយឡែកមួយនៅក្បែរនឹងផ្ទះឪពុកម្តាយនាងដែរ។ កាលពីប៉ុន្មានឆ្នាំមុន ប្តីរបស់នាង សុភារ៉ា ជាទាហានមកពីកំពង់ឆ្នាំង បានបោះបង់នាង និងកូនចោល។

លោក សៅ សំផន និង អ្នកស្រី ខាន់ សត្ថា បានប្រើប្រាស់ប្រាក់ដែលកូនៗផ្ញើមកសំរាប់ទិញម្ហូបអាហារ ជួលកំលាំងពលកម្មធ្វើស្រែ ទិញជីដាក់ស្រូវ ធ្វើបុណ្យទានផ្សេងៗ ទិញថ្នាំសំរាប់លោកស្រី សត្ថា ហើយនិងផ្គត់ផ្គង់ចៅពីរនាក់នៅក្នុងបន្ទុកជាមួយគាត់។ គ្រួសារនេះ ពឹងផ្អែកទាំងស្រុងលើលើប្រាក់ដែលកូនផ្ញើមក និងការធ្វើស្រែសំរាប់ចិញ្ចឹមជីវិតរបស់ពួកគេ ។ ពួកគាត់មានវ័យកាន់តែចាស់ណាស់ទៅហើយមិនអាចរកចំណូលបានពីប្រភពណាទៀតទេ។

## ការធ្វើស្រែចំការរបស់ក្រុមគ្រួសារ

សំផន និង សត្ថា បង្កបង្កើនផលលើដីស្រែលិចទឹកចំនួន២ហិកតានៅភូមិពានី ។ ផ្ទៃដីនេះរាប់បញ្ចូលទាំងដីកន្លះហិកតា ដែលគាត់បានបែងចែកទៅឱ្យកូនស្រីគាត់ សុភី ទុកជាកេរ្តិ៍។ ក្រុមគ្រួសារនេះ បង្កបង្កើនផលលើដី២ហិកតានេះ ហើយប្រើប្រាស់ស្រូវដែលផលិតបានលើដីកន្លះហិកតា សំរាប់ចិញ្ចឹមកូនទាំង២របស់សុភី ។ សុភីក៏បាននាំយកស្រូវដែលផលិតបានមួយចំណែក ទៅភ្នំពេញដើម្បីផ្គត់ផ្គង់ជីវភាពរបស់នាង និងប្តីនាងដែរ។

សំផន បាននិយាយថា ពួកគាត់អាចប្រមូលទិន្នផលស្រូវបាន ១០០ ថាំង ស្មើនឹង ២,៤០០គីឡូក្រាម លើផ្ទៃដី២ហិកតាក្នុងឆ្នាំ នៅក្នុងឆ្នាំណាដែលមានអំណោយផលល្អ ពោលគឺស្មើនឹង ១,២តោនក្នុង១ហិកតា ។ តែ កាលពី៤ឆ្នាំកន្លងទៅនេះ ពួកគាត់ទទួលរងនូវភាពរាំងស្ងួត ហើយអំឡុងពេលគ្រោះរាំងស្ងួតនោះ ពួកគាត់ផលិតស្រូវបានត្រឹមតែ ៧០ថាំង ស្មើនឹង ១,៦៨០គីឡូក្រាមលើផ្ទៃដី២ហិកតា បើគិតក្នុងមួយហិកតាទទួលបានតែ ០,៨ តោន។ ក្នុងឆ្នាំ ២០០៤ លោក សំផន បានធ្វើការប៉ាន់ប្រមាណថា ការប្រមូលផលនាពេលខាងមុខនេះ នឹងទទួលបានតិចជាង៧០ថាំង ដោយសារគ្រោះរាំងស្ងួតដែលបានជួបក្នុងពេលថ្មីនេះ។ សំផន បានអះអាងថា គ្រួសាររបស់គាត់ដែលសមាជិក ៥នាក់ (សំផន សត្ថា កូនស្រីច្បងបង្អស់ និងចៅ២នាក់) ត្រូវការស្រូវ ៧០ ថាំង សំរាប់ការហូបចុកប្រចាំឆ្នាំរបស់ពួកគេ បន្ថែមពីលើពូជស្រូវបំរុងទុកសំរាប់ធ្វើពូជផង។ បើការប្រមូលផលស្រូវរបស់ក្រុមគ្រួសារនៅឆ្នាំខាងមុខនេះ មិនគ្រប់គ្រាន់ទេនោះ លោក សំផន បានគ្រោងស្នើសុំឱ្យកូនៗរបស់គាត់ បង្កើនការឧបត្ថម្ភប្រាក់បន្ថែមទៀត។

ខណៈពេលការប្រមូលផលស្រូវរបស់ក្រុមគ្រួសារ មានការឡើងចុះពីមួយឆ្នាំទៅមួយឆ្នាំ លោក សំផន និងអ្នកស្រី សត្ថា នៅតែចំណាយទុនច្រើនលើការផលិតស្រូវប្រចាំឆ្នាំដដែល។ លោក សំផន បានប្រើប្រាស់លុយដែលកូនស្រីផ្ញើមកឱ្យ ដើម្បីទិញជី១ ឬ២ការ៉ុងបង្ការទុកមុនរដូវបង្កបង្កើនផលចូលមកដល់ ដោយជីមួយការ៉ុង តាមការរាយការណ៍ថា មានតំលៃ ២០០,០០០ រៀល។ បច្ចុប្បន្ននេះ ដោយសារគាត់កាន់តែមានវ័យចាស់ហើយ ពុំអាចភ្ជួរដោយខ្លួនឯងបាន គាត់ក៏ជួលក្មួយប្រុស គាត់ឱ្យភ្ជួររាស់ឱ្យក្នុងតំលៃ ៥០,០០០រៀល សំរាប់ដី២ហិកតា ដោយប្រើប្រាស់គោ និងន័ង្គលរបស់គាត់។ គ្រួសារ នេះ ក៏បានជួលកំលាំងដកស្ទូងក្នុងតំលៃ ៣,០០០រៀលក្នុងមួយ ថ្ងៃសំរាប់ម្នាក់ៗ ដោយមានអាហារបីពេលផង ។ ពេលខ្លះ គ្រួសារនេះ អោយកម្មករស៊ីឈ្នួលខ្ចីបុលស្រូវជាមុននៅក្នុងរដូវប្រាំង ចំពោះអ្នកណាដែលយល់ព្រមសងវិញ តាមរយៈការដកស្ទូងលើដីស្រែរបស់គាត់ ។ តាមធម្មតា អ្នកដែលខ្ចីអង្ករ ១៥គីឡូក្រាម នឹងត្រូវជួយធ្វើស្រែគាត់ ក្នុងរយៈពេល៥ថ្ងៃ។ នាពេលរដូវច្រូតកាត់ លោក សំផន រកអ្នកដទៃមកធ្វើការដូរយកអាហារ៣ពេលក្នុងមួយថ្ងៃ ដោយការប្រើប្រាស់គោរបស់គាត់ដឹកជញ្ជូនស្រូវពីស្រែមកដាក់ផ្ទះ។

## ការប្រមើលមើលអនាគតក្នុងគ្រួសារ

បច្ចុប្បន្ននេះ នាង សៅ សូភី ដែលមានគតិ បានឈប់សំរាកពីការងារនៅរោងចក្រកាត់ដេរមួយរយៈ ។ ដោយសារ នាងមិនបានទទួលនូវប្រាក់កម្រៃពីរោងចក្រសំរាប់ការឈប់សំរាកលំហែមាតុភាពនោះ ដូច្នេះការឧបត្ថម្ភរបស់នាង ដល់ឪពុកម្តាយត្រូវបានកាត់ផ្តាច់ស្ទើរទាំងស្រុង ។ កាលពីមួយសប្តាហ៍កន្លងមកនេះ នាងបានមកលេងភូមិពានី ហើយបានផ្តល់លុយ ៤០,០០០៛ (១០ដុល្លារ) ឱ្យទៅឪពុកម្តាយនាងសំរាប់ផ្គត់ផ្គង់កូនទាំងពីរនាក់។ ឥឡូវនេះ សុភី បានទៅកំពង់ឆ្នាំង ជាស្រុកកំណើតម្តាយក្មេករបស់នាង ដើម្បីទៅសំរាលកូនទី៣របស់នាងនៅទីនោះ ហើយនៅពេលនាងត្រឡប់មកភ្នំពេញវិញ កូនរបស់នាងនឹងត្រូវផ្ញើទុកនឹងម្តាយក្មេកនៅកំពង់ឆ្នាំងមើលថែទាំ។ ការរស់នៅទីក្រុងភ្នំពេញ គ្រួសាររបស់នាង សុភី មានតែបន្ទប់មួយនៅក្នុងផ្ទះតូចមួយ មិនមានអ្នកមើលថែទាំកូនៗឡើយ។ ដូច្នេះ ក្នុងពេលអនាគតខ្លីមួយ កូនច្បងទាំងពីរ នឹងត្រូវបន្តរស់នៅជំធាត់នៅខេត្តព្រៃវែង និងកូនពៅ នៅឯខេត្តកំពង់ឆ្នាំង។ សុភីមានគំរោងត្រឡប់ទៅធ្វើការនៅរោងចក្រកាត់ដេរវិញ ក្នុងអំឡុងពេល ៣ខែទៀត ប៉ុន្តែលោក សំផន មិនប្រាកដក្នុងចិត្តថា រោងចក្រគេនឹងទទួលយកកូនស្រីរបស់គាត់ម្នាក់នោះ បន្តធ្វើការទៀត ឬយ៉ាងណានោះទេ ។

## ករណីសិក្សាទី ៦:
## គ្រួសាររបស់លោក ភោគ សារុន និង អ្នកស្រី ហៀវ ចាន់ផា
## ភូមិព្រៃខ្សាច់ ឃុំល្វា

លោក ភោគ សារុន អាយុ ៥២ឆ្នាំ ចំណែកភរិយារបស់គាត់ឈ្មោះ ហៀវ ចាន់ផា មានអាយុដូចគ្នានឹងគាត់ដែរ រស់នៅនៅភូមិព្រៃខ្សាច់ ឃុំល្វា ។ គ្រួសារនេះមានកូន ៨នាក់ ។ កូនស្រីច្បងបង្អស់បានរៀបការរួចហើយ កំពុងរស់នៅជាមួយប្តី និងកូន៣នាក់នៅឃុំក្បែរគ្នា ហើយពួកគេក៏ជាកសិករ។ រីឯកូនប្រុសច្បងបង្អស់របស់គ្រួសារនេះជាព្រះសង្ឃគង់នៅវត្តមួយនាខេត្តតាកែវ ។ ចំពោះកូន ៦នាក់ទៀត ស្ថិតនៅក្នុងបន្ទុករបស់គ្រួសារ។ កូនស្រីបីនាក់ដែលនៅលីវក្នុងចំណោមកូនទាំង៦ កំពុងធ្វើការងារនៅរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញ។

នាង ភោគ ប៊ុនធី អាយុ ២៣ឆ្នាំ បានធ្វើការនៅរោងចក្រកាត់ដេរនៅភ្នំពេញតាំងពីឆ្នាំ ២០០០មកម្ល៉េះ ដោយឪពុកមានាង ជាអ្នកថែទាំ និងជួសជុលម៉ាស៊ីនភ្លើងនៅរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញ រកការងារឱ្យនាងធ្វើ ដូច្នេះ នាងមិនបានសូកកាក់សំរាប់ចូលធ្វើការទេ។ នាងទទួលបានប្រាក់ខែ ៤៥ ដុល្លារក្នុងមួយខែ ហើយអាចឡើងដល់ ៧០-៨០ដុល្លារ ករណីធ្វើការថែមម៉ោង ។ នាងបានបញ្ចប់ការសិក្សាដល់ថ្នាក់ទី៨។

នាង ភោគ ធីតា អាយុ ២០ ឆ្នាំ និង ភោគ កណ្ណារី អាយុ ១៨ ឆ្នាំ បានធ្វើចំណាកស្រុកទៅទីក្រុងភ្នំពេញជាមួយគ្នា រយៈពេល៥ខែកន្លងទៅនេះគឺក្រោយពេលចូលឆ្នាំខ្មែរ២០០៤រួចភ្លាមៗ។ ម្តាយមីងដែលបានធ្វើការនៅក្នុងរោងចក្រមួយ បានជួយរកការងារឱ្យគេបានធ្វើនៅ ក្នុងរោងចក្រដែលគាត់ធ្វើការនោះដែរ ។ នាងទាំងពីរនាក់ រស់នៅក្នុងបន្ទប់មួយជាប់នឹងបន្ទប់ម្តាយមីងនាង នៅក្បែររោងចក្រ ។ ពួកគេក៏មិនបានចំណាយលុយដើម្បីសូករកដែរ ។ នៅពេលចាប់ផ្តើមធ្វើការដំបូង ពួកគេទទួលបានប្រាក់ខែ ៣០ដុល្លារម្នាក់ៗ ប៉ុន្តែឥឡូវទទួលបាន ៤០ ដុល្លារក្នុងមួយខែ ហើយបើធ្វើការថែមម៉ោង ពួកគេអាចទទួលបាន ៦០ ដុល្លារ ក្នុង១ខែ។ ធីតា បានបញ្ចប់ការសិក្សាថ្នាក់ទី៦ ចំណែកឯ កណ្ណារី បានបញ្ចប់ការសិក្សាថ្នាក់ទី ៨ ។

លោក សារុន និង អ្នកស្រី ចាន់ផា បានពន្យល់ថា កូនស្រីរបស់គាត់បានធ្វើចំណាកស្រុក ទៅធ្វើការនៅរោងចក្រកាត់ដេរ ដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់បានធ្វើឱ្យថយចុះនូវទិន្នផលស្រូវរបស់គាត់ ។ គាត់មានការលំបាកដើម្បីចិញ្ចឹមគ្រួសារទាំងមូលដែលរស់នៅជុំគ្នា ដោយការទទួលបាននូវផលស្រូវបន្តិចបន្តួច ។ លើសពីនេះទៅទៀត នៅពេលការធ្វើស្រែបានចប់សព្វគ្រប់ កូនស្រីរបស់គាត់មិនមានការងារផ្សេងសំរាប់ធ្វើទេ។

## ការធ្វើផែស្រចំការរបស់ក្រុមគ្រួសារ

ក្រុមគ្រួសាររបស់ លោក ភោគ សារុន និងអ្នកស្រី ហៀវ ចាន់ផា មានដីស្រែធ្វើស្រូវវស្សាចំនួន ១.៥ ហិកតា។ គាត់បានបែងចែកដីមួយឡូត៍មានទំហំ ០.៣ ហិកតាដល់កូនស្រីដែលបានរៀបការរួច ។ គ្រួសារធ្វើការដាំដុះនៅលើផ្ទៃដី ១.៥ ហិកតា រួមគ្នា ។ កូនស្រីដែលបានរៀបការរួចហើយ បានមកជួយធ្វើស្រែ និងប្រមូលផលស្រូវជាចំណែករបស់នាង នៅរដូវច្រូតកាត់រួចរាល់ ។

នៅក្នុងរដូវធ្វើស្រែជាធម្មតា ក្រុមគ្រួសារនេះអាចផលិតស្រូវបាន ២.០០០គីឡូក្រាម លើទំហំក្បាលដី ១.៥ ហិកតា ឬ ១.៣ តោន ក្នុងដីស្រែមួយហិកតា ។ នៅក្នុងពេលមានគ្រោះទឹកជំនន់ និងរាំងស្ងួត គ្រួសារនេះ បានផលិតស្រូវបានតិច ។ ឧទាហរណ៍ នៅឆ្នាំ ២០០៣-២០០៤ គេមិនបានធ្វើស្រែនៅលើផ្ទៃដី ០.៥ ហិកតា ដោយសាររាំងស្ងួត ហើយបានប្រមូលផលស្រូវបានតែ ៩៦០គីឡូក្រាម នៅលើក្បាលដីដែលនៅសល់មួយហិកតា ។ កាលពីឆ្នាំមុនៗ មានភ្លៀងធ្លាក់ខ្លាំងមុនពេលច្រូតកាត់ ធ្វើអោយមានទឹកជំនន់ ហើយបានបំផ្លាញដំណាំស្រូវអស់ ។ ក្នុងឆ្នាំ ២០០៤ គ្រួសារនេះមិនអាចដកស្ទូងបាននៅក្នុងខែកក្កដា ដោយសារភាពរាំងស្ងួត តែក្រោយមកនៅក្នុងខែកញ្ញា ទឹកហូរពីស្ទឹងមកលិចស្រែអស់រលីង ។ ពួកគេមានគំរោងមានផែនការដកស្ទូងនៅដើមខែតុលា ហើយមិនមានសង្ឃឹមថានឹងប្រមូលផលបានពីការច្រូតកាត់នៅក្នុងខែមករានោះទេ ។ ក្នុងអតីតកាល គ្រួសារនេះបានជួលកម្មករដើម្បីជួយធ្វើការដកស្ទូង ។ នៅក្នុងឆ្នាំនេះ ដោយសារគ្មានប្រាក់កាស ពួកគាត់ត្រូវធ្វើការដោយខ្លួនឯង។ លោក ភោគ សារុន បានកត់សំគាល់ថា រូបគាត់ និងប្រពន្ធព្រមទាំងកូនតូចៗទាំងបីត្រូវការស្រូវចំនួន ១.៥០០ គ.ក សំរាប់ការហូបចុកក្នុងមួយឆ្នាំៗ។

ដើម្បីជាជំនួយបន្ថែមលើផលស្រូវរបស់គេ ក្រុមគ្រួសារបានខិតខំដាំដំណាំ និងចិញ្ចឹមមាន់ ។ កាលពីមុន ពួកគេបានចិញ្ចឹមជ្រូក បុន្តែងាប់អស់ ។ អ្នកស្រី ចាន់ផា បានដាក់តូបតូចមួយនៅក្នុងផ្ទះ ដោយមានលក់ចេក ស៊ុត និងគ្រឿងបរិភោគផ្សេងៗទៀតដែលគាត់បានទិញពីផ្សារចម្ងាយ ១០គ.ម តាមបណ្តោយផ្លូវជាតិ ។ លោក សារុន និងអ្នកស្រី ចាន់ផា បាននិយាយថា ពួកគាត់កាន់តែចាស់ ហើយមានជម្ងឺរផងនោះ នឹងមិនមានកម្លាំងពលំឯណា ទៅរកស៊ីឈ្នួលស្ទូងដក និងច្រូតកាត់បានទេ ។ លោក សារុន មិនធ្លាប់បានមកធ្វើការនៅទីក្រុងភ្នំពេញ ដូច្នេះមិនដែលបានស្គាល់ទីក្រុងទេ មានតែអ្នកស្រីចាន់ផា ជាអ្នកធ្លាប់ទៅភ្នំពេញដើម្បីទៅយកលុយឧបត្ថមពីកូនស្រីទាំងបីរបស់ពួកគាត់ ។

## ប្រាក់ផ្ញើឧបត្ថម្ភដល់ក្រុមគ្រួសារពីរោងចក្រកាត់ដេរ

អ្នកស្រី ចាន់ផា ធ្វើដំណើរទៅភ្នំពេញជារៀងរាល់ពីរឬបីខែម្តង ដើម្បីប្រមូលលុយដែលកូនស្រីរបស់គាត់បំរុងទុកសំរាប់ជួយដល់ក្រុមគ្រួសារ ។ ជាធម្មតា នាង ប៊ុនធី បានជូនម្តាយរបស់គេ ២០ ដុល្លារក្នុងមួយខែ ។ ចំនួនពិតប្រាកដដែលបានផ្ញើ មានពេលខ្លះច្រើន មានពេលខ្លះតិច គឺវាអាស្រ័យទៅលើការរកកំរៃបានពីការងារលើសម៉ោង ហើយកំរៃដែលបានពីការធ្វើការលើសម៉ោង ក៏មានការប្រែប្រួលពីមួយខែទៅមួយខែ ។ ប្រាក់ខែធម្មតាដែល នាង ប៊ុនធី ទទួលបានស្ទើរតែទាំងអស់ គឺចំណាយទៅលើជីវភាពរស់នៅរបស់នាង ។ នៅពេលដែល នាង ធីតា និងកណ្ណារី បានធ្វើការនៅទីក្រុងភ្នំពេញរយៈពេល៥ខែដំបូង អ្នកស្រីចាន់ផា បានមកសួរសុខទុក្ខពួកគេពីរដងហើយ ។ កាលពីលើកទីមួយ កូនស្រីទាំងពីរនាក់នេះបានរួមគ្នាផ្តល់ប្រាក់ឧបត្ថមដល់គាត់ ៣០ដុល្លារ ប៉ុន្តែលើទីពីរ បានត្រឹមតែ ១០ ដុល្លារប៉ុណ្ណោះ ។ លោក សារុន និងអ្នកស្រី ចាន់ផា ប្រើប្រាស់លុយដែលកូនរកបានពីការងារនៅរោងចក្រកាត់ដេរទៅទិញអង្ករ ត្រី និងសាច់ជ្រូក បរិច្ចាកចូលរួមបុណ្យសព និងអាពាហ៏ពាហ៏ ទិញជីដាក់ស្រែ ទិញសំលៀកបំពាក់ និងសម្ភារៈសិក្សាសំរាប់កូនតូចៗ ព្រមទាំងទិញថ្នាំសង្កូវ សំរាប់អ្នកស្រី ចាន់ផា ដែលមានជំងឺខ្នងរ៉ាំរ៉ៃ ។

## ការប្រមើលមើលអនាគតក្នុងគ្រួសារ

អ្នកស្រី ចាន់ផា មានកង្វល់ពីកូនស្រីរបស់គាត់ដែលធ្វើការនៅរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញ ប៉ុន្តែគាត់មានអារម្មណ៏ថា ពួកគេគ្មានជំរើសទេ ។ បើពួកគេរស់នៅក្នុងភូមិវិញ ក្រុមគ្រួសារពិតជាជួបប្រទះផលលំបាក ដោយការខ្វះខាតអង្ករហូបចុកជាមិនខាន។ លោក សារុន បានបញ្ជាក់ថា តាំងពីការចែកដីធ្លីនៅដើមទសវត្សឆ្នាំ ១៩៨០ ក្រុមគ្រួសារគាត់បានពឹងផ្អែកតែទៅលើផ្ទៃដីស្រែទំហំ ១.៥ហិកតាដដែល ។ កាលពីពេលនោះ គេមានកូនតែម្នាក់ប៉ុណ្ណោះ បុន្តែឥឡូវនេះ ពួកគេមានកូនរហូតដល់ទៅ៨នាក់ ។ ជាមួយនឹងការរៀបអាពាហ៏ពិពាហ៏អោយកូនជាបន្តបន្ទាប់ទៀតនោះ ដីស្រែដែលមាននេះ នឹងត្រូវបន្តបែងចែកតទៅទៀត។ តើពួកគេនឹងអាចរស់នៅបានដោយរបៀបណា? ។ លោក សារុន បានលើកឡើងថា គេត្រូវតែបង្កើតការងារបន្ថែមទៀត ព្រោះចំនួនមនុស្សមានកើនឡើងឥតឈប់ឈរ។ គាត់បានពោលអះអាងថា រដ្ឋាភិបាលគួរគាំទ្រដល់ការពង្រីករោងចក្រកាត់ដេរ ។ បើរោងចក្រកាត់ដេរត្រូវបានគេបិទ ដូចពាក្យចចាមអារាមមែននោះ ប្រជាពលរដ្ឋនៅព្រៃវែងនឹងប្រឈមមុខផលលំបាកយ៉ាងច្រើន ។ ដូច្នេះ រដ្ឋាភិបាលត្រូវបណ្តាក់ទុនទៅលើឧស្សាហកម្មរោងចក្រកាត់ដេរនេះ ព្រោះមានដីកាន់តែតិចទៅៗ ។

## ករណីសិក្សាទី ៧:
## គ្រួសាររបស់លោក ភោគ រិទ្ធី និង អ្នកស្រី ពេជ្រ ស៊ុនលី
## ភូមិព្រៃខ្សាច់ ឃុំល្វា

លោក ភោគ រិទ្ធី គឺជាប្អូនប្រុសរបស់លោក ភោគ សារុន (សូមមើលករណីសិក្សាទី៦)។ លោក រិទ្ធី និង ភរិយា អ្នកស្រី ពេជ្រ ស៊ុនលី មានអាយុ ៤១ ឆ្នាំដូចគ្នា និងមានកូន ៦នាក់។ លោក រិទ្ធី បានធ្វើការនៅទីក្រុងភ្នំពេញរយៈពេល៩ឆ្នាំមកហើយ ជាអ្នកថែទាំ និងជួសជុលម៉ាស៊ីនភ្លើងនៅរោងចក្រកាត់ដេរ ។ រយៈពេល៩ខែកន្លងទៅ កូនស្រីរបស់គាត់ឈ្មោះ ភោគ សុធា អាយុ ២១ ឆ្នាំ ក៏បានបំរើការងារជាកម្មការិនី នៅរោងចក្រកាត់ដេរដែរ។ ដោយមានការបង្ខំឱ្យធ្វើការថែមម៉ោងលើសលប់ នាង សុធា បានដួលសន្លប់នៅក្នុងសាលរោងចក្រ ។ បន្ទាប់មក ឪពុករបស់នាងបាននាំនាងទៅស្រុកកំណើត ដើម្បីធ្វើការព្យាបាល។

នាង ភោគ សុធា រកការងារបានធ្វើដំបូងនៅរោងចក្រកាត់ដេរនាក្រុងភ្នំពេញ កាលពីឆ្នាំ ២០០១ នៅពេលនោះ នាងបានស្នាក់នៅជាមួយបងជីដូនមួយនាងឈ្មោះ ភោគ ប៊ុនធី។ នាង សុធា បានបំរើការងារឱ្យរោងចក្រកាត់ដេរ ដែលគ្រប់គ្រងដោយថៅកែចិនរយៈពេលបីខែ បន្ទាប់មក នាងត្រូវបានគេបញ្ឈប់ដោយមូលហេតុជំងឺរាំរ៉ៃ និងបន្ត ការឈប់សំរាកញឹកញាប់ ប៉ុន្តែ នាង សុធា បានអះអាងថា រោងចក្រនេះតែងតែបញ្ឈប់កម្មករជាទៀតទាត់ ក្រោយពេលបញ្ចប់រយៈពេលសាកល្បងការងារបីខែ ដើម្បីកុំឱ្យកម្មករទាមទារបៀវត្សខ្ពស់សំរាប់ការងារពេញសិទ្ធិ របស់ពួកគេ។ ពីរខែក្រោយមក នាងទទួលបានការងារផ្សេងទៀតជាកម្មការិនីអណ្តែតនៅរោងចក្រទី២ ដែលមាន គ្រប់គ្រងដោយជនជាតិចិនដែរ ។ ប៉ុន្តែនាងបានឈប់ពីរោងចក្រទីពីរនោះភ្លាម ក្រោយពេលនាងបានសំភាសន៍ជាប់ នៅរោងចក្រទី៣ដែលគ្រប់គ្រងដោយជនជាតិចិនទៀត។ នាង សុធា បាននៅធ្វើនៅរោងចក្រកាត់ដេរនេះរយៈពេល ជិត៣ឆ្នាំហើយដែលកាលពីចូលដំបូង នាងបានធ្វើជាបុគ្គលិកអណ្តែត ក្រោយមកជាបុគ្គលិកពេញសិទ្ធិ។ នៅរោង ចក្រនេះ រាល់កិច្ចការទាំងអស់ ដោយមិនគិតថា ជាកម្មករពេញសិទ្ធិ ឬកម្មករអណ្តែតនោះទេ គឺពួកគេត្រូវទទួល ប្រាក់ឈ្នួលទៅតាមចំនួនបុង។ តាមធម្មតា នាង សុធា អាចទទួលបុងតែមួយក្នុងមួយថ្ងៃដែលស្មើនឹងទឹកប្រាក់ ៥,០០០៛ (១,២៥ ដុល្លារ) ។ កាលណានាងធ្វើការបានច្រើន ចំណូលរបស់នាងក៏កើនឡើងតាមនោះដែរ ពោលគឺក្នុងមួយខែទទួលបាន ៥0 ដុល្លារគិតទាំងប្រាក់ធ្វើការថែមម៉ោង។ កាលនោះ សុធា ធ្វើការថែមម៉ោងពី ៣-៥ម៉ោង ក្នុងមួយថ្ងៃ ដោយធ្វើការពេញមួយថ្ងៃ និងបន្តរហូតដល់យប់ជ្រៅ ។

**ប្រាក់ផ្ញើឧបត្ថម្ភដល់ក្រុមគ្រួសារពីរោងចក្រកាត់ដេរ**

អ្នកស្រី ពេជ្រ ស៊ុនលី បានឱ្យដឹងថា ប្តីរបស់គាត់ លោក ភោគ រិទ្ធី បានផ្ញើលុយជាទៀងទាត់មកឱ្យគាត់នៅខេត្តព្រៃវែងចំនួន៤០-៥០ដុល្លាររៀងរាល់ខែ។ អ្នកស្រី បាននិយាយថា ប្តីរបស់គាត់ចេះសន្សំសំចៃចំពោះចំណូលដែលគាត់រកបាន ដោយមិនចាយវាយខ្ជះខ្ជាយនៅភ្នំពេញទេ។ ពេលខ្លះ លោក រិទ្ធី យកលុយមកឱ្យគ្រួសារដោយផ្ទាល់ និងពេលខ្លះទៀត កូនប្រុសឈ្មោះ ភោគ សុវណ្ណារិទ្ធី អាយុ ១៩ ឆ្នាំ ទៅភ្នំពេញ យកលុយពីឪពុករបស់គេ។

នាង ភោគ សុធា មិនបានផ្ញើប្រាក់ទៅឱ្យម្តាយឱ្យបានទៀងទាត់ដូចឪពុករបស់នាងទេ បើប្រៀបធៀបនឹងប្រាក់ខែរបស់នាងនៅរោងចក្រដំបូង ចំណូលដែលបានតាមរយៈជាបុងនៅរោងចក្រទី៣នេះតិចជាង ហើយជាធម្មតាគឺសំរាប់តែការចំណាយផ្ទាល់ខ្លួនរបស់នាងប៉ុណ្ណោះ ។ មានពេលមួយនោះ អ្នកស្រី ស៊ុនលី បានយកលុយដែលនាង សុធា បានផ្តល់អោយនោះ ផ្ញើមកអោយនាងវិញចំនួន ៥០,០០០៛ (១២,៥ដុល្លារ) ដោយគាត់យល់ពីការលំបាករបស់កូននៅក្រុងភ្នំពេញ។ នៅពេលមានការចាំបាច់ខ្លាំង នាងសុធា ថែមទាំងបានសុំប្រាក់ពីឪពុកនាងដែលធ្វើការនៅភ្នំពេញដែរ។

ពីពេលមុន បន្ទាប់ពីប្រមូលផលស្រូវរួចហើយ ភោគ សុវណ្ណារិទ្ធី អាយុ ១៩ ឆ្នាំ មានឱកាសបានទៅធ្វើការងារសំណង់ជាលើកដំបូងនៅភ្នំពេញរយៈពេល៦ខែ។ សុវណ្ណារិទ្ធី ស្នាក់នៅទីឯកន្លែងការដ្ឋានសាងសង់ ហើយបានផ្ញើប្រាក់ឱ្យម្តាយរបស់គាត់ពី ៥០,០០០-៦០,០០០៛ (១២,៥-១៥ ដុល្លារ) រៀងរាល់ខែ ។ ឥឡូវនេះ សុវណ្ណារិទ្ធី បានត្រឡប់មកភូមិវិញហើយ ប៉ុន្តែមានគំរោងត្រឡប់ទៅភ្នំពេញវិញនាពេលឆាប់ៗនេះ ក្រោយពេលបានធ្វើស្រែរួចរាល់ហើយនោះ។

**ការធ្វើផែស្រចំការរបស់ក្រុមគ្រួសារ**

គ្រួសារនេះ មានដីស្រែមួយហិកតា ដោយរាប់បញ្ចូលដីស្រែដែលបានចែកកាលពីដើមទសវត្សឆ្នាំ ១៩៨០ និងដីកេរ្តិ៍មរតករបស់អ្នកស្រី ស៊ុនលី ។ នៅឆ្នាំណាដែលមានអំណោយផលល្អ ពួកគាត់អាចប្រមូលផលស្រូវបាន ១,៥៦០ គីឡូក្រាម ស្មើនឹង ១,៥៦តោនក្នុងដីស្រែមួយហិកតា។ តែក្នុងឆ្នាំមានទឹកជំនន់ និងរាំងស្ងួត គាត់អាចប្រមូលផលបានត្រឹមតែ ៩៦០ គីឡូក្រាម ស្មើនឹង ០,៩៦តោនលើដីស្រែមួយហិកតា ។ អ្នកស្រី ស៊ុនលី បានអះអាងថា គ្រួសាររបស់គាត់ ត្រូវការស្រូវ ២,៤០០ គីឡូក្រាម សំរាប់ការហូបចុកប្រចាំឆ្នាំ។ ដូច្នេះ នេះជាការបង្ហាញឱ្យឃើញថា ទោះបីជាឆ្នាំណាដែលមានអំណោយផលល្អក៏ដោយ ក៏គ្រួសារនេះមិនអាចពឹងផ្អែកតែលើការធ្វើស្រែមួយមុខដើម្បីចិញ្ចឹមជីវិតនោះទេ ដូច្នេះក្រៅពីការចិញ្ចឹមមាន់ និងជ្រូក គ្រួសារនេះត្រូវពឹងផ្អែកទាំងស្រុងលើការផ្ញើប្រាក់ពី លោក រិទ្ធី និងការផ្ញើបន្តិចបន្តួចពី នាង សុធា និង កូនប្រុសរបស់គាត់ សុវណ្ណារិទ្ធី។

## ការប្រមើលមើលអនាគតក្នុងគ្រួសារ

លោក ភោគ រិទ្ធី ហាក់ដូចជាមានការងារអចិន្ត្រៃយ៍នៅភ្នំពេញ តែក៏អាស្រ័យលើលទ្ធភាពដំណើរការតទៅមុខនៃឧស្សាហកម្មកាត់ដេរដែរ ។ ចំពោះ នាង សុធា ទោះបីនាងបានដួលសន្លប់ក្នុងរោងចក្រកាលពីដើមឆ្នាំក៏ដោយ នាងនៅតែបានមកភ្នំពេញដាក់ពាក្យធ្វើការនៅតាមរោងចក្រកាត់ដេរផ្សេងទៀតដែរ ។ សុធាបានទទួលស្គាល់ថា នាងមិនពូកែធ្វើស្រែចំការទេ ហើយនាងក៏នឹកមិត្តភក្តិនៅភ្នំពេញ។ នាងបានបន្ថែមទៀតថា ក្នុងនាមជាស្រី នាងត្រូវការសំលៀកបំពាក់ច្រើន និងមានការងារធ្វើផ្ទាល់ខ្លួន ដើម្បីឱ្យនាងអាចទិញនូវអ្វីដែលនាងត្រូវការ ។ នាង សុធា បានទទួលស្គាល់ដែរថា ការចូលរួមចំណែកផ្គត់ផ្គង់គ្រួសារ ជាការជួយសំរាលបន្ទុកដែលរ៉ាប់រងដោយឪពុករបស់នាង។ ចំណែកឯ សុវណ្ណារិទ្ធិ ក៏ខិតខំស្វែងរកការសំណង់ធ្វើបន្ថែមទៀតនៅភ្នំពេញដែរ។ តាមការប្រមើលមើលទៅអនាគត អ្នកស្រី ពេជ្រ ស៊ុនលី បានអះអាងថា គាត់មិនមានដីស្រែគ្រប់គ្រាន់សំរាប់ចែកកូនចៅទេ។ ក្នុងខណៈដែលដីស្រែ អាចផលិតបានស្រូវសំរាប់តែជួយចិញ្ចឹមគាត់ និងប្តីក្នុងច្រើនឆ្នាំតទៅមុខនោះ ដូច្នេះកូនៗត្រូវតែខិតខំរកការងារធ្វើនៅភ្នំពេញជាបន្តទៅទៀត។

## សេចក្ដីសន្និដ្ឋាន

ជាងមួយទសវត្សរកន្លងទៅនេះ វិស័យឧស្សាហកម្មកាត់ដេរនាំចេញសម្លៀកបំពាក់ បានចូលរួមចំណែកច្រើន ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា ។ កំណើនប្រចាំឆ្នាំនូវផលិតផល ការលក់ចេញទៅបរទេស ការទទួលបានចំណូលរូបិយប័ណ្ណបរទេស និងការមានការងារធ្វើ បញ្ជាក់ពីកំណើនយ៉ាងឆាប់រហ័សនៃឧស្សាហកម្ម និងជាការរួមចំណែកដ៏សំខាន់មួយនៃសេដ្ឋកិច្ចជាតិទាំងមូល ។ ការកើនឡើងនៃឧស្សាហកម្មកាត់ដេរនេះ អាស្រ័យទៅលើកត្តាពាក់ព័ន្ធមួយចំនួន ។ ដំណើរវិវត្តន៍ដូចជា ការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចពីសេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចទីផ្សាររបស់ប្រទេសកម្ពុជា កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មជាមួយសហគមន៍អ៊ឺរ៉ុប និងសហរដ្ឋអាមេរិក ការប្រកាន់ខ្ជាប់នូវស្តង់ដារការងារក្នុងស្មារតីទទួលខុសត្រូវចំពោះសង្គម ការចូលរួមយ៉ាងសំខាន់ពីសំណាក់មន្ត្រីរាជរដ្ឋាភិបាល និងមន្ត្រីនៃសមាគមផលិតកររោងចក្រកាត់ដេរនៃប្រទេសកម្ពុជា និងឥទ្ធិពលនៃកូតា សម្លៀកបំពាក់ បានចូលរួមចំណែកក្នុងការជំរុញអោយសហគ្រាសកាត់ដេរថ្មីៗលូតលាស់ និង បង្កើនសកម្មភាពផលិតកម្មយ៉ាងខ្លាំងក្លា នៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់ពី ការបញ្ចប់ប្រព័ន្ធកូតាទូទាំងពិភពលោកនោះមក ក៏ឧស្សាហកម្មនេះនៅតែដំណើរការជាបន្តនៅក្នុងឆមាសទី ១នៃឆ្នាំ ២០០៥ នេះដែរ ។ តែលទ្ធភាពនៃការបន្តដំណើរការតទៅមុខនៃឧស្សាហកម្មនេះ ស្ថិតនៅក្នុងភាពមិនទាន់ប្រាកដប្រជានៅឡើយនោះទេ ។ ការនៅបន្តដាក់របាំងការពារការនាំចូលពីប្រទេសចិនពីសំណាក់ប្រទេសអាមេរិក និងសហគមន៍អ៊ឺរ៉ុប នៅក្នុងឆ្នាំ ២០០៥ នឹង មានសុពលភាពត្រឹមឆ្នាំ ២០០៨ ប៉ុណ្ណោះ ។ ដូច្នេះ គេមើលឃើញថា ពេលវេលានៅសល់តិច សំរាប់រាជរដ្ឋាភិបាល ក៏ដូចជា ឧស្សាហកម្មកាត់ដេរ ក្នុងការធ្វើកំណែទំរង់ក្នុងក៏រិតធំដែលនេះជាប្រការចំបាច់ ដើម្បីអោយឧស្សាហកម្មនេះ អាចមានលទ្ធភាពប្រកួតប្រជែងជាបន្តទៅទៀតបាន ។

កំណើនការងារក្នុងវិស័យកាត់ដេរ បានឆ្លើយតបចំពេលវេលាដែលមានវិបត្តិវិស័យកសិកម្មនៅខេត្តព្រៃវែង និងខេត្តដទៃទៀតនៅប្រទេសកម្ពុជា។ ដោយសារ គ្រោះរាំងស្ងួត និងទឹកជំនន់ជាប់ៗគ្នាតាំងពីឆ្នាំ ២០០១ មក ធ្វើអោយខូចខាតទិន្នផលស្រូវ និងបានធ្វើអោយក្រុមគ្រួសារនៅតំបន់ជនបទក្នុងខេត្តព្រៃវែងជួបនូវការខ្វះខាតស្បៀងយ៉ាងខ្លាំង និងជំពាក់បំណុលច្រើនដោយសារការចំណាយសំរាប់ធ្វើស្រែចំការ ។ ដូច្នេះ ការចំណាកស្រុកមករកការងារធ្វើនៅតាមរោងចក្រកាត់ដេរជាជំរើសមួយដែលមានការចាប់អារម្មណ៍ក្នុងការទទួលនូវប្រាក់ចំណូល ទោះបីថា ការងារនេះបានផ្តល់ឱកាសឱ្យស្ត្រីវ័យក្មេងៗធ្វើការនៅភ្នំពេញច្រើនជាងបុរសក្តី ហើយនេះក៏ជាការបង្ហាញអោយឃើញនូវការផ្លាស់ប្តូរមួយនៅក្នុងទំនៀមទម្លាប់ពីបុរាណមក ។ នៅពេលដែលទទួលបានការងារនៅរោងចក្រ ហើយកម្មករជឿជាក់ថា បើគ្មានការងារបន្ថែមម៉ោងទេ ពួកគេមិនអាចមានប្រាក់គ្រប់គ្រាន់ក្នុងការផ្ញើទៅឱ្យគ្រួសាររបស់គេទេ ។ តែការខិតខំធ្វើការងារលើសម៉ោងដោយសារមានការងារច្រើនត្រូវបំពេញ បានធ្វើអោយកម្មកររោងចក្រជាច្រើន

មានទុក្ខកង្វល់ និងមានបញ្ហាសុខភាព ។ កម្មករកាត់ដេរមកពីខេត្តព្រៃវែង មកធ្វើការនៅភ្នំពេញដែលត្រូវបាន សំភាសន៍បានផ្ញើប្រាក់ទៅគ្រួសាររបស់គេ ជាមធ្យមគឺ ១៦,៨២ ដុល្លារអាមេរិកក្នុងមួយខែ ឬស្មើនឹង ២៧%នៃ ប្រាក់ចំណូលប្រចាំខែជាមធ្យមដែលរួមទាំងប្រាក់ការងារបន្ថែមម៉ោងផង ។ តួលេខនេះ ស្រដៀងគ្នានឹងចំលើយ របស់ក្រុមគ្រួសារនៅខេត្តព្រៃវែងដែលមានសមាជិកគ្រួសារធ្វើជាកម្មករកាត់ដេរដែរនោះបានឱ្យដឹងថា កូនៗរបស់ ពួកគេបានផ្ញើប្រាក់ទៅឱ្យចំនួន ១៦,១២ ដុល្លារអាមេរិកក្នុងមួយខែ ។ ការផ្ញើប្រាក់កាសទៅដល់ក្រុមគ្រួសារ នៅតំបន់ជនបទដែលបានរងនូវគ្រោះមហន្តរាយធម្មជាតិ ធ្វើអោយពួកគេមានលទ្ធភាពទិញស្រូវ និងស្បៀងអាហារ ផ្សេងៗទៀត ចំណាយលើសុខភាព យកទៅធ្វើស្រែ និងសងបំណុលគេ ។ ជាទូទៅ លុយដែលបានផ្ញើទៅផ្ទះនោះ ត្រូវបានយកទៅចំណាយសំរាប់ តែការខ្វះខាតសៀងអាហារក្នុងគ្រួសារ ជាជាងយកទៅប្រកបមុខជំនួញខ្នាតតូច ដើម្បីទទួលបាននូវប្រាក់ចំណូល។ ដូច្នេះ ជាលទ្ធផល ឧស្សាហកម្មកាត់ដេរមិនបានធ្វើអោយជីវភាពប្រសើររុងរឿង ទេ តែបានត្រឹមជួយទប់ទល់នូវការខ្វះខាតនៅក្នុងគ្រួសារប៉ុណ្ណោះ ។

ការផ្តល់ការងារដល់ស្ត្រីវ័យក្មេងៗ នៅក្នុងឧស្សាហកម្មកាត់ដេរ មានផលប៉ះពាល់ជាវិជ្ជមានមួយចំនួន។ កម្មករ មកពីខេត្តព្រៃវែង បានឱ្យដឹងថា ឋានៈនិងតួនាទីរបស់គេនៅក្នុងគ្រួសារមានភាពប្រសើរឡើង ហើយពួកគេមាន ឱកាសច្រើនឡើងក្នុងការធ្វើសេចក្តីសំរេចចិត្តដោយខ្លួនឯង។ ទាំងនេះធ្វើឱ្យស្ត្រីកាន់តែមានជំនឿជាក់លើខ្លួនឯង។ ទោះបីពួកគេបានចំណូលតិចតួចក្តី នេះក៏ជាប្រភពចំណូលឯករាជ្យរបស់គេដែលអាចមានលទ្ធភាពចំណាយមួយភាគ សំរាប់ទិញសំលៀកបំពាក់ ដើរលេងកំសាន្តផ្សេងៗ ព្រមទាំងទិញរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន។ នៅក្នុងប្រទេស កម្ពុជា ដែលគេមើលឃើញជាទូទៅថា ស្ត្រីវ័យក្មេងក្នុងគ្រួសារក៏ដូចជានៅក្នុងសង្គម មានឋានៈតូចទាបនោះ ពេលនេះការដែលពួកគេទទួលបាននូវ ផលប្រយោជន៍ដូចបានរៀបរាប់មកនេះគឺជា ការបង្ហាញអោយឃើញនូវ ការសំរេចបានស្នាដៃសំខាន់ៗយ៉ាងច្រើន និង ជាជោគជ័យរបស់ស្ត្រី ។ ផ្ទុយទៅវិញ ការបន្តទទួលបាននូវ ភាពប្រសើរឡើងរបស់កម្មការនីនេះគឺអាស្រ័យទៅលើលទ្ធភាពនៃការបន្តផ្ញើប្រាក់ទៅដល់ក្រុមគ្រួសារតទៅទៀត។

ចំពោះខ្លួនគេផ្ទាល់ កម្មករតែងតែបានជួបប្រទះនូវឧបសគ្គជានិច្ច ដោយសារមានភាពប្រែប្រួលឡើងចុះយ៉ាងខ្លាំង នៅក្នុងឧស្សាហកម្មកាត់ដេរនេះ។ ករណីជាក់ស្តែងគឺ ការបិទរោងចក្រ និងផ្អាកដំណើរការជាទូទៅគឺ ធ្វើឱ្យបាត់បង់ ការងាររបស់កម្មកររាប់ពាន់នាក់។ ការប្រែប្រួលនូវតម្រូវការកំលាំងពលកម្ម បណ្តាលឱ្យមានកំលាំងពលកម្មចល័ត កាន់តែច្រើនឡើងផងដែរ ។ តាមការកត់សំគាល់ មាន៤៣%នៃកម្មករមកពីខេត្តព្រៃវែងដែលត្រូវបានសំភាសន៍ ធ្លាប់ធ្វើការច្រើនជាងមួយរោងចក្រ ។ នៅពេលដែលកម្មករបាត់បង់ការងារ ឬ ឈប់ធ្វើការក្នុងរោងចក្រ ដោយខ្លួនឯង ពួកគេភាគច្រើនអាចរកបានការងារថ្មីនៅរោងចក្រផ្សេងទៀតភ្លាម។ អ្នកខ្លះទៀតត្រឡប់ទៅផ្ទះសិន រួចហើយមកភ្នំពេញវិញសារជាថ្មី ។ វាមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេដែលថា បញ្ហាកង្វះការងារធ្វើនៅជនបទ

ធ្វើអោយស្ត្រីវ័យក្មេងសំរេចចិត្តត្រឡប់មកទីក្រុងភ្នំពេញវិញនោះ ។ ប៉ុន្តែនិន្នាការនេះ អាចមានផលប៉ះពាល់ជាអវិជ្ជមាន ក្នុងពេលណាដែលឱកាសការងារធ្លាក់ចុះក្នុងទ្រង់ទ្រាយធំ គិតចាប់ពីបានបញ្ចប់កូតានោះ។ កម្មករ ដែលពុំមានជំនាញសំរាប់ការងារផ្សេងទៀត ព្រមទាំងមិនអាចត្រឡប់ទៅធ្វើការងារនៅក្នុងភូមិកំណើតរបស់គេវិញបាននោះ អាចធ្លាក់ទៅក្នុងការទទួលយកការងារដែលមិនសមស្រប ឬការងារណាដែលអាចមានការកេងប្រវ័ញ្ចនៅទីក្រុងភ្នំពេញ[២៩] ។

ការសន្យាបង្កើនផលិតភាពខាងពលកម្មនៅក្នុងឧស្សាហកម្មកាត់ដេរ ជាការផ្តល់នូវយុទ្ធសាស្ត្រមួយដើម្បីធ្វើឱ្យដំណើរការកាន់តែប្រសើរឡើងដើម្បីជាប្រយោជន៍ដល់ម្ចាស់រោងចក្រផង និងកម្មករផងដែរ ។ ដូចដែលមាននៅក្នុងការស្រាវជ្រាវមួយដែលឧបត្ថម្ភដោយជំនួយអភិវឌ្ឍន៍អន្តរជាតិរបស់អាមេរិក (USAID) នាពេលថ្មីៗនេះថា ការអភិវឌ្ឍន៍ និងបណ្តុះបណ្តាលបុគ្គលិក មានសក្តានុពលសំរាប់កែលំអរផលិតភាពរោងចក្រពី ១៥-២០%។ ការចំណេញពីផលិតភាព អាចឱ្យរោងចក្រផលិតនូវសំលៀកបំពាក់ដែលមានគុណភាពល្អ និងមានតម្លៃខ្ពស់។ ស្រដៀងគ្នានេះដែរ ដើម្បីកែលំអរផលិតភាព លុះត្រាតែមានកំលាំងពលកម្មដែលមានជំនាញខ្ពស់ និងផ្តល់ឱ្យគេនូវប្រាក់ខែខ្ពស់ផងដែរ ។ ការទទួលបាននូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលគោរពទៅតាមស្តង់ដារការងារប្រកបដោយភាពទទួលខុសត្រូវចំពោះសង្គម និងដើម្បីអោយមានការប្រកួតប្រជែងគឺ ទាមទារអោយមានការគ្រប់គ្រងដែលសំដៅទៅលើការលើកកពស់ជំនាញ និងស្តង់ដារការងារ ជាជាងការកាត់បន្ថយប្រាក់បៀវត្សរ៍ និងដាក់កំហិតនូវសកម្មភាពសហជីពរបស់កម្មករ ។ បន្ថែមពីលើការផ្តល់ផលប្រយោជន៍ភ្លាមៗដល់ម្ចាស់រោងចក្រ និងកម្មករ ការអភិវឌ្ឍន៍ជំនាញការប្រតិបត្តិការ បច្ចេកទេស និងការគ្រប់គ្រង អាចមានឥទ្ធិពលទៅលើរោងចក្រផ្សេងទៀត ទាក់ទាញការវិនិយោគក្នុងស្រុក និងបរទេស ព្រមទាំងអាចបង្កើតបានការងារថ្មីៗថែមទៀត ។ អ្វីដែលសំខាន់នោះគឺ ការបង្កើតអោយមានរោងចក្រច្រើនប្រភេទ អាចផ្តល់នូវមូលដ្ឋានគ្រឹះទូលំទូលាយសំរាប់នៃការអភិវឌ្ឍន៍មនុស្ស និងកំណើនសេដ្ឋកិច្ច[៣០] ។

កំណើនដែលគួរឱ្យកត់សំគាល់នៃឧស្សាហកម្មកាត់ដេរនៅកម្ពុជា បានផ្តល់នូវការលើកស្ទួយសេដ្ឋកិច្ចជាតិ យ៉ាងច្រើន ហើយគេមើលឃើញថា នឹងបន្តដំណើរបែបនេះនាពេលឆាប់ៗខាងមុខទៀត ។ ទោះបីជាមានការលូតលាស់ដូចដែលបានរៀបរាប់មកនេះក្តី ក៏កម្មករកាត់ដេរដែលមានចំនួន៦៥%នៃអ្នកដែលមានការងារធ្វើនៅក្នុងវិស័យផលិតកម្មក្នុងប្រទេស បើធៀបជាមួយកម្លាំងពលកម្មសរុបនៅទូទាំងប្រទេសគឺ មានតែប្រហែល៤% ប៉ុណ្ណោះ។

---

[២៩] សូមមើលអត្ថបទរបស់លោក Hach, "*Cambodia's Garment Industry in 2005 and Beyond*"

[៣០] Salinger et al, *Measuring Competitiveness and Labor Productivity in Cambodia's Garment Industry*.

ហេតុដូច្នេះ ការកាត់បន្ថយភាពក្រីក្រទូទាំងប្រទេស ត្រូវពឹងផ្អែកជាសំខាន់ទៅលើផលិតភាពនៃវិស័យកសិកម្ម ព្រមទាំងសហគ្រាសធុនតូច និងធុនមធ្យមនៅជនបទដែលមានប្រជាជនភាគច្រើនបំផុតកំពុងរស់នៅ និងធ្វើការនៅទីនោះ ។ ការបង្កើនតម្លៃបន្ថែមនៅក្នុងវិស័យទាំងនេះ អាចជួយពង្រីកឧស្សាហកម្មច្រើនប្រភេទ និងពង្រីកទីផ្សារក្នុងស្រុកថែមទៀត ។ ការលូតលាស់នៃកសិឧស្សាហកម្ម អាចបង្កើតបានការងារនៅជនបទ ទន្ទឹមនឹងនោះដែរក៏ផ្តល់នូវទុនសំរាប់យកទៅធ្វើវិនិយោគបន្ថែមទៀត ។ ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម អាចជួយលើកស្ទួយពាណិជ្ជកម្មក្នុងស្រុក ព្រមទាំងផ្តល់នូវផលប្រយោជន៍ដល់អ្នកផ្គត់ផ្គង់ពីមូលដ្ឋាន ដែលនឹងមានតួនាទីចូលរួមចំណែកលើកស្ទួយឧស្សាហកម្មកាត់ដេរ និងឧស្សាហកម្មដទៃទៀតដែរ ។ ប៉ុន្តែ យុទ្ធសាស្ត្របែបនេះ ក៏ទាមទារឱ្យមានការចាប់ផ្តើមកំណែទំរង់ ជាពិសេស ការសំរបសំរួលពាណិជ្ជកម្ម និង ដកចេញនូវរបាំងនានាដែលជាឧបសគ្គ ចំពោះការលូតលាស់នៃឧស្សាហកម្មច្រើនប្រភេទទៀត[៣១] ។ ក្នុងខណៈពេលដែលមានការលើកស្ទួយការលូតលាស់ផ្នែកកសិកម្ម និងឧស្សាហកម្ម ការជំរុញអោយមានទីផ្សារក្នុងស្រុក និងនាំចេញក្រៅប្រទេសផងនោះ ការដាក់ចេញនូវវិធានការហ្មត់ចត់របស់រដ្ឋក្នុងការបោសសំអាតអំពើពុករលួយ អាចមានឥទ្ធិពលយូរអង្វែង និងផ្តល់ផលប្រយោជន៍ដល់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទជាមិនខាន ។

---

[៣១] សូមមើល *Cambodia Seizing Global Opportunity.*

## ឧបសម្ព័ន្ធទី ១៖ សិក្ខាកាម និងក្រុមអេឌីអាយ

### ឈ្មោះ និងអង្គការរបស់សិក្ខាកាមដែលចូលរួមស្រាវជ្រាវ

| | |
|---|---|
| Hun Leakhena | Krom Akphiwat Phum |
| Keo Chamroeun | NGO Forum on Cambodia |
| Keo Chenda | Enfants & Developpment |
| Nop Sarom | Family Health Promotion |
| Nut Mak Chhong | Kunathor |
| Sok Bun Sean | Cambodian Association for Development of the Economy Together |
| Uch Ponh | Cambodian Women for Peace and Development |
| Khieu Thoun | Cambodian Women's Crisis Center |
| Yim Nimola | Khmer Women's Voice Center |
| Chhoeung Sun Lay | Cambodian Women's Development Association |
| Hem Sakhorn | Chamreun Chiet Khmer |
| Sok Sophal | Cambodian Development and Relief Center for the Poor |

### ក្រុមអេឌីអាយ

| | |
|---|---|
| Oeur Il | Cooperation Committee for Cambodia/ADI Project |
| Seng Savuth | Cooperation Committee for Cambodia/ADI Project |
| Ang Sopha | Cooperation Committee for Cambodia/ADI Project |
| Hor Sakphea | Cooperation Committee for Cambodia/ADI Project |
| John McAndrew | Cooperation Committee for Cambodia/ADI Project |

# ឯកសារស្រាវជ្រាវរបស់គំរោងអេឌីអាយ

- អំពើហិង្សាក្នុងគ្រួសារនៅក្នុងតំបន់តាំងទីលំនៅថ្មីតាមជាយដែន នៅប៉ោយប៉ែតដែលមានកំណើនមនុស្សយ៉ាងឆាប់រហ័ស: ការស្រាវជ្រាវនៅក្នុងភូមិពីរ ក្នុងឃុំប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ខែ ឧសភា ២០០៥

- ការលើកកំពស់ក្នុងការប្រើប្រាស់ធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច នៅភាគឦសាននៃប្រទេសកម្ពុជា ខែ ធ្នូ ២០០៤

- ការឆ្លើយតបរបស់ជនជាតិដើមភាគតិច ទៅនឹងការថយចុះនៃធនធានធម្មជាតិ: ការសិក្សាស្រាវជ្រាវនៅក្នុងភូមិពីររបស់ជនជាតិស្មៀង នៅស្រុកស្នួល ខេត្តក្រចេះ ខែ កញ្ញា ២០០៤

- ការប្រើប្រាស់គ្រឿងញៀនជាបញ្ហាសង្គម: ទស្សនៈរបស់ប្រជាជននៅក្នុងភូមិបី នៅជាយក្រុងបាត់ដំបង ខែមេសា ២០០៤

- បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការលើកកំពស់អភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម: ករណីសិក្សារបស់ឃុំ/សង្កាត់ចំនួនប្រាំនៅក្នុងប្រទេសកម្ពុជា ខែ មីនា ២០០៤

- ការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ: និន្នាការនាពេលបច្ចុប្បន្ន នៅភូមិចំនួន៤ ក្នុងខេត្តបាត់ដំបង ខែ ធ្នូ ២០០៣

- ផលប៉ះពាល់នៃឧស្សាហកម្មទេសចរណ៍មកលើជីវភាពរស់នៅរបស់ប្រជាជន នៅតំបន់ឧទ្យានអង្គរ ខែ ធ្នូ ២០០២

- ការសិក្សាស្រាវជ្រាវទ្រង់ទ្រាយតូច ស្តីពីការបែងចែកដីធ្លី នៅប្រទេសកម្ពុជា: ចំនុចសំខាន់៧ដែលទទួលបានពីករណីសិក្សាចំនួនបី ខែ វិច្ឆិកា ២០០១